បញ្ញា

# មនុស្សលោក



ចំណេះទូទៅ

ចម្លងដោយ
បណ្ណាគារ វិទ្យាតេជ
ព.ស.២៥៤៤ គ.ស.២០០១

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង
**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**
ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត
ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ
សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់
**អង្គការរីស្សូ កូសី-កៃ វិទ្យាស្ថានបើកទូលាយ**
**ករុណាខ្មែរ** និង **មូលនិធិខ្មែរសម្រាប់ការសិក្សា**
ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh www.elibraryofcambodia.org

# មនុស្សលោក

## ការដោះស្រាយអំពីបញ្ហាមនុស្ស

**សុង-ស៊ីវ**

**និពន្ធទី ៣៦**

ផ្សាយចេញពី

លេខ ៥៨ វិថីយុគន្ធរ ភ្នំពេញ

ពុទ្ធសាសនបណ្ឌិត្យ
បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

បោះពុម្ពលើកទី ២

ព. ស. ២៥១៦ គ. ស. ១៩៧២

# បុព្វកថា

សៀវភៅមនុស្សលោកនេះ ជាមធ្យោបាយមួយយ៉ាងសំខាន់ សម្រាប់ដោះស្រាយបញ្ហាផ្ទាល់ខ្លួន របស់មនុស្សម្នាក់ៗ ក្នុងពេលដែលបានជួបប្រទះ នូវវិបត្តិទាំងឡាយ មានការស្លាប់ព្រាត់ប្រាសចាកបុត្រភរិយា ការខូចខាតទ្រព្យសម្បត្តិ ការខូចយសស័ក្តិ ការមានជម្ងឺរោគាបៀតបៀន និងការមានវិបត្តិស្នេហាជាដើម ។ កាលបើវិបត្តិទាំងនេះកើតមានឡើង សូមមិត្តអ្នកអានទាំងឡាយ យកសៀវភៅមនុស្សលោកនេះមកអាន ឲ្យបានច្រើនចប់ ហើយត្រិះរិះពិចារណាតាមអត្ថបទមួយៗ ដែលមានក្នុងសៀវភៅនេះ មិត្តនឹងបានក្សាន្តចិត្ត ធូរថយចាកវិបត្តិនោះៗ ពុំខាន ថែមទាំងបានយល់ហេតុផលផ្សេងៗ អាចដោះស្រាយបញ្ហាមនុស្ស បានដោយងាយ ។

ភ្នំពេញ ថ្ងៃទី ២៥ វិច្ឆិកា ១៩៦៧

**សុខ-ស៊ីន**

# បញ្ជីអត្ថបទ


| ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|
| ១-មនុស្សគឺអ្វី | ១ |
| ២ អំពីសរីរយន្ត | ៣ |
| ៣- អ្នកវិទ្យាសាស្ត្រពិសោធរកចរិតចិត្តមនុស្ស | ៨ |
| ៤- អ្នកវិទ្យាសាស្ត្រចង់ធ្វើពិសោធជីវិតរបស់មនុស្ស | ១១ |
| ៥- ដើមកំណើតចិត្តមនុស្ស | ១២ |
| ៦-រូបភាពទីលំនៅរបស់ចិត្ត | ១៤ |
| ៧- សម្ពន្ធភាពនិងសរីរយន្ត | ២៣ |
| ៨- កម្មវិធីបច្ចេកទេសនៃការលាងសរីរយន្ត | ២៦ |
| ៩-រូបភាពកំណើតកូនក្នុងផ្ទៃមាតា | ៣០ |
| ១០- ហេតុអ្វីបានជាមនុស្សមានរូបមិនដូចគ្នា | ៣២ |
| ១១- ជនកកម្ម ៤ បែប | ៣៥ |
| ១២- ហេតុអ្វីកូនមានរូបរាងកាត់ទៅរកម៉ែឪ | ៣៨ |
| ១៣- ដើមកំណើតសត្វញីឈ្មោល | ៤២ |
| ១៤-ហេតុអ្វីមនុស្សធ្វើអំពើអាក្រក់ច្រើនជាងល្អ | ៥០ |
| ១៥- ហេតុអ្វីមនុស្សលោកមានសុខទុក្ខស្នេហាស្រឡាញ់ស្អប់ | ៦៩ |
| ១៦- កំណើតនៃសេចក្តីសុខទុក្ខ | ៧១ |
| ១៧- កំណើតនៃសេចក្តីស្នេហាស្រឡាញ់ស្អប់ | ៨៧ |
| ១៨- ការដោះស្រាយវិបត្តិស្នេហា | ៩៧ |
| ១៩- ហេតុអ្វីបានជាមនុស្សចេះសើចយំ | ១០១ |

| ឈ្មោះអត្ថបទ | លេខទំព័រ |
| --- | --- |
| ២០- អំពីការសើប | ១០៣ |
| ២១- អំពីការយល់ | ១០៩ |
| ២២- រូបភាពសរសៃវិញ្ញាណ | ១២០ |
| ២៣- រូបសរសៃវិញ្ញាណសំខាន់ៗក្នុងខ្លួនមនុស្ស | ១២១ |
| ២៤- របៀបប្រតិកម្មដែលនាំឲ្យសើបយល់ | ១២៣ |
| ២៥- រូបភាពផ្នែកខាងក្នុង | ១២៥ |
| ២៦- រូបភាពផ្នែកខាងក្រៅ | ១២៦ |
| ២៧- អំពីសង្គមមានជី | ១២៨ |
| ២៨- គុណសម្បត្តិនិងគុណវិបត្តិក្នុងសង្គមរុក្ខជាតិ | ១២៩ |
| ២៩- គុណសម្បត្តិនិងគុណវិបត្តិក្នុងសង្គមសត្វតិរច្ឆាន | ១៤០ |
| ៣០- សង្គមមនុស្ស | ១៥៣ |
| ៣១- សង្គមជាប្រភពនៃលាភសក្ការៈកេរ្តិ៍ឈ្មោះយសសក្តិ | ១៥៤ |
| ៣២- សង្គមជាប្រភពនៃសេដ្ឋកិច្ចទ្រព្យសម្បត្តិមាសប្រាក់ | ១៥៩ |
| ៣៣- សង្គមជាប្រភពនៃសុជីវធម៌ជាដើម | ១៦២ |
| ៣៤- សង្គមជាប្រភពនៃចំណីអាហារ | ១៦៥ |
| ៣៥- សង្គមជាចំណីអាហាររបស់សង្គម | ១៦៨ |
| ៣៦- អំពីឋាននិព្វាននិងលោកធាតុ | ១៧៨ |
| ៣៧- អំពីសេចក្តីសុខក្នុងឋាននិព្វាន | ២០០ |
| ៣៨- អត្ថបទប្រៀបធៀបអំពីរឿងនិព្វាន | ២០៣ |

បើតាមចំណាំ ការស្គាល់មនុស្សនោះ ស្គាល់ច្បាស់ពិតប្រាកដណាស់គ្មានភាន់ច្រឡំទេ សូម្បីក្មេងតូច ៗ មិនទាន់ចេះនិយាយស្តី មិនទាន់ចេះដើរផង ក៏វាស្គាល់មនុស្សគឺមាតាបិតាវាច្បាស់លាស់ណាស់ គ្រាន់តែឃើញមុខវាស្គាល់ភ្លាម វាយំវាស្រែក វាមិនព្រមតាម មិនព្រមផ្ញើសេចក្តីទុកចិត្តស្និទ្ធស្នាលឡើយ ។

ដូច្នេះ បញ្ហាស្គាល់មនុស្សនេះ ដូចជាចប់សព្វគ្រប់អស់ទៅហើយ គ្មានការសិក្សា ដើម្បីឲ្យស្គាល់មនុស្សទៀតទេ ។

ប៉ុន្តែ បើគិតឲ្យហួស ពីការស្គាល់ តាមទម្លាប់បន្តិចទៅមុខ ជាយកដៃទប់ថ្ងាសហើយថ្ងូរថា «មនុស្សគឺអ្វី? អ្វីជាមនុស្ស?» ហើយបដិសេធការស្គាល់មនុស្សតាមទម្លាប់នោះ ទុកដូចជាការយល់សប្តិទៅវិញ, ភាពងងឹតក្នុងគំនិត ក៏កាន់តែមានច្រើនឡើង ៗ បញ្ហាមនុស្ស ក៏លេចចោទឡើងដើរបន្តបន្ទាប់គ្នារកទីបំផុតគ្មាន ។

បញ្ហាមនុស្ស ស្មុគស្មាញណាស់ ព្រោះជាបញ្ហាពិភពលោកទាំងមូល, អ្នកនិពន្ធខ្ញុំ មិនអាចដោះស្រាយឲ្យពិស្តារសព្វគ្រប់បានទេ គ្រាន់តែដោះស្រាយជូន តាមយោបល់ដែលមាន, ដើម្បីជាមេគំនិត ចំពោះអ្នកអានទាំងឡាយ សម្រាប់រិះគិតរកសេចក្ដីពិតឲ្យឃើញវែងឆ្ងាយតទៅទៀត, ដូចខាងក្រោមនេះ

## អ្វីជាមនុស្ស

សរីរយន្តរបស់ចិត្តដែលស្គាល់នូវហេតុ និងមិនមែនហេតុ គឺជាមនុស្ស, តាមលោកវោហារ សន្មតហៅសរីរយន្តរបស់ចិត្តបែបនេះថា ជាមនុស្សផង ជាបុគ្គលផង ជាជនផង ជាសត្វលោកផង ។

គ្រឿងយន្ត គឺរូបកាយមនុស្សប្រុសស្រីនេះ ជាគ្រឿងប្រដាប់មួយដែលកំរើកបានដោយកម្លាំងចក្រប្រកបគ្នា តាមបញ្ជាដួងចិត្ត, មានទ្វារ ៩ គឺទ្វារត្រចៀក ២, ទ្វារភ្នែក ២, ទ្វារច្រមុះ ២, ទ្វារមាត់១, ទ្វារវច្ចៈ១ និងទ្វារមូត្រ ១ សម្រាប់បើកបិទ បញ្ចេញ

បញ្ចូលសម្ភារធាតុ គឺដីទឹកភ្លើងខ្យល់ ដើម្បីញុំាងគ្រឿងយន្តឲ្យមានចលនាប្រព្រឹត្តទៅបានស្រួល តាមបញ្ញារបស់ចិត្តជាយន្តការី និងប្រដាប់ដោយគ្រឿងចក្រ ៤ គឺ ហត្ថចក្រ ២ បាទចក្រ ២ (ដៃ ២ ជើង ២) ន័យខ្លះថា ឥរិយាបថ ៤ ។

កាលណាសរីរយន្តនេះ ប្រើសម្ភារធាតុ គឺទឹកភ្លើងខ្យល់ មិនស្អាត មានលាយដោយមេរោគ ឬ ជាតិពុល ឲ្យចូលទៅក្នុងគ្រឿងយន្តនោះ បណ្តាលឲ្យស្ទះគាំងដើរមិនស្រួល ដែលគាប់ហៅថាមានជម្ងឺ ឬកើតរោគ, ចួនកាល ចិត្តប្រើគ្រឿងយន្តនេះហួសកម្លាំង ក៏បណ្តាលឲ្យទៅជាគាំងដើរមិនស្រួលដែរ ដូចជាអ្នកធ្វើការច្រើនហួស ឬ ដើរ ឈរ អង្គុយ ដេក ស៊ី ផឹក គិត ច្រើនហួសជាដើម ។

យប់និងថ្ងៃចេះតែកន្លងផុតទៅ ៗ សរីរយន្តក៏ចេះតែមានចលនាធ្វើការមិនឈប់ នាំឲ្យសឹកយឹតគួរខូចគ្រឿងយន្តរហូតដល់មានសណ្តករង្គោះជ្រុះបាត់សម្ភារៈខ្លះ ដូចជាធ្មេញបាក់ជ

ដើម, ឯសរសៃដែលជាគ្រឿងចងរឹតរួតគ្រឿងយន្ត និងសរសៃវិញ្ញាណ សម្រាប់នាំសារតាមបញ្ជាដួងចិត្ត ក៏ឃឹតធូរ នាំឲ្យមានការភាន់ច្រឡំខុសនាទី ដែលធ្លាប់ហៅថា វង្វេងភ្លេច ជាងងឹតថ្ងន់ ជាចាស់ជរា ។

កាលបើគ្រឿងយន្ត ចាស់ទ្រេកទ្រោកដូច្នេះហើយ, ក្នុងលោកនេះ សូម្បីតែគ្រឿងយន្តសាមញ្ញទាំងឡាយ មានរថយន្តជាដើម ក៏មិនអាចមានសម្ភារៈផ្លាស់ផ្ដូរឲ្យថ្មីទាំងអស់ដូចដើមបានទេ, ពួកជាងទាំងឡាយយ៉ាងជំនាញក្នុងយន្តសាល គ្រាន់តែកែជួសជុលលាបថ្នាំឲ្យបានសមរម្យ ល្មមប្រើការបានជាបណ្ដោះអាសន្នប៉ុណ្ណោះ មិនយូរប៉ុន្មានគេត្រូវបោះបង់រថយន្តនោះចោលរកថ្មីទៀត ។

ឯសរីរយន្តក៏ដូច្នោះដែរ, កាលបើចាស់មានចលនាប្រព្រឹត្តទៅមិនស្រួលហើយ គេតែងនាំយកទៅជួសជុលកែកុនក្នុងយន្តសាល គឺមន្ទីរពេទ្យ, សូម្បីតែគ្រូពេទ្យពូកែបេះកាត់ត បេះបណ្ដុះ

ធ្មេញ ចេះបញ្ចេញបញ្ចូលឈាម ចេះប៉ះផុលថ្លើមប្រមាត់យ៉ាងណា ក៏គ្រាន់តែជាការបណ្ដោះអាសន្នប៉ុណ្ណោះ យូរបន្តិចទៅ ក៏ត្រូវតាំងប្រើការមិនកើត ដែលធ្លាប់ហៅថា ស្លាប់តាមពាក្យបច្ចេក-ទេស សម្រាប់ប្រើចំពោះសរីរយន្ត ។ កាលបើស្លាប់ហើយ សម្បកសរីរយន្តនោះ ត្រូវគេយកទៅកប់ឬដុតចោល ពុករលួយកើតជាដីទឹកភ្លើងខ្យល់ ។ រីឯយន្តការីម្ចាស់សរីរយន្តគឺដួងចិត្ត-ក៏ត្រូវទៅកសាងធ្វើគ្រឿងយន្តថ្មីទៀតតាមសមត្ថភាពរបស់ខ្លួន ។

សរីរយន្តនេះ ជាគ្រឿងយន្តពិសេសបំផុតក្នុងលោក ដែលអ្នកប្រាជ្ញទាំងឡាយ មានអ្នកប្រាជ្ញវិទ្យាសាស្ត្រជាដើមធ្វើតាមមិនកើត ។

សម័យបច្ចុប្បន្ននេះ ពួកបណ្ឌិតទាំងឡាយខាងយន្តសាស្ត្របានសាងគ្រឿងយន្តគ្រប់បែប សុទ្ធតែប្រកបដោយវិជ្ជាបច្ចេក-ទេសយ៉ាងជំនាញក្រៃលែង ដូចជាកាំជ្រួចហោះ ថាសហោះ យន្តហោះប្រតិកម្ម ផលយានយន្តបរមាណូ សម្រាប់បើកលើ

ទឹក សម្រាប់មុជទឹក និងយន្តហោះចូរបញ្ជាដែលប្រើឲ្យហោះ ទៅប្រតិបត្តិការខ្លួនឯង មិនបាច់មានមនុស្សបើកជាដើម ឃើញថាសុទ្ធតែជាគ្រឿងយន្តយ៉ាងវិសេសអស្ចារ្យគួរឲ្យស្ញើចមែន ។

ប៉ុន្តែបើយកគ្រឿងយន្តទាំងនោះ មកប្រៀបធៀបនឹងសរីរ-យន្តឃើញថាចាញ់ប្រៀបសរីរយន្តឆ្ងាយណាស់ ដូចមេឃនិងដី ព្រោះគ្រឿងយន្តទាំងឡាយ មានរថយន្តជាដើមនោះ ជាអវិ-ញ្ញាណកយន្ត គ្មានចេះដឹងអ្វីទាំងអស់ គេទុកចោលនៅទីណាក៏នៅទីនោះដូចជាដុំដី , សូម្បីយន្តហោះចូរបញ្ជាដែលចេះហោះទៅប្រតិបត្តិការខ្លួនឯង ឥតមនុស្សបើកនោះ ក៏ទៅតាមបញ្ជាដែលមនុស្សបើកប្រដាប់បញ្ជា នៅក្នុងស្ថានីយដែរ បើគ្មានប្រដាប់បញ្ជាទេ យន្តហោះនោះក៏មិនអាចទៅណាបានឡើយ ។

ដូច្នេះឃើញថា គ្រឿងយន្តទាំងឡាយក្នុងលោក សុទ្ធតែត្រូវប្រាស្រ័យទាក់ទងនឹងសរីរយន្តទាំងអស់ គឺត្រូវយកថាម-ពលពីសរីរយន្តទៅផ្សំផង ទើបគ្រឿងយន្តទាំងនោះមានចលនា

ប្រព្រឹត្តទៅបាន ។

តើក្នុងសរីរយន្តនោះ មានអ្វីជាថាមពល បានជាចេះដឹង ស្គាល់ខុសត្រូវ មានចលនារស់រវើកខ្លួនឯង មិនចាំបាច់មានប្រដាប់បញ្ជា ហើយអាចស្ថាបនា និងបញ្ជាដល់គ្រឿងយន្តដទៃទៀតបាន ? ។

ចំណុចនេះ ចុចចំបញ្ហាដែលស្មុគស្មាញជាអតិបរមា ជាបញ្ហាអាថ៌កំបាំងកប់បាត់ក្នុងដុំពិភពលោក ជាច្រើនសតវត្សរ៍មក ហើយ មិនអាចដោះស្រាយឲ្យចំសេចក្តីពិតបាន ។

កាលពីសតវត្សរ៍មុន មានអ្នកប្រាជ្ញជាតិអល្លឺមង់មួយក្រុម ដឹងថាមានថាមពលម្យ៉ាងគឺចិត្ត ស្ថិតនៅក្នុងខ្លួនមនុស្ស, គេចង់ចាប់យកចិត្តនោះមកពិនិត្យមើល ដោយសំគាល់ថាមានរូបល្មមយកមកមើលបាន គេក៏ឲ្យជាងធ្វើប្រអប់កែវមួយល្មមដាក់មនុស្សទៅក្នុងនោះកើត, លុះធ្វើហើយគេយកអ្នកទោសដែលត្រូវប្រហារជីវិតម្នាក់ ចងយ៉ាងមាំ ដាក់ក្នុងប្រអប់នោះ ហើយផ្សារ

បិទយ៉ាំងជិត សូម្បីតែខ្យល់ក៏ចេញចូលមិនបាន ដើម្បីខ្ទប់ចាប់ចិត្តមនុស្សយកមកពិសោធមើល ៗ ប៉ុន្តែជាការឥតអំពើសោះ ដល់អ្នកទោសដាច់ខ្យល់ស្លាប់ដោយទប់ដង្ហើមទៅ មិនឃើញមានអ្វីដែលល្មមសំគាល់ថាចិត្តបាន ក្រៅពីសាកសពឡើយ មិនដឹងជាចិត្តអ្នកទោសនោះ ចេញទៅតាមផ្លូវណាបាត់ទៅ , គេក៏នាំគ្នាសន្និដ្ឋានថា ចិត្តគ្មានចេញទៅណាទេ គឺវាស្លាប់ជាមួយនឹងរូបកាយនោះឯង ។ល។

ការដែលមនុស្សស្លាប់ហើយ គ្មានឃើញអ្វីចេញពីរូបកាយនេះឯង ជាហេតុនាំឲ្យមានការកាន់ប្រឡុំយ៉ាំងធំ ដែលពួកមេសាសនាខ្លះ ពួកបញ្ញវន្តខ្លះយល់ថាមនុស្សឬសត្វតែស្លាប់ហើយសូន្យ គ្មានអ្វីទៅកើតទៀតទេ , ឯបុណ្យបាបនរកសួគ៌ក៏គ្មានដែរ ព្រោះគ្មាននរណាទៅកើត ទៅទទួលផលបុណ្យបាបនោះ ចង់ធ្វើអ្វីក៏ធ្វើទៅ កុំឲ្យតែគេចាប់ខ្លួនបាន នាំឲ្យមានទោសក្នុងលោកនេះ តែដល់ពេលស្លាប់វាចប់រួចគ្នាទៅហើយ ៗ

បើព្រឹត្តិការណ៍ មានមកហើយយ៉ាងនេះ តើសេចក្ដីពិត ដែលមាននៅក្នុងសរីរយន្តនោះ គឺអ្វីទៅវិញ? បើថាមានចិត្ត នៅក្នុងសរីរយន្តមែន ដល់ពេលស្លាប់ចិត្តនោះសូន្យឬយ៉ាង ណា ? ចិត្តកើតពីអ្វី ? អ្នកណាបង្កើតចិត្ត ?

ដើម្បីរាវរកសេចក្ដីពិតឲ្យឃើញក្នុងរឿងនេះ ជាបឋម ខ្ញុំ សូមធ្វើសេចក្ដីសន្និដ្ឋានថា រឿងចិត្តនេះ អ្នកប្រាជ្ញខាងវិទ្យា-សាស្ត្រ ពិតជារកមិនឃើញទេ ៖មានតែទស្សនវិជ្ជាផ្នែកចិត្ត-សាស្ត្រ (Philosophy of mind) ដែលមានក្នុងទ្រឹស្ដីពុទ្ធ-សាសនាមួយគត់ ទើបរកសេចក្ដីពិតក្នុងខ្លួនមនុស្សឃើញ ព្រោះ ព្រះពុទ្ធ ព្រះអង្គចេះដឹងរឿងមនុស្សនេះពិតប្រាកដណាស់ជាប ដល់ញ៉ាំងមនុស្ស ឲ្យទៅកើតក្នុងទីមិនស្លាប់បាន ។

ឯអ្នកប្រាជ្ញវិទ្យាសាស្ត្រ គ្រាន់តែចេះដឹងត្រឹមសម្បុររូប កាយមនុស្ស ដែលកើតមានហើយតែប៉ុណ្ណោះ គឺគ្រាន់តែចេះ ដឹងថា ក្នុងខ្លួនមនុស្សមានចិត្ត មានឆ្អឹង សាច់ ស្បែក សរសៃ

ថ្លើម ប្រមាត់ ។ល។ ចំនួនប៉ុណ្ណេះប៉ុណ្ណោះ មាននាទី ធ្វើការយ៉ាងនេះយ៉ាងនោះ, មានការប្រាស្រ័យគ្នាបែបនេះបែបនោះ មនុស្សសត្វ ស្លាប់មកពីហេតុនេះ រស់មកពីហេតុនោះ ។ល។ ត្រង់ជីដូនជីតារបស់ហេតុដែលនាំឲ្យរស់ឲ្យស្លាប់នោះ មកពីអ្វី ទៀតមិនដឹង រកមិនឃើញ ព្រោះវិទ្យាសាស្ត្រកើតមកពីទស្សន-វិជ្ជា គឺមានទស្សនវិជ្ជាជាអ្នកបង្កើត, ដូចជាសាខាមួយនៃទស្សន-វិជ្ជាផ្នែកចិត្តសាស្ត្រ (Philosophy of mind) បង្កើតបានវិទ្យា-សាស្ត្រមួយឈ្មោះចិត្តវិទ្យា (Psychology) ។

ក្នុងសម័យឋានព្រះចន្ទនេះ ពួកអ្នកប្រាជ្ញវិទ្យាសាស្ត្រខាងវេជ្ជសាស្ត្រ គេកំពុងចាប់អារម្មណ៍យ៉ាងខ្លាំង ចង់ធ្វើឥសីដប់ប្រស់មនុស្សសត្វ ដែលស្លាប់ហើយឲ្យរស់វិញ, គេបានពិសោធឃើញថា មនុស្សសត្វដែលស្លាប់ភ្លាមៗ អាចផ្សប៉ាំកែឲ្យរស់វិញបាន ដោយធ្វើឲ្យខួរក្បាលដើរឡើងវិញ ។

ថ្ងៃមួយនៅក្រុងហ្វេនិក នៃ ស. រ. អ. គេបានយកសព

លោក បេត ហ្វុន៖ ដែលស្លាប់ដោយកើតដំបៅមហារីកក្នុង ជន្មាយុ ៧៣ ឆ្នាំ ទៅដាក់ក្នុងបន្ទប់ពិសោធក្លាមួយរំពេច ត្រាំក្នុងអាងទឹកជាតិគីមីម៉្យាងឈ្មោះ « អេហ្សូត » ដែលមានសីតុណ្ហភាព ២៦០ អង្សា ក្រោមសូន្យទៅទៀត ដើម្បីធ្វើឲ្យមានដង្ហើម ឲ្យខួរក្បាលដើរឡើងវិញ ។ ប៉ុន្តែធ្វើដូចម្តេចនឹងបានរស់ បើមនោធាតុគឺចិត្តដែលជាវត្ថុសំខាន់បំផុតក្នុងការធ្វើឲ្យមានជីវិតនោះ ចេញផុតពីរូបកាយលោក បេត ហ្វុន ទៅហើយ ។ ឯសិល្បផលទាំងនោះ គេបានប្រកាសថា បើសិនជាមើលដំបៅមហារីក ដែលបណ្តាលឲ្យស្លាប់នោះបានជា លោក បេត-ហ្វុន ពិតជាបានជីវិតឡើងវិញមិនខាន ។

## ដើមកំណើតចិត្តមនុស្សឬមនោធាតុ

តាមពុទ្ធទស្សនៈ ផ្នែកបរមត្ថវិជ្ជាថា ក្នុងសរីរយន្ត គឺក្នុងខ្លួនមនុស្ស មានធម្មជាតិម៉្យាង ជាអរូបី ប្រកបដោយថាមពលវិសេសបំផុតក្នុងពិភពលោក ឈ្មោះ "មនោធាតុ" ជាធាតុដ៏

(Corps composé) គឺចិត្ត ស្ថិតនៅក្នុងខ្លួនត្រង់មូលដ្ឋានពីរ

១- ស្ថិតនៅត្រង់ទីប្រជុំសរសៃធំទាំង ៥ ក្នុងខួរក្បាល សម្រាប់ធ្វើការគ្រប់យ៉ាង ។

២- ស្ថិតនៅត្រង់បេះដូងផ្នែកខាងលើ សម្រាប់សម្រាកដេក និងចូលនិរោធរបស់អ្នកមានឈាន និងពេលជិតស្លាប់ ។

មនោធាតុនេះ ពេលមនុស្សសត្វស្លាប់មិនសូន្យទេ ត្រូវទៅកើតទៀត, បានជាមើលមិនឃើញ ព្រោះល្អិតបំផុតក្រៃលែងជាអតិបរមាណូ លើសលុបជាងធាតុបរមាណូទាំងឡាយរាប់លានដង ។ ពួកអ្នកប្រាជ្ញវិទ្យាសាស្ត្រ គ្មានប្រដាប់រាវរកធាតុនេះឃើញឡើយ ព្រោះហួសវិស័យការចេះដឹង ផ្នែកវិទ្យាសាស្ត្រ, មានតែប្រដាប់វិសេសប៉ុណ្ណោះគឺ សព្វញ្ញុតញ្ញាណ ទើបរាវរកឃើញ យកមកប្រើការបាន ។

មនោធាតុ គឺចិត្តនេះ ព្រះសម្ពុទ្ធបានរាវរកដោយគ្រឿងប្រដាប់សព្វញ្ញុតញ្ញាណ ឃើញមាននៅពាសពេញពិភពលោក ច្រើន

ពុទ្ធសាសនបណ្ឌិត្យ បណ្ណាល័យ LIBRARY BUDDHIST INSTITUTE




១- ខួរក្បាល ។ ២- ទីប្រជុំសរសៃធំទាំង ៥ ក្នុងខួរក្បាល ជាការិយាល័យទី១ របស់ចិត្ត ស្ថិតនៅធ្វើការគ្រប់យ៉ាង ។ ៣- សរសៃវិញ្ញាណទាក់ទងនឹងខួរក្នុងឆ្អឹងកញ្ចឹងក សម្រាប់បន្ថយល្បឿនចលនាបេះដូងជាដើម ។ ៤- សរសៃវិញ្ញាណទាក់ទងនឹងខួរក្នុងឆ្អឹងខ្នង សម្រាប់ញ៉ាំងចលនារូបកាយ មានចលនាបេះដូងជាដើមឲ្យដើរញឹកញាប់ជាប់រហ័ស ។ ៥- បេះដូងផ្នែកខាងលើ ជាអាសយដ្ឋានទី ២ របស់ចិត្ត សម្រាប់សម្រាកដេក ឬចូលនិរោធ និងសម័យមរណជវនពេលជិតស្លាប់ ។ ៦- តួបេះដូង ។ ៧- ខួរក្នុងឆ្អឹងកញ្ចឹងក ។ ៨- ខួរក្នុងឆ្អឹងខ្នង ។

ជាធាតុដទៃៗទៀតទាំងអស់, ដូចកាលព្រះអង្គទើបបានត្រាស់ដឹងនូវចុតូបបាតញាណ ព្រះអង្គមានព្រះតម្រាស់ថា «មនោធាតុគឺដួងចិត្តមនុស្សសត្វ មានព្រោងព្រាតពេញអាកាស ខ្លះកំពុងស្វែងរកភព ខ្លះកំពុងចុតិ ខ្លះកំពុងបដិសន្ធិ» ។ល។ ព្រោះមនោធាតុនេះ កើតមកពីអវិជ្ជានិងសង្ខារ ។.

អវិជ្ជា = ក្នុងអង្គសេចក្តីនេះ ជាឈ្មោះរបស់ធាតុសុខុម (Gorps simble) ទាំង ៥ គឺដី ទឹក ភ្លើង ខ្យល់ អាកាស ។ ក្នុងធាតុមួយៗនេះ មានសម្ពន្ធធាតុ ៨ យ៉ាងល្អិតនៅក្នុងនោះទៀតគឺ: ធាតុដី មាន ដី ទឹក ភ្លើង ខ្យល់ ពណ៌ ក្លិន រស ឱជា នៅក្នុងនោះផង ។ ឯធាតុ ទឹក ភ្លើង ខ្យល់ អាកាស ក៏មាន ៨ៗ ដូចគ្នាទាំងអស់ ។

សម្ពន្ធធាតុទាំង ៨នោះ ល្អិតពេកណាស់ កប់បាត់ក្នុងមេធាតុនោះៗ មើលដោយកែវអតិសុខុមទស្សន៍មិនឃើញឡើយ ឧបមាដូចគ្រាប់រុក្ខជាតិ, ក្នុងគ្រាប់នោះមានឫស ដើម មែក ស្លឹក ផ្កា ផ្លែ

កប់នៅខាងក្នុង តែមើលមិនឃើញ, កាលបើគេយកគ្រាប់ទៅដាំ គ្រាប់នោះអាចបញ្ចេញ ឫស ដើម មែក ស្លឹក ផ្កា ផ្លែ ឲ្យគេឃើញបានយ៉ាងងាយ ។

ការពិត ធាតុទាំង៥ គឺដី ទឹក ភ្លើង ខ្យល់ អាកាស នេះគ្មានទេវតា ឬព្រះអង្គណាបង្កើតទេ គឺជាមេធម្មជាតិ ប្រចាំពិភពលោក ។ ឯធាតុទាំងឡាយដែលមានឈ្មោះ បច្ចេកទេសតាមក្បួនវិទ្យាសាស្ត្រថា នីត្រូហ្សែន (Nitrogène) អុកស៊ីហ្សែន (Oxygène) ឧស្ម័នទឹក (Vapeur d·eau) អារហ្គុង (Argon) ឧស្ម័នកាបូនិក (Caz carbonipue) អ៊ីដ្រូហ្សែន (Hydrogène) គ្រីបតុង (Krypton) នេអុង (Néon) និង ហេល្យ៉ូម (Hèlium) ជាដើមនេះ ក៏មាននៅក្នុងមេធាតុទាំង ៥នេះឯង ។

សង្ខារៈ=គឺការតាក់តែង ជាឈ្មោះចលនានៃការផ្សំធាតុ ព្រោះហេតុទាំង៥ នេះ កាលបើប៉ះគ្នាហើយ កើតជាឈ្នាន់ជាន់

បង្វិលពិភពលោក ឲ្យមានដំណើរវិលវល់ជានិច្ចឥតឈប់ឈរ គឺ
ធាតុភ្លើងបណ្តាលឲ្យមានកំដៅទៅប៉ះនឹងធាតុទឹក ហើយស្រូបយក
ចំហាយទឹកពីផែនដី ពីស្ទឹង ទន្លេ សមុទ្រ ឡើងទៅក្នុងអាកាស
កើតជាពពក, ធាតុខ្យល់ត្រជាក់ទៅប៉ះនឹងពពកនោះ កើតជា
ទឹកភ្លៀងធ្លាក់មកដីវិញ, ធាតុភ្លើងទៅប៉ះនឹងទឹកដែលធ្លាក់មក
នោះ ក៏ស្រូបយកចំហាយឡើងទៅក្នុងអាកាសវិញ ចេះតែប៉ះៗ
គ្នាជាន់បង្វិលឲ្យវិលចុះឡើងគ្មានពេលចប់ ។ កាលណាធាតុ
ដីត្រូវកំដៅធាតុភ្លើងមិនស្មើ នាំឲ្យមានធាតុអាកាសក្តៅខ្លះ ត្រ
ជាក់ខ្លះ, ធាតុអាកាសផ្នែកក្តៅទៅជាស្រាលអណ្តែតឡើង, ឯ
ធាតុអាកាសផ្នែកត្រជាក់នោះធ្ងន់ ធ្លាក់ទៅនៅត្រង់កន្លែងអាកាស
ក្តៅវិញ បណ្តាលឲ្យកើតជាខ្យល់ ធ្វើឲ្យធាតុខ្យល់នៅមិននឹង
ចេះតែបក់ទៅជាដរាបឥតឈប់ឈរ ។

ចលនានៃធាតុទាំង៤ ដែលចេះតែកើតមានដោយស្វ័យប្រ
វត្តិនេះឯង បណ្តាលឲ្យចក្រវាឡប្តូរលោកធាតុ មានដំណើរវិល

ជានិច្ចគ្រប់នាទី គឺវិលពីយប់ទៅថ្ងៃ ពីថ្ងៃមកយប់; ពីរដូវក្ដៅ ទៅរដូវត្រជាក់ ពីរដូវត្រជាក់មករដូវក្ដៅ, ពីរដូវភ្លៀងទៅរដូវគ្មានភ្លៀង ពីរដូវគ្មានភ្លៀងមករដូវមានភ្លៀង ចម្លងពីធាតុមួយទៅមួយ ឲ្យចូលលាយឡំផ្សំគ្នា កកើតឡើងជាពូជនៃតិណជាតិ រុក្ខជាតិទាំងឡាយ ។ បុព្វហេតុនៃមនោធាតុ គឺចិត្តក៏ផ្ដើមមានឡើងបន្តិច ៗ ខុសពីធាតុដើមទាំង ៥ គឺ តិណជាតិរុក្ខជាតិនោះ ដូចជាចេះដឹងក្ដៅត្រជាក់ មានស្ងួត មានស្រស់មានស្លាប់ មានរស់ ។

យប់និងថ្ងៃចេះតែកន្លងច្រើនទៅ, តិណជាតិ រុក្ខជាតិនោះចេះតែចំរើនឡើង ដរាបដល់កើតជាសត្វល្អិត ៗ ពីសត្វល្អិតទៅជាសត្វធំ ៗ ពីសត្វធំទៅជាមនុស្ស ។ ឯមនោធាតុគឺចិត្តក៏មានថាមពលពេញសមត្ថភាពឡើង ។

ដើម្បីឲ្យងាយយល់ពីការផ្សំធាតុ ឲ្យកើតចំរើនឡើងជាមនោធាតុនេះ សូមនិយាយពីធំទៅតូចវិញម្ដង: អ្នកដែលមាន

មនោធាតុចំរើនដល់កំណត់ហើយ ប្រកបដោយថាមពលធំបំផុតនោះ គឺព្រះពុទ្ធ, មនោធាតុនោះ នាំឲ្យព្រះអង្គចេះដឹងសព្វគ្មានចន្លោះ, ការចេះដឹងសព្វគ្មានចន្លោះនេះ កើតមកពីការចេះដឹងល្មម, ការចេះដឹងល្មមនេះ កើតមកពីការចេះដឹងតិច, ការចេះដឹងតិចនេះ (កើតមកពីការដឹងស្ទួចស្ទើង) ស៊ើរតែគ្មានដឹងសោះ (តិណជាតិ រុក្ខជាតិ) ការដឹងស្ទួចស្ទើងស៊ើរតែគ្មានសោះនេះ កើតមកពីការឥតដឹងអ្វីសោះ (អវិជ្ជា គឺ ដី ទឹក ភ្លើង ខ្យល់ អាកាស) នោះឯង ។

ចលនានៃធាតុ ដែលបន្តការដឹកតាំងពីធាតុនៅកក់កាយដរាបដល់ប្រមូលផ្តុំផ្សំផ្គុំចម្រាញ់កើតបានជាមនោធាតុ គឺ ចិត្តនេះ ឈ្មោះថាសង្ខារ ឧបមាដូចជាមេជាងអ្នកស្ថាបនាសាងសង់នូវគ្រឿងប្រើប្រាស់ ឬ ដូចវេជ្ជបណ្ឌិតអ្នកផ្សំថ្នាំ ផ្សំធាតុ ។

ម្យ៉ាងទៀតសង្ខារនេះ ប្រៀបដូចជាគ្រឿងឧស្សាហកម្មទាំងឡាយ មានគ្រឿងឧស្សាហកម្មធ្វើស្ករជាដើម, មុននឹងធ្វើឲ្យ

កើតជាស្ករ គេត្រូវយកវត្ថុធាតុដើម (Matière 1ère) ដូចដើមអំពៅ ទឹកត្នោតជាដើម ទៅដាក់ក្នុងចលនាគ្រឿងយន្ត ឲ្យគាបកិនសង្កត់យកទឹក រួចក្លាយប្រែហាញ់ដោយកំដៅឲ្យខះគោកកក ធ្វើឲ្យក្រដាក់ស្ករតូចកើតជាគ្រាប់ស្ករ ដោយចំហាយខ្យល់ ។ កាលបើកើតជាស្ករហើយ ស្ករនេះមានថាមពលខាងបញ្ចេញរសផ្អែម បន្កើតជាតាំងម៉ៃ ជាចំណី ជាភេសជ្ជៈបានគ្រប់បែបយ៉ាងអស់តាមលោកនិយម ។

ឯចិត្តដែលកើតមកពីអវិជ្ជានិងសង្ខារ ក៏មានលំនាំប្រហាក់ប្រហែលគ្នានឹងស្ករ ដែលកើតមកពីវត្ថុធាតុដើមនិងគ្រឿងឧស្សាហកម្មនោះដែរ ។

ក្រង់ន័យនេះ អ្នកវិទ្យាសាស្ត្រគេយល់ថា មនុស្សសត្វកើតពីពូជមនុស្សសត្វ តិណជាតិ រុក្ខជាតិ កើតពីពូជតិណជាតិរុក្ខជាតិ មិនដែលកើតបន្តគ្នា ពីដីទឹកភ្លើងខ្យល់មកតិណជាតិរុក្ខ-ជាតិ, ពីតិណជាតិរុក្ខជាតិមកសត្វល្អិត, ពីសត្វល្អិតមកសត្វធំ,

ពីសត្វធំមកមនុស្សឡើយ ។

ការយល់នេះពិតជាត្រូវចំពោះបច្ចុប្បន្នហេតុនិងបច្ចុប្បន្នផល ដែលកើតមានជាពូជ ជាមេបារួចហើយ, ចំពោះអតីតហេតុអតីតផលដែលនាំឲ្យកើតមានជាពូជ កើតបានជាមេបានោះ មិនត្រូវទេ ព្រោះក្នុងក្បួនវិទ្យាសាស្ត្រាវរកមិនឃើញ ទើបគេជឿសិប់ត្រឹមតែថា មេបានិងពូជនោះជាធម្មជាតិកើតអានស្រាប់ ឬជឿថាមានព្រះម្ចាស់សួគ៌បង្កើតពូជ បង្កើតមេបាទុកក្នុងលោកនេះ, តាមពិត ពូជនិងមេបាដែលជាធម្មជាតិឲ្យកើតមានស្រាប់នោះ គឺកើតមកពីអវិជ្ជានិងសង្ខារ ការផ្សំគ្នានៃធាតុដីទឹកភ្លើងខ្យល់នោះឯង ដែលថាព្រះម្ចាស់សួគ៌បង្កើតនោះគ្មានទេ គឺគ្មានព្រះអង្គណាអាចបង្កើតបានឡើយ, សូម្បីព្រះគោតមបរមសម្ពុទ្ធជាកំពូលព្រះអរហន្ត ក៏ព្រះអង្គពុំអាចប្រកាសថាជាអ្នកបង្កើតលោក បង្កើតពូជបង្កើតមេបាឡើយ ។

ចាប់ពីពេលដែលចិត្តកើតបានឡើងហើយ មនោធាតុ

គឺចិត្តនេះ តែងប្រែប្រួលទៅតាមធាតុដើមរបស់ខ្លួន គឺ ដី ទឹក ភ្លើងខ្យល់អាកាសដែលជាធម្មជាតិមិនទៀង ចេះតែវិលវល់ពីក្តៅទៅត្រជាក់ ពីត្រជាក់មកក្តៅ, ពីថ្ងៃទៅយប់ ពីយប់មកថ្ងៃ ។ល។ ពូជមិនទៀងនេះឯងហើយ បណ្តាលឲ្យមនុស្សសត្វមិនទៀងដែរ គឺចេះតែវិលវល់ពីក្មេងទៅចាស់ ពីចាស់មកក្មេង, ពីសុខទៅទុក្ខ ពីទុក្ខមកសុខ, ពីល្អទៅអាក្រក់ពីអាក្រក់មកល្អ, ពីចេះទៅល្ងង់ពីល្ងង់មកចេះ, ពីធំទៅតូច ពីតូចមកធំ, ពីមនុស្សទៅសត្វ ពីសត្វមកមនុស្ស, ពីមានទៅក្រ ពីក្រមកមាន, ពីស្រឡាញ់ទៅស្អប់ ពីស្អប់មកស្រឡាញ់ ។ល។ ចេះតែវិលទៅតាមសកម្មភាពរបស់មនោធាតុ ដែលប្រព្រឹត្តទៅក្នុងផ្លូវល្អ អាក្រក់គ្មានទីចប់ ។

មនោធាតុគឺចិត្តដែលបានសំដែងមកនេះជាថាមពលវិសេសបំផុតមាននៅក្នុងសរីរយន្ត ទើបសរីរយន្តមានគុណភាពវិសេសប្លែកជាងគ្រឿងយន្តទាំងឡាយក្នុងលោក ដែលអ្នកប្រាជ្ញវិទ្យា-

សាស្ត្រធ្វើតាមមិនកើត ព្រោះគ្មានក្បួនផ្សំធាតុ សូបង្កើតចិត្តមនុស្សសត្វ ។

## ការបែកញែកបញ្ជាក់

## សម្ពន្ធភាពចិត្តនិងសរីរយន្ត

គ្រឿងយន្តទាំងឡាយក្នុងលោកមានៈរថយន្តជាដើម អ្នកជំនាញការខាងយន្តសាស្ត្របានយកសម្ភារៈមានដែកជាដើមដែលកើតពីធាតុទាំង៤ គឺដីទឹកភ្លើងខ្យល់អាកាស មកសាងផលិតជាគ្រឿងយន្ត ប្រហាក់ប្រហែលគ្នានឹងអ្នកជំនាញការខាងសរីរយន្ត គឺអវិជ្ជានិងសង្ខារដែរ , ប៉ុន្តែគួរឲ្យឆ្ងល់ក្រៃលែង ចំពោះស្នាដៃបច្ចេកទេសរបស់អវិជ្ជានិងសង្ខារ ដែលចេះសាងអ្នកបើកបរភ្ជាប់នឹងសរីរយន្តតែម្តង គឺសរីរយន្តមួយមានអ្នកបើកបរម្នាក់ស្រេចពីកំណើតគ្រប់សរីរយន្តទាំងអស់ សូម្បីសរីរយន្តរបស់សត្វតិរច្ឆានក៏ដូចគ្នាមិនបាច់រកអ្នកបើកបរទៀតឡើយ ។

តើវិធីសាងភ្ជាប់នោះ មានបច្ចេកទេសដូចម្តេច?

យកអ្វីទៅផ្សំនឹងអ្វី ទើបកើតជាយ៉ាងដូច្នោះ ?

តាមការស្រាវជ្រាវឃើញៈ ការចាប់ផ្ដើមសាងដំបូងបំផុត អ្នកជំនាញការឈ្មោះសង្ខារផ្សំសហការធាតុទាំង៥ គឺ ដី ទឹក ភ្លើង ខ្យល់អាកាសដោយវិធីបច្ចេកទេស តាមចង្វាក់ចលនានៃធាតុ ដែលវិលជាប់ជានិច្ច ដូចបាននិយាយហើយក្នុងខាងដើម ដរាប កើតបានជាមនោធាតុគឺចិត្តឡើង ។

កាលកើតបានមនោធាតុហើយ ក្នុងមនោធាតុនោះមានមេ ថាមពលវិសេស ៣ គឺ

១- មនៈ មេធាតុសម្រាប់ឆាកឆេកអារម្មណ៍,

២- វិញ្ញាណៈ មេធាតុសម្រាប់ដឹងនូវអារម្មណ៍,

៣- ចិត្ត មេធាតុសម្រាប់គិតសន្សំនូវអារម្មណ៍ ។

និងសហភាពជាតិបច្ច័យ៩ យ៉ាងទៀតផ្សំស្រេចពីកំណើតមកគឺ:

១- នាមរូប គឺសរីរយន្ត និងចិត្តចេតសិក,

២- អាយតនៈ ប្រដាប់ស្រូប,

៣- ផស្សៈ ការទទួលសម្ផស្ស,

៤- វេទនា ការសោយអារម្មណ៍,

៥- តណ្ហា ការបង់ប្រាថ្នា,

៦- ឧបាទាន សេចក្ដីប្រកាន់,

៧- ភព ទីកំណើត,

៨- ជាតិ ការកើត,

៩- ជរាមរណៈ ការគ្រុឌគ្រាមនិងសេចក្ដីស្លាប់ ។ ហើយមានគ្រឿងត្រាំផ្សំភ្ជាប់នឹងមនោធាតុនោះ៤ទៀត គឺកាម១, ជាតិភូមិ១, គំនិតខុស១, សេចក្ដីល្ងង់១, (អាសវៈ៤) ។

មនោធាតុមានសម្ភារៈសម្រាប់បង្កើតសរីរយន្តផ្សំស្រេចនៅខាងក្នុងដួងចេះឯង ទើបសរីរយន្តមានអ្នកបើកបរស្រេចតែម្ដង ។ មនោធាតុនេះ ឧបមាដូចគ្រាប់ស្វាយ, ក្នុងគ្រាប់ស្វាយនោះមានគ្រឿងសម្ភារៈពាក់ ឫសស្វាយ, ដើមស្វាយ, មែកស្វាយ, ស្លឹកស្វាយ, ផ្កាស្វាយ, ផ្លែស្វាយនឹងរសជាតិស្វាយ ផ្សំស្រេចនៅ

ទាំងក្នុង, ដល់គេយកគ្រាប់ស្វាយទៅដាំក្នុងដីមានជីជាតិ ត្រូវធាតុក្តៅត្រជាក់សើមយូរបន្តិចទៅ ឫស ដើម មែក ស្លឹក ផ្កា ផ្លែ និងរសជាតិក៏កើតមានព្រមជាប់នឹងស្វាយនោះមើលឃើញច្បាស់នឹងភ្នែក, យ៉ាងណាមិញ មនោធាតុគឺចិត្ត កាលបើចុះចាប់បដិសន្ធិក្នុងផ្ទៃមាតាដែលមានជីវជាតិ មានធាតុក្តៅត្រជាក់ប្រកបដោយសភាវធម៌៤គឺកម្ម, ចិត្ត ឧតុ, អាហារគ្រប់លក្ខណៈបដិសន្ធិហើយ រូបក៏កើតឡើងបន្តបន្ទាប់គ្នាជាតួសរីរយន្ត គឺកើតជាមនុស្សពិតប្រាកដឡើង មើលឃើញច្បាស់នឹងភ្នែកដែរ ។

## កម្មវិធីបច្ចេកទេសនៃការសាងសរីរយន្ត

ក្នុងរឿងនេះ មានន័យល្អិតពេកណាស់ សុទ្ធតែត្រូវប្រើពាក្យបច្ចេកទេសទាំងអស់តាមផ្លូវបរមត្ថ, ខ្ញុំយល់ថាបើនិយាយឲ្យបានសព្វគ្រប់ល្អិតល្អន់ទៅ ក៏អ្នកអានមិនងាយស្តាប់បានដែរចំពោះអ្នកមិនធ្លាប់សិក្សាធម៌បរមត្ថ, ដូច្នេះខ្ញុំចាប់យកតែគោលៗមកនិយាយ គ្រាន់តែឲ្យដឹងដំណើរកកើតនៃរូបកាយនោះ មាន

លំនាំបែបណាខ្លះដូចតទៅនេះ :

រូបដែលកើតឡើងដោយកុសលាកុសលកម្ម តែងកើតព្រមជាមួយបដិសន្ធិចិត្ត តាំងពីថ្ងៃចុះចាប់បដិសន្ធិ ក្នុងផ្ទៃមាតាជាដំបូងមក ។ ក្នុងថ្ងៃដំបូងនោះ មានតែមនោធាតុ គឺតួបដិសន្ធិចិត្តប៉ុណ្ណោះ ជាអរូបី ស្ថិតនៅក្នុងស្បូនអាស្រ័យនឹងមេជាតិស្ពែរម៉ាតូហ្សូអ៊ីត (Spermatozoïde) គឺអតិសុខុមប្រាណដែលមានក្នុងទឹកកាមបិតា ( អាស្រ័យមេជាតិមាតាជាមូលដ្ឋានជួយឧបត្ថម្ភផង ។

ត្រង់ចំណុចនេះ អ្នកវិទ្យាសាស្ត្រដែលរកមនោធាតុមិនឃើញ គេសំគាល់ថា មេជាតិស្ពែរម៉ាតូហ្សូអ៊ីតនោះឯងជាតួចិត្តជីវិតកំណើតមនុស្សសត្វតែម្តង ។ ឯការពិតនោះ មិនមែនទេ មេជាតិនោះគ្រាន់តែជាមូលដ្ឋាននៃបដិសន្ធិចិត្តអាស្រ័យនៅ និងជាឧបករណ៍នៃជនកកម្មសម្រាប់ស្ថាបនា ឲ្យកើតជាសាច់ឈាមរូបកាយប៉ុណ្ណោះឯង ។

ក្នុងរវាង ១ អាទិត្យដំបូងនោះ មានដូចដំណក់ប្រេងថ្លាយ៉ាង

តូចបំផុតឈ្មោះ កលលរូប , ដោយអំណាចសភាវធម៌ ៤គឺកម្ម ចិត្ត ឧតុ អាហារ ជាគ្រឿងឧបករណ៍ , មនោធាតុចេះតែបញ្ចេញ ថាមពលរបស់ខ្លួនចំរើនឡើងជានិច្ចបានចំនួន ៤២ថ្ងៃកើតជាស្នាម បសាទរូបមានស្នាមក្អែកជាដើម នឹងកើតបានសាខរូប ៥ មាន ភាគក្បាលនិងពន្លកដៃជើង ៗ រូបទាំង ១០ នេះកើតឡើងក្នុងបដិ-សន្ធិកាលដោយអំណាចបដិសន្ធិចិត្ត ។ តមកចំនួន៥៦ថ្ងៃទៀត កើតបានសម្ភាររូប៤៩មានចក្ខុទសករូបជាដើម ដោយអំណាច កុសលាកុសលកម្មឈ្មោះកម្មសមុដ្ឋានកលាប ។ តមកចំនួន៤៧ ថ្ងៃទៀតកើតបានសម្ភាររូប ៦៣ មានសុទ្ធដ្ឋករូបដែលមានឱជារូប ជាគំរប់៨ជាដើមដោយអំណាចចិត្ត ឈ្មោះចិត្តសមុដ្ឋានកលាបៈ ។ តមកចំនួន២៨ថ្ងៃទៀត កើតបានសម្ភាររូប៤០មានសុទ្ធដ្ឋករូបជា ដើមចំរើនធំឡើងដោយអំណាចរដូវ ឈ្មោះថាឧតុសមុដ្ឋាន-កលាបៈ ។ តមកចំនួន១៤ថ្ងៃទៀត កើតបានសម្ភាររូប ១៩ មានសុទ្ធដ្ឋករូបជាដើម ដែលចំរើនឡើងពេញបរិបូណ៌ ដោយ

អំណាចអាហារ ឈ្មោះជាកពហារសម្ពុទ្ធកលាបៈ ។ គិតពីថ្ងៃ ទី៤៣ មកដល់ត្រឹមនេះ ហៅជាបវត្តិកាល ។

បូករួមចំនួនថ្ងៃតាំងពីចាប់បដិសន្ធិមកបាន ១៨៤ ថ្ងៃគត់បើ គិតជាខែបាន៦ខែ៤ថ្ងៃ កើតបានសម្ភាររូប៤១១គ្រប់ពេញបរិបូណ៌ជាសរីរយន្ត គឺជារូបមនុស្សប្រុសស្រី ស្ថិតនៅក្នុងគភ៌មាតា រង់ចាំពេលានឹងប្រសូតមក ។

ទារកដែលស្ថិតនៅក្នុងគភ៌មាតា អង្គុយប្រែហោងបែរមុខ ទៅខាងខ្នងមាតា ញ៉ាំងអត្តភាពឲ្យចំរើនឡើង ដោយរសជាតិ មាតា, លុះដល់គភ៌ចាស់កំណត់បាន៩ ឬ១០ ខែ ទើបប្រសូតចាក ផ្ទៃ ។ ចំណែកខាងព្រះសម្ពុទ្ធនិងស្តេចចក្រ កាលគង់នៅក្នុងផ្ទៃ មាតា បែរព្រះភ័ក្ត្រមកខាងមុខមាតា ខុសពីជនសាមញ្ញ ។

(សំដែងអំពីកំណើតចិត្តនិងការសាងសរីរយន្តសង្ខេបប៉ុណ្ណោះ)


๑๐
๑๑

# ន័យរបស់រូបតាមលំដាប់លេខរៀង

១- មាត់ស្បូន ។ ២- សាច់ស្បូន ។ ៣- មេកំណើតដែលមានក្នុងកាមបុរស (មេជាតិ ស្ពែរម៉ាតូហ្សូអ៊ីត (Spermatozoide) ជាមូលដ្ឋាននៃបដិសន្ធិចិត្ត ។ ៤- ក្រដាសស្បូន គឺក្នុងស្បូនមានប្រហោង ជុំវិញប្រហោងនោះ មានក្រដាសស្បែកកស្តើងព័ទ្ធជុំវិញ ក្រដាសនេះមិនជាប់នឹងសាច់ស្បូនឡើយ គ្រាន់តែជាស្រទាប់ ដូចឡូត មានមាត់ជាប់នឹងមាតស្បូន។ ៥- មាត់ស្រដាសស្បូន នៅអែបជិតសាច់ស្បូន, បើស្បូននៅទំនេរមិនទាន់មានគភ៌ ពេលរួមតម្រេកដោយទ្វារមគ្គ មាត់ក្រដាសស្បូននេះបើកចំហឡើង ទឹកកាមបុរសនាំមេជាតិស្ពែរម៉ាតូហ្សូអ៊ីតចូលទៅក្នុង (អូវុល Ovule) គឺក្នុងស្រទាប់ក្រដាសស្បូន តាមមាត់ក្រដាសស្បូននេះឯង ដើម្បីផ្សំគ្នាជាមួយជាតិស្ត្រី បង្កើតគភ៌ ហើយមាត់ក្រដាសស្បូននេះ បិទដោយស្វ័យ័ត មិនឱ្យមេជាតិបុរសចូលទៅទៀតបាន បិទរហូតប្រសូតបុត្រហើយ ។ ៦- កលល្អូច គឺភាពមេជាតិស្ពែរម៉ាតូហ្សូអ៊ីតក្នុងរវាង៧ថ្ងៃដំបូង។ ៧-បសាទរូបនិងសាខរូបក្នុងរវាង៤២ថ្ងៃ។ ៨-សម្ភាររូបក្នុងរវាង ៩៨ ថ្ងៃ ។ ៩- សម្ភាររូបក្នុងរវាង ១៤០ថ្ងៃ ។ ១០- សម្ភាររូបក្នុងរវាង ១៦៨ ថ្ងៃ។ ១១- សម្ភាររូបក្នុងរវាង ១៨២ ថ្ងៃ (៦ ខែ ២ ថ្ងៃ) ។

ទារកទាំងឡាយ ដែលស្ថិតនៅក្នុងគភ៌មាតា ឥតមានសេចក្តីសុខស្រួលឡើយ មានតែសេចក្តីទុក្ខលំបាកគ្រប់ពេលវេលា, សេចក្តីទុក្ខនោះឈ្មោះ គព្ភោក្កន្តិមូលទុក្ខ ។

# ហេតុអ្វីបានជាមនុស្សមានរូបមិនដូចគ្នា?

បញ្ហានេះគួរឲ្យសង្ស័យដែរ ព្រោះគ្រឿងយន្តទាំងឡាយ មានរថយន្តជាដើម ដែលមានរូបរាងផ្សេងគ្នា ដោយសារតែម៉ាកខុសគ្នាប៉ុណ្ណោះ, បើម៉ាកដូចគ្នា រូបរាងរថយន្តនោះក៏ដូចគ្នាដែរ ព្រោះពុម្ពតែមួយ ៗ ឯរូបមនុស្សប្រុសស្រីវិញ កើតពីមាតាបិតាតែមួយទុកដូចពុម្ពតែមួយដែរ ហេតុអ្វីក៏មានរូបរាងមិនដូចគ្នា?

តាមការរែករញែករកសេចក្ដីពិតៈឃើញថា រូបកាយមនុស្សប្រុសស្រីដែលមិនដូចគ្នានោះ មកពីមានពុម្ពនិងម៉ាកផ្សេង ៗ គ្នា គឺរូបមនុស្សម្នាក់មានពុម្ពមួយម៉ាកមួយ ទោះបីកើតពីមាតាបិតាតែមួយក៏មិនដូចគ្នាដែរ ព្រោះឧទរនៃមាតានោះមិនមែនជាពុម្ពជាម៉ាកសម្រាប់បោះរូបមនុស្សប្រុសស្រីឡើយ គ្រាន់តែជាបន្ទប់ទុស៊ិនសម្រាប់បណ្ដុះសម្ភាររូប ឲ្យកើតបានជាសំណុំរូបកាយមនុស្សប្រុសស្រីប៉ុណ្ណោះ ៕

ឯពុម្ពនិងម៉ាករបស់រូបកាយមនុស្សប្រុសស្រីនោះ គឺកម្ម អំពើរបស់ចិត្តមនុស្សម្នាក់ៗដែលប្រព្រឹត្តទៅក្នុងចរន្តវិថី បំពេញសកម្មភាពមានលក្ខណៈប្លែកៗគ្នាគ្រប់នាទី, ក្នុងមួយថ្ងៃៗ ចិត្តផ្លាស់ប្តូរចរន្តវិថីរាប់លានដង ពីសភាពល្អទៅអាក្រក់ ពីអាក្រក់មកល្អ មានចលនាមិនទៀងចួនខឹងស្អប់ ចួនស្រឡាញ់ពេញចិត្ត ចួនគុំគួនព្យាបាទ ចួនមានមេត្តាករុណា, ជួនសង្គ្រោះឲ្យទាន, ចួនកំណាញ់កេងកិប, ចួនសប្បាយរីករាយស្នេហា, ចួនកើតទុក្ខក្រៀមក្រំ ។ល។ លក្ខណៈផ្សេងៗគ្នានៃចិត្តមនុស្សម្នាក់ៗនេះឯងឈ្មោះថាកម្ម ជាពុម្ពជាម៉ាក សម្រាប់សាងរូបកាយមនុស្សសត្វឲ្យមានលក្ខណៈប្លែកពីគ្នា គឺប្លែកតាមវិថីចិត្តរៀង ៗ ខ្លួន ។

ព្រះសម្ពុទ្ធ ជាអគ្គមហាទស្សនវិទូ ព្រះអង្គត្រាស់បញ្ជាក់ត្រង់ចំណុចនេះថា «មនុស្សសត្វ មានកម្មជាទ្រព្យរបស់ខ្លួន, មានកម្មជាអ្នកឲ្យផល, មានកម្មជាពូជកំណើត, មានកម្មជា

នៅតែឲ្យផលមក និងមានកម្មជាទីពំនាក់អាស្រ័យ ។ល។

ពាក្យថា « កម្ម » នេះមិនមែនជាអំពើអាថ៌កំបាំង អព្ភូតហេតុ (Miracle) នោះទេ គឺជាពាក្យសាមញ្ញ ងាយស្ដាប់ ងាយយល់ណាស់ ដូចជាការធ្វើស្រែចំការ ឲ្យកើតផលផ្សេងៗ មានស្រូវជាដើម ឈ្មោះថា កសិកម្ម, ការធ្វើជំនួញដូរលក់ យកផលចំណេញ ឈ្មោះថា ពាណិជ្ជកម្ម, ការធ្វើគ្រឿងប្រដាប់ប្រើប្រាស់ឲ្យកើតផលផ្សេងៗ មានសំពត់រថយន្តជាដើម ឈ្មោះថា ឧស្សាហកម្ម, ការធ្វើគ្រឿងប្រដាប់សម្រាប់ជ្រកនៅរបស់ចិត្ត គឺរូបកាយមនុស្សប្រុសស្រី ឈ្មោះថា ជនកកម្ម ។ល។

ជនកកម្មនេះ ហាក់ដូចជាមានន័យប្លែកពីកសិកម្មជាដើម នោះឆ្ងាយណាស់ ព្រោះមិនធ្លាប់គិត; ប៉ុន្តែធ្លាប់ធ្វើញឹកញាប់ជាងកសិកម្មជាដើមនោះ គឺធ្លាប់ធ្វើរាល់នាទី ហើយញៀនញ៉ាប់ចង់តែធ្វើថែមទៀត ។ មនុស្សម្នាក់ៗ គិតតាំងពីថ្ងៃកើត

ដល់ថ្ងៃស្លាប់ នាំគ្នាធ្វើជនកកម្មនេះគ្រប់នាទីទាំងអស់ វៀរតែដេកលក់ចេញ ។

តើជនកកម្មនោះគឺអ្វី បានជាមនុស្សម្នាក់ៗ ហាក់ដូចជាមិនដឹងថាខ្លួនធ្លាប់បានធ្វើសោះ?

ជនកកម្ម គឺអំពើដែលធ្វើដោយកាយវាចាចិត្ត ជាពូជកំណើតរបស់មនុស្សសត្វ ដែលនាំចិត្តឲ្យចាប់បដិសន្ធិក្នុងកំណើតផ្សេងៗ មានអំណាចឲ្យផលតែក្នុងបដិសន្ធិកាល ចំនួន ៤២ ថ្ងៃប៉ុណ្ណោះ, បន្ទាប់មក កម្មដទៃៗមានឧបត្ថម្ភកកម្មជាដើម ឲ្យផលបន្តៗគ្នា តាមកម្លាំងរៀងខ្លួនដរាបដល់ថ្ងៃស្លាប់ទៅវិញ ទើបជនកកម្មថ្មីនាំទៅកើតទៀត ។

## ជនកកម្មនោះមាន ៤ បែបគឺ:

១ – អំពើអកុសលទាំងឡាយ មានលួចប្លន់ កាប់សម្លាប់ កុហកបោកប្រាស់ ផិតក្បត់ ផឹកជក់គ្រឿងស្រវឹង កេងបំ-បាត់ស៊ីសំណូក និងព្យាបាទប្រមាថមើលងាយលុបគុណជាដើម

ដែលកើតឡើងដោយអំណាច លោភៈ ទោសៈ មោហៈ អំពើបែបនេះ ឲ្យផលជាអហេតុកអកុសលវិបាក ឈ្មោះថា កាមទុគ្គតិបដិសន្ធិជនកកម្ម នាំអ្នកធ្វើឲ្យទៅកើតក្នុងអបាយភូមិ មាននរក ប្រេត តិរច្ឆានជាដើម តាមសកម្មភាពរបស់ខ្លួន ៗ

២– អំពើជាកុសលខ្លះ អកុសលខ្លះ គឺធ្វើបុណ្យទាន រក្សាសីលផង ធ្វើអំពើបាបខ្លះផង ដោយអំណាច លោភៈទោសៈ មោហៈខ្លះ ដោយអំណាចអលោភៈ អទោសៈ អមោហៈខ្លះ, អំពើបែបនេះ ឲ្យផលជាអហេតុកកុសលវិបាកក៏មាន ជាសហេ-តុកកុសលវិបាកក៏មាន ឈ្មោះថា កាមសុគតិបដិសន្ធិជនកកម្ម នាំធ្វើឲ្យកើតជាមនុស្ស ចាប់តាំងពីមនុស្សវិកលវិការឆ្កួតលេលា ថោកទាបបំផុត រាបដល់មនុស្សខ្ពង់ខ្ពស់ និងកើតជាទេវតាក្នុង ឋានសួគ៌ ៦ ជាន់ តាមកម្លាំងកុសលាកុសលកម្មរៀងខ្លួន ៗ

៣– អំពើជាកុសល របស់អ្នកបានសម្រេចរូបជ្ឈានទាំងឡាយ ឈ្មោះថា រូបាវចរបដិសន្ធិជនកកម្ម នាំអ្នកធ្វើឲ្យកើត

ក្នុងរូបភព គឺឋានព្រហ្មមានរូប ។

៤ - អំពើជាកុសលរបស់អ្នកបានសម្រេច អរូបជ្ឈានជាន់ខ្ពស់ឈ្មោះថា អរូបាវចរបដិសន្ធិជនកកម្ម នាំអ្នកធ្វើឲ្យកើតក្នុងអរូបភព គឺឋានព្រហ្មគ្មានរូប ។

ជនកកម្មទាំង ៤ នេះ ទី ១ និងទី ២ មានដើម មនុស្សសព្វគ្រប់រូប ព្យៀនព្យាំមណាស់ចង់តែធ្វើ ទោះបីមានច្បាប់រដ្ឋឃាត់ហាមយ៉ាងណា ក៏នៅតែមានមនុស្សលួចធ្វើរាល់ថ្ងៃ ពាសពេញពិភពលោក ដូចជាការកាប់សម្លាប់ ស៊ីសំណូកលួចប្លន់ កុហកបោកប្រាស់ ក្រោធខឹងប្រទូសចង់ពៀរព្យាបាទ និងស្នេហាផិតក្បត់ជាដើម ។ អំពើបែបនេះហើយ ឈ្មោះថាកម្ម បណ្តាលកើតមកពីមនោធាតុ គឺចិត្តនាំឲ្យធ្វើ ឲ្យចង់តែធ្វើគ្រប់នាទី, ដល់ពេលស្លាប់ អំពើណាដែលមានកម្លាំងជាងគេ អំពើនោះជាជនកកម្ម ជាពូជ ជាពន្ធុ ជាម៉ាក សម្រាប់បង្កើតរូបកាយ ឲ្យកើតឡើងតាមពូជ តាមពន្ធុ តាមម៉ាកនោះ ៗ

ដូចពូជគ្រាប់រុក្ខជាតិដែរ ។

កម្រងរឿងនេះ មាន ១៦រឿង ប៉ុន្តែក្នុងទីនេះ ខ្ញុំយកតែ ផ្នែកសារប្រយោជន៍មកនិយាយត្រួសៗ ត្រូវតាមដំណើររឿងតួបទ តាម តែស្ដាប់ពាល់ប៉ុណ្ណោះ, ឯកម្ម ១១ទៀត មិនបានលើកនិយាយ ទេ កុំឲ្យសៀវភៅនេះកាន់ទំព័រច្រើនពេក ។

ម្យ៉ាងទៀត មានរូបកាយមនុស្សសត្វជាច្រើនដែរ ដែល ប្រហាក់ប្រហែលគ្នា ព្រោះសំគាល់បានថាជាបងប្អូននឹងគ្នានោះ ដោយអំណាចជាតិពូជ និងកម្លាំងដួងចិត្ត នៃមាតាបិតាក្នុង ពេលរួមតម្រេកជាមួយគ្នា ។

ចំណុចនេះ យើងត្រូវគិតមើលរឿងបង្កាត់ពូជសត្វ រហូត ដល់វត្ថុតូចតាចទាំងឡាយ ដូចរុក្ខជាតិធញ្ញជាតិ ដែលអាចប្រែ ក្លាយតាមក្បាលខ្លួននោះ យកមកវែកញែករកសេចក្ដីពិតឲ្យ ឃើញ ។

រឿងបង្កាត់ពូជសត្វ ក៏ដូចជាបង្កាត់ពូជមនុស្សដែរ សុទ្ធ

តែមានញីឈ្មោល មានជាតិពូជ ២ មានកម្លាំងផ្លូវចិត្ត ២ ។

ក្នុងពេលរួមតម្រេកជាមួយគ្នា បើខាងញីមានតម្រេកខ្លាំងជាងដោយកម្លាំងផ្លូវចិត្ត, ឯជាតិពូជគឺឈាមដែរ ក៏មានកម្លាំងច្រើន ក៏មានសុខភាពផងដែរ ហើយចួនជាក្នុងពេលនោះ មានសត្វចុះចាប់បដិសន្ធិផង រូបកាយពណ៌សម្បុរកូន ត្រូវកាត់ទៅខាងញី គឺបើញីមានសម្បុរសហើយធំខ្ពស់ កូនក៏បានសម្បុរសហើយធំខ្ពស់ មានលក្ខណៈទម្រង់ទ្រាយស្រដៀងនឹងញីដែរ គឺខាងណាមានកម្លាំងទាំងពីរខ្លាំងជាង កូនកាត់ទៅខាងនោះច្រើនជាង ព្រោះធម្មជាតិរឹក៏ដោយ ឲ្យតែមានកម្លាំងជាងតែងតែឈ្នះខាងខ្សោយជាដរាប នេះជាសច្ចភាព ។

បើខាងញីមានតម្រេកខ្លាំងដោយកម្លាំងផ្លូវចិត្ត ប៉ុន្តែខាងជាតិពូជ គឺឈាមដំរខ្សោយជាងឈ្មោលនោះ, ពណ៌សម្បុរសាច់ឈាមត្រូវកាត់ទៅខាងឈ្មោល, ឯរូបរាងទម្រង់ទ្រាយកាត់ទៅខាងញី ។ បើមានកម្លាំងទាំងពីរស្មើគ្នា កូនក៏មាន:

រូបភាពទ្រង់ទ្រាយពណ៌សម្បុរស្មើភាគគ្នាដែរ គឺប្រហាក់ប្រហែលទៅតាមចិត្តខ្លះ ល្អិតល្អន់ខ្លះ ។

ម្យ៉ាងវិញទៀត បើគិតពន្យល់រូបតម្រេកនោះ ចិត្តនឹកឃើញរូប បុរសស្ត្រីណា ឬក៏ឃើញរូបថត ឬរូបចម្លាក់ បុរសស្ត្រីណា ឬ ក៏រូបគាមីដែលគេគិតពីរូបតម្រេកវាជួយគ្នានោះ ហើយខាងចិត្តខ្ញុំខាងល្អិតល្អ មានតម្រេកកើតឡើងយ៉ាងខ្លាំង ដោយកម្លាំងស្នូលចិត្ត ដែលចាប់អារម្មណ៍នោះ ៗ មកជាអារម្មណ៍ កូនត្រូវគាត់ទៅតាមរូបារម្មណ៍នោះៗ ក៏មានដែរ ។ ឧទាហរណ៍នេះ ក៏ដូចយ៉ាង ព្រោះពាស់ ៗ ជាបុព្វបុរសខ្លះ បានយកស្បែកគោព្រៃ ឬខ្ពីង ស្បែង ក្បាលគោព្រៃ មកឲ្យគោញីលិទ្ធ ដើម្បីឲ្យគាត់ពូជបានធំៗ ល្អ ។ ល។ រឿងនេះ សូមពិចារណាថែមទៀតចុះ ខ្ញុំគ្រាន់តែនាំមកជាគំនិតប៉ុណ្ណោះ ។

ចំណែកខាងឯធម្មជាតិដែលមានប្រភពជាពូជនោះ គេឧក្ខាយ សបគ្គាបាក្រោយយកម៉្យ៉ាងជាតិពូជស្រាយគាត់តែម្យ៉ាង ដូចត្រូវដំណើរ

និងស្រូវខ្សាយ ពោតសនិងពោតក្រហម ដែលដាំជិតគ្នា ។ ពូជជាតិណា មានកម្លាំងជាងអាចគ្របសង្កត់លើពូជខ្សោយបាន, ដូចស្រូវខ្សាយនិងពោតក្រហមដែលមានជាតិពូជខ្លាំងជាង អាចធ្វើឲ្យស្រូវដំណើបនិងពោតសក្លាយជាស្រូវខ្សាយជាពោតក្រហមតាមខ្លួនបាន, ព្រោះថាកាលធញ្ញជាតិនោះមានផ្កាដើមចេញមក វាមានសំបកសម្រាប់ដាក់គ្រាប់ ដែលនៅក្នុងសំបកនោះមានពូជជាតិសម្រាប់ផ្សំជាមួយលំអងផ្កា បាក់ដូចជាតិញីឈ្មោលដែរ ។ ជាតិដែលនៅក្នុងសំបកក្តី, ក្នុងលំអងផ្កាក្តី ដែលដល់ពេលវេលាហើយ លំអងផ្កាហោះហើរចេញពីផ្កាតាមខ្យល់ រត់ចូលទៅក្នុងសំបកតាមប្រហោងមួយនៅខាងចុង ដែលបានបើកចំហចាំជាស្រេច ដូចជាទ្វារមគ្គមនុស្សសត្វដែរ, កាលណាសំបកបានទទួលលំអងហើយបិទជិតភ្លាម, ឯសំបកដែលមិនបានទទួលលំអងទៅជាស្កកក៏គ្មានគ្រាប់ឡើយ ទោះបីមានគ្រាប់ខ្លះក៏មិនពេញជាគ្រាប់ល្អដែរ ។

ការសរសេររបស់ខ្ញុំមកដល់ត្រង់ចំណុចនេះ សូមលើកយកបញ្ហាពេចទឹកច្បាំងមួយមកនាំមិត្រអ្នកអាន វែកញែករកការពិតទៀត គឺរកដើមកំណើត ភេទញីឈ្មោល ប្រុសស្រី របស់មនុស្សសត្វ ដែលនាំគ្នាឆ្ងល់ថា អ្នកណានាំបង្កើតឲ្យមានញីមានឈ្មោល ? ភេទញីឈ្មោលកើតពីអ្វី ?

## ដើមកំណើតភេទញីឈ្មោល

បញ្ហានេះ តាមគ្រិស្តសាសនាថា ព្រះម្ចាស់សួគ៌បង្កើតឲ្យមាន**អាដាំ**ជាតួឈ្មោល, នាង**អេវ** ជាតួញី ។ល។

ទ្រឹស្តីរបស់សាសនាគ្រិស្តនេះ ធ្វើឲ្យជាតិអឺរ៉ុបស្ទើរតែទាំងអស់ដែលមានអ្នកវិទ្យាសាស្ត្រនៅក្នុងនោះផង និងពួកអាស៊ីខ្លះ ជឿតាមស៊ប់ឥតគិតគូរ ដរាបដល់បញ្ចប់គំនិតក្នុងបទចម្រៀងនិងកំណាព្យថា „ធ្វើម៉េច! នឹងចៀសសេចក្តីស្នេហាបាន បើព្រះម្ចាស់សួគ៌ បង្កើតឲ្យមានញីឈ្មោលមកហើយ „ ។ល។

ដើម្បីរកសេចក្តីពិត ក្នុងរឿងកំណើតភេទញីឈ្មោលនេះ

សូមនឹកទៅដល់អត្ថបទខាងដើមបន្តិចទៀត ដែលនិយាយពីអវិជ្ជា និងសង្ខារ បង្កើតចិត្តវិញ្ញាណ ; ចិត្តវិញ្ញាណ កើតមកពីតិណជាតិ ធញ្ញជាតិ រុក្ខជាតិ , តិណជាតិ ធញ្ញជាតិ រុក្ខជាតិ កើតមកពីធាតុដី ទឹក ភ្លើង ខ្យល់ អាកាស ។ល។ ដូច្នេះ ឃើញថាក្នុងធាតុ ដី ទឹក ភ្លើង ខ្យល់ អាកាសនោះ មានមេធាតុញីឈ្មោលនៅក្នុងនោះដែរ , ប៉ុន្តែមិនទាន់វែកញែកឲ្យដាច់ពីគ្នាបាន ព្រោះមិនទាន់មានឧបាទិន្នករូប គឺរូបដែលមានវិញ្ញាណ , ដូចកាលចលនាធាតុ ដី ទឹក ភ្លើង ខ្យល់ អាកាស ទើបនឹងផ្សំកើតបានជាតិណជាតិ ធញ្ញជាតិ រុក្ខជាតិនៅឡើយ មិនទាន់កើតជាចិត្តវិញ្ញាណពិតប្រាកដនោះ មេធាតុញីឈ្មោលអាស្រ័យនៅក្នុងអនុបាទិន្នករូបជាមួយគ្នា , ដូចដើមស្រូវ ដើមពោត ជាអនុបាទិន្នករូប គឺមេធាតុញីស្ថិតនៅក្នុងសំបកគ្រាប់ មេធាតុឈ្មោល ស្ថិតនៅក្នុងលំអងផ្កានៃដើមតែមួយ ៗ លុះដល់ពេលវេលា មេធាតុញីឈ្មោលឲ្យចុងសំបកគ្រាប់ចា

ឡើង មេធាតុឈ្មោល បណ្ដាលឲ្យលំអងវត់ចូលទៅក្នុងសំបក ហាក់ដូចជាចេះស្នេហាគ្នាដែរ នាំឲ្យកើតជាគ្រាប់ស្រូវគ្រាប់ពោត ឡើង ។ ចួនកាលលំអងផ្កាជាមេធាតុញី ជាតិក្នុងសំបក គ្រាប់ជាមេធាតុឈ្មោល ផ្ទុយគ្នាដូច្នេះក៏មានខ្លះដែរ ។

ក្នុងក្បួនវិទ្យាសាស្ត្រ គេបាននិយាយអំពីធញ្ញជាតិ មាន លំនាំដូចគ្នានេះដែរ ប៉ុន្តែគេមិនបានចាប់អារម្មណ៍ថា នេះហើយ ជាដើមកំណើតនៃភេទញីឈ្មោលឡើយ ព្រោះគេបានជឿតាម ព្រះម្ចាស់សួគ៌ថា កើតពីអាដាំនាងអេវនោះស៊ប់ទៅហើយ ។

លុះដល់អវិជ្ជានិងសង្ខារ គឺធាតុ ដី ទឹក ភ្លើង ខ្យល់ អាកាស និងចលនានៃធាតុទាំងនោះវង្វេងគ្នាកាន់តែចំរើនឡើង ៗ ដរាបដល់កើតជាមនោធាតុពិតប្រាកដ គឺកើតជាចិត្តវិញ្ញាណ ហើយ នាមរូបគឺឧបាទិន្នករូប ក៏កើតមានភ្លាមឡើង , មេធាតុ ញីឈ្មោលក៏បែកគ្នាដាច់ស្រឡះ គឺរូបណាដែលមានមេធាតុញី នៅក្នុងនោះកើតជាសត្វញី យូរៗទៅជាមនុស្សស្រី , រូបណា

ដែលមានមេធាតុឈ្មោលនៅក្នុងនោះ កើតជាសត្វឈ្មោល យូរ ៗ ទៅជាមនុស្សប្រុសទៅ; គ្មានព្រះគ្មានទេវតាណាបង្កើតភេទញីឈ្មោលឡើយ ។

ដើម្បីបញ្ជាក់រឿងនេះឲ្យច្បាស់លាស់, សូមមើលអត្ថបទខាងដើមត្រង់ថាមពលជាបច្ច័យ ៩ យ៉ាង ដែលផ្សំគ្រោងកាយមួយមនោធាតុពីកំណើតមកនោះ និងឃើញថាទី ១ គឺនាមរូប ដែលនៅក្នុងនាមរូបនោះ មានចិត្តនិងចេតសិក៥២ និងរូប ២៨ ដោយសង្ខេប, ក្នុងរូប២៨ នោះ មានឥត្ថីភាវរូប ១ ភាពស្ត្រី ឬភេទញី និងបុមភាវរូប ១ ភាពប្រុស ឬភេទឈ្មោលនៅក្នុងនោះផង ។ សឲ្យឃើញថា ចាប់កើតមាននាមរូបភ្លាម ភេទញីឈ្មោលក៏ចែកដាច់ពីគ្នាភ្លាមដែរ មិនដូចកាលទៅជាអនុបាទិន្នករូប ជាដើមស្រូវ ដើមពោតនោះឡើយ ។

ដូច្នេះ ឃើញការពិតហើយថា ភេទញីឈ្មោល ជាមេធាតុប្រចាំពិភពលោក មានតាំងពេលក្នុងដី ទឹក ភ្លើង ខ្យល់

អាកាស ទើបបណ្ដាលឲ្យវត្ថុធាតុក្នុងលោកនេះមានញីឈ្មោល ដែរ ហើយធាតុទាំងពីរនេះត្រូវប្រស្រ័យគ្នាជាចាំបាច់ទៀតផង ទើបសម្រេចផលប្លែក ៗ បាន, សូម្បីវត្ថុធាតុឥតជីវិតសោះដូច ខ្សែភ្លើងអគ្គិសនី ក៏មានខ្សែញី (Négatif) ខ្សែឈ្មោល (Positif) ដែរ ទើបប៉ះគ្នានេះឆេះភ្លើងបាន ។ ឯពាក្យសំដីអក្សរ សាស្ត្រ ក៏មានញីឈ្មោលដែរ, ដូចពាក្យថា «សាលា» ជាដើមជាពាក្យញី (ឥត្ថីលិង្គ), ពាក្យថា «ជន» ជាដើម ជាពាក្យឈ្មោល (បុំលិង្គ) រហូតដល់ការងាររបស់ជាង ក៏មានញីឈ្មោលដែរ, ដូចជាជាប់គោះ ក្ដីស្នូលបញ្ចូលតភ្ជាប់ គ្នា ក៏ហៅថា ពន្លុញ ដំណាប់ ញីឈ្មោលដែរ ។

ពិភពលោក ដែលសម្បូណ៌ទៅដោយធាតុញីឈ្មោលនេះ ឯងកើយ ទើបសេចក្ដីទុក្ខសោកកើតក៏មាន និងសេចក្ដីស្លាប់ ក៏សម្បូណ៌ដែរ ។

វត្ថុតាងមួយទៀត បញ្ជាក់ឲ្យឃើញទ្រាស់ថា ធាតុញី

ឈ្មោលមាននៅពាសពេញដី ទឹក ភ្លើង ខ្យល់ អាកាស ដូចធាតុដទៃៗទៀតដែរ, សូមពិចារណាមើល ពួកកុកញីមួយបែបដែលតែងមានពងដោយសារសូរផ្គរដើមឆ្នាំ និងពួកទាញី មាន់ញីមួយបែបព័ណ៌សមានផង ដែលគេចញ្ចឹមមិនឲ្យមានឈ្មោលនៅជិត ហើយអាចមានពងបានដែរ ។ល។ តើមកពីអ្វី? គឺមកពីសត្វញីទាំងនោះ ស្បូនវាអាចស្រូបធាតុឈ្មោលពីដី ទឹក ភ្លើង ខ្យល់អាកាសទៅផ្សំនឹងធាតុញីវាបាន ទើបមានពង, ប៉ុន្តែពងនោះភាស់មិនញាស់ជាកូនទេ ព្រោះគ្មានមេជាតិស្ពែរម៉ាតូ-ហ្សូអ៊ីតរបស់ឈ្មោល ។

ទ្រឹស្តីពុទ្ធសាសនាមួយកន្លែង ក្នុងគម្ពីរសមន្តបាសាទិកាបានពន្យល់ថា: សូម្បីគ្មានមេជាតិស្ពែរម៉ាតូហ្សូអ៊ីតរបស់ឈ្មោល ក៏មនុស្សស្រីអាចចាប់បដិសន្ធិបានដែរ, ព្រោះថា ហេតុដែលសត្វចុះចាប់បដិសន្ធិបាននោះ មាន ៧ យ៉ាងគឺ

១- ដោយប៉ះពាល់កាយ (ដូចស្រីខ្លះនិងសត្វពួកខ្លះ),

២-ដោយកាន់សំពត់ប្រខោរកេរ (ដូចកិរិយារបស់ឧទាយី),

៣-ដោយផឹកទឹកកាម (ដូចសិង្គឥសី),

៤-ដោយស្ទាបអង្អែលផ្តិត (ដូចសុវណ្ណសាម),

៥-ដោយឃើញវត្ថុជាទីត្រេក (ដូចស្ត្រីរាំងពួកខ្លះ),

៦-ដោយឮសូរសម្លេង (ដូចកុក មាន់ជាដើម),

៧-ដោយហិតក្លិន (ដូចចៀម ពពែ) ។

ចំណែកខាងមនុស្សសត្វ ដែលចាប់កើតឡើងជាញីជាឈ្មោលតាំងពីបឋមកំណើតមកហើយនោះ មិនមែននៅជាញីជាឈ្មោលរៀងខ្លួនរហូតទៅទេ អាចប្រែភេទពីញីទៅឈ្មោល ពីឈ្មោលមកញីឬទៅឡើយវិញបានដោយអំណាចកម្ម ដែលជាអំពើទុច្ចរិតរបស់ខ្លួន មានអំពើផិតក្បត់លួចប្រពន្ធគេជាដើម ។

អំពើផិតក្បត់នេះ ជាការរំលោភលើភេទញីឈ្មោលដែលមានម្ចាស់ ធ្វើឲ្យម្ចាស់គេកើតទុក្ខក្តៅក្រហាយ មានជម្ងឺរោគាក្នុងផ្លូវចិត្ត ដែលពិបាករកថ្នាំព្យាបាលបាន ។ អ្នកធ្វើអំពើផិត

ក្បត់ភេទបែបនេះ ត្រូវទទួលផលដូចអ្នករងអំពើវិញ, ក្នុងបច្ចុប្បន្ន ត្រូវច្បាប់ផ្តន្ទា ដល់ស្លាប់ទៅត្រូវអំពើខ្លួនផ្តន្ទាខ្លួនឯង គឺអំពើក្បត់ចំពោះភេទញីឈ្មោលនោះ ជាជនកកម្មឲ្យបដិសន្ធិកំណើត, បើប្រុសក្បត់ ត្រូវកើតជាសត្វឈ្មោលត្រូវគេក្រៀវ ផុតពីសត្វកើតជាមនុស្សហើយ ផុតពីហើយកើតជាស្រីអាវ៉ាសែ វិបត្តិស្នេហារងទុក្ខវេទនាយ៉ាងខ្លោចផ្សា, បើស្ត្រីក្បត់ត្រូវកើតជាសត្វញីត្រូវគេក្រៀវ ផុតពីសត្វញី កើតជាមនុស្សហើយ ផុតពីហើយកើតជាស្រីអាវ៉ាសែខូចកេរ្តិ៍ឈ្មោះ អភ័ព្វស្នេហាមិនបានសម្រេចដូចបំណង នាំឲ្យកើតទុក្ខក្តៅក្រហាយ ដូចកាលខ្លួនធ្វើឲ្យអ្នករងអំពើកើតទុក្ខនោះដែរ ។ សូមប្រាប់ថា អ្នកដាំពូជឈើពុលត្រូវផុះជាឈើពុល មានផ្កាផ្លែពុល ។ នេះជាសច្ចភាព ។

ម្យ៉ាងទៀត ក្នុងទ្រឹស្តីពុទ្ធសាសនា ស្ត្រីទាំងឡាយមិនងាយបានកើតជាបុរសឡើយ ទោះបីធ្វើបុណ្យមានប្រាថ្នាយ៉ាងណាក៏ដោយ នៅតែមិនបានកើតជាបុរសដដែល ឧបមា

ដូចទឹកនៅក្នុងទីទាប មិនអាចហូរឡើងទៅទីខ្ពស់បាន ដោយកម្លាំងខ្លួនឡើយ, លុះតែស្ត្រីនោះបានគោរពប្រតិបត្តិស្វាមីរបស់ខ្លួន ជាក់ច្ឆមមិនឲ្យពាល់ចិត្តគ្រប់យ៉ាង ហើយថ្វាយចង្គំសុំស្វាមីកើតជាបុរស បើស្វាមីស្ម័គ្រចិត្តអនុញ្ញាតឲ្យ ទើបកើតជាបុរសបាន ៗ ខាងបុរសវិញ បើចង់កើតជាស្ត្រី កើតបានភ្លាម ដូចជាទឹកស្ថិត នៅក្នុងទីខ្ពស់ អាចហូរចុះទៅទីទាបបានដោយងាយស្រួលឆាប់រហាស់ ៗ

(ចប់ហេតុដែលមនុស្សសត្វមានរូបមិនដូចគ្នា និងកំណើតភេទញីឈ្មោល)

## ហេតុអ្វីមនុស្សធ្វើអំពើអាក្រក់ច្រើនជាងល្អ

ដើម្បីងាយរកសេចក្តីពិត ក្នុងរឿងនេះ សូមពិនិត្យមើលហេតុដើមដែលនាំឲ្យកើតជាមនុស្ស, ដូចបាននិយាយរួចហើយថា ហេតុដើមបំផុតដែលនាំឲ្យកើតចិត្ត កើតមនុស្សនោះ គឺអវិជ្ជា បានដល់ ដី ទឹក ភ្លើង ខ្យល់ អាកាស ដែលមិនដឹងគំនរទុក្ខ

មិនដឹងហេតុឲ្យកើតទុក្ខ និងមិនដឹងការរំលត់ទុក្ខជាដើម ។

ការមិនដឹងបែបនេះ ជាតួនៃលោភៈ ទោសៈ មោហៈ ដែលហៅថា កិលេសតណ្ហា ជាពូជនៃសេចក្តីអាក្រក់ បានជាប់នៅក្នុងចិត្តមនុស្សគ្រប់រូប ។

កិលេសតណ្ហានេះឯង ដែលចេះតែបណ្តាលចិត្ត ឲ្យលោភលន់ចង់តែបាន, ឲ្យប្រទូសព្យាបាទ, ឲ្យក្រោធខឹង, ឲ្យចងគំនុំ, ឲ្យលុបគុណគេ, ឲ្យវាយឫកលើកខ្លួន, ឲ្យច្រណែន ឫស្យា, ឲ្យមានសេចក្តីកំណាញ់, ឲ្យបិទបាំងទោសខ្លួនទុក, ឲ្យមានអំនួតអួតអាង, ឲ្យរឹងត្អឹងចចេសមុខរឹង, ឲ្យប្រណាំងប្រជែងវាសនា, ឲ្យប្រកាន់ខ្លួន, ឲ្យមើលងាយគេ, ឲ្យស្រវឹងវង្វេងភ្លេច និងឲ្យធ្វេសប្រហែស ។

ថាមពលនៃចិត្ត ដែលប្រកបដោយកិលេសតណ្ហានេះឯង បណ្តាលឲ្យមានសកម្មភាពជាក់ស្តែងតាមផ្លូវកាយនិងវាចា គឺឲ្យហ៊ានកាប់សម្លាប់, ឲ្យហ៊ានប្លន់ឆបោកកេងកិបស៊ីសំណូក, ឲ្យ

ហ៊ានស្នេហាខុសច្បាប់ទម្លាប់, ឲ្យហ៊ាននិយាយកុហកភូតភរ, ឲ្យហ៊ាននិយាយញុះញង់, ឲ្យហ៊ាននិយាយចាក់ដោត និងឲ្យហ៊ាននិយាយផ្ដេសផ្ដាសឥតផលប្រយោជន៍ ។

កិលេសតណ្ហាដូចរាប់ឈ្មោះខ្លះៗខាងលើនេះ ជារោគជម្ងឺប្រចាំដួងចិត្តដូចជារោគជម្ងឺគ្រុន ដំបៅ ហ្មង់ របេងជាដើម ដែលជារោគប្រចាំរូបកាយដែរ ។

ក្នុងពិភពលោកនេះ មានអង្គការច្រើនក្រុម ច្រើនក្រសួងណាស់សម្រាប់ការពារប្រឆាំងតែនឹងរោគជម្ងឺទាំងពីរក្រុមនេះឯង, ដូចជាក្រសួងអប់រំជាតិ, ក្រសួងការពារប្រទេស, ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ, ក្រសួងកសិកម្ម, ក្រសួងឧស្សាហកម្ម, ក្រសួងសង្គមកិច្ចនិងការងារ, ក្រសួងប្រៃសណីយ៍ទូរគមនាគមន៍, ក្រសួងសុខាភិបាល, ក្រសួងសាធារណការ និងក្រសួងធម្មការជាដើម ។ ចំពោះរោគជម្ងឺក្នុងរូបកាយ មិនសូវកាចសាហាវធ្ងន់ធ្ងរជាប៉ុន្មានទេ គេបង្កើតតែក្រសួងសុខាភិបាលមួយប៉ុណ្ណោះ

អាចប្រឆាំងការពារព្យាបាលរោគជម្ងឺនោះបាន ។ ឯក្រសួងទាំងឡាយក្រៅពីនេះ សុទ្ធតែជាក្រសួងសម្រាប់ប្រឆាំងការពារព្យាបាលរោគជម្ងឺក្នុងខ្លួនចិត្តទាំងអស់ ព្រោះរោគជម្ងឺក្នុងខ្លួនចិត្តនេះកាចសាហាវឆ្លងរាលដាលខ្លាំងណាស់, បើជនណាម្នាក់កើតរោគណាមួយ មានរោគប្រទូសព្យាបាទជាដើមចំពោះជនណាម្នាក់ហើយ រោគនោះឆ្លងរាលដាលភ្លាមដល់ជនអ្នករងអំពើនោះ ដល់គ្រួសារ ដល់ញាតិមិត្រ ដល់ពូជជាតិសាសន៍របស់ជននោះ បណ្ដាលឲ្យកើតការប្រទូសព្យាបាទតបវិញយ៉ាងសកម្ម ញុំាងមនុស្សក្នុងលោកឲ្យវិនាសអន្តរាយ ខូចសុខភាពខ្លួនចិត្តគ្រប់ៗគ្នាគ្មានសល់ម្នាក់ ។

សូមជ្រាបជាពិសេសថា អ្នកដែលធ្វើអំពើអាក្រក់ទាំងអស់ក្នុងលោកនេះ សុទ្ធតែមនុស្សមានជម្ងឺ គឺរោគកិលេសតណ្ហាបណ្ដាលឲ្យឈឺចាប់ក្នុងខ្លួនចិត្តជានិច្ច ទើបចេះតែធ្វើអំពើអាក្រក់ផ្សេងៗ តាមសមុដ្ឋានរោគ, មានតែមនុស្សអ្នកជាដែលមានសុខ-

ភាពស្ងប់ចិត្តល្អប៉ុណ្ណោះទេ ដែលអាចធ្វើអំពើល្អបានច្រើនជាងអំពើអាក្រក់ ។

អាស្រ័យហេតុដូចពោលមកខាងលើនេះឯង ទើបមនុស្សលោកចូលចិត្តធ្វើអំពើអាក្រក់ច្រើនជាងល្អ ព្រោះសុទ្ធតែជាមនុស្សឈឺ, បើឈឺតិចធ្វើអំពើអាក្រក់តិច ឈឺច្រើនធ្វើអំពើអាក្រក់រឹតតែច្រើន ។

ដើម្បីការពារព្យាបាលរោគជម្ងឺផ្លូវចិត្ត រក្សាចិត្តឲ្យមានសុខ-ភាពល្អ ឲ្យធ្វើអំពើល្អបានច្រើននោះ ព្រះអរហន្តសម្មាសម្ពុទ្ធជាមហាវេជ្ជបណ្ឌិតខាងផ្លូវចិត្ត ព្រះអង្គបានរកឃើញសមុដ្ឋានរោគ រកឃើញឱសថសម្រាប់ព្យាបាលរោគ និងរកឃើញគ្រូពេទ្យអ្នកព្យាបាលរោគនោះ នៅក្នុងខ្លួនចិត្តតែមួយជាមួយគ្នា, ព្រោះអវិជ្ជានិងសង្ខារបង្កើតចិត្តមនុស្សឲ្យមក, ជម្ងឺទៅតាមឯឱសថសំរាប់ព្យាបាលរោគក៏កើតព្រមមកជាមួយគ្នាជាប់នឹងខ្លួនចិត្តដែលជាគ្រូពេទ្យនោះដែរ ។ ឯឱសថនិងគ្រូពេទ្យដទៃដែលមាននៅក្រៅ

ផ្លូវចិត្ត មិនអាចយកមកព្យាបាលដើម្បីផ្លូវចិត្តឲ្យសះជាបានឡើយ បានតែចិត្តរបស់ខ្លួនយកឱសថក្នុងចិត្តខ្លួនព្យាបាលខ្លួនឯង ទើបសះជារោគបាន ។

សូមបញ្ជាក់ថា រូបកាយមនុស្សសត្វដែលរស់នៅក្នុងលោក គឺកកើតនៃធាតុដីទឹកភ្លើងខ្យល់អាកាសសព្វថ្ងៃនេះ កាលបើរូបកាយមានជម្ងឺរោគា ត្រូវតែស្វែងរកឱសថដែលមានក្នុងធាតុនោះៗ មកព្យាបាលទើបបានសះជា, ឯជម្ងឺរោគាផ្លូវចិត្តក៏ត្រូវយកឱសថក្នុងផ្លូវចិត្តមកព្យាបាលដែរ ទើបសះជាបាន ។

ឱសថដែលមានក្នុងផ្លូវចិត្តនិងវិធីព្យាបាលរោគផ្លូវចិត្ត មាន របៀបបច្ចេកទេស ជាឧទាហរណ៍ខ្លះដូចខាងក្រោមនេះ ៖

- រោគលោភលន់ចង់តែបាន រម្ងាប់ដោយឱសថឈ្មោះ សន្តោស ការល្មមគ្រប់គ្រាន់តាមមានតាមបាន ។

- រោគប្រទូស្តព្យាបាទ រម្ងាប់ដោយឱសថឈ្មោះមេត្តា ការប្រណីរាប់រកគ្នា ។

-ភេទក្រោធខឹង រម្ងាប់ដោយធម៌ឈ្មោះអកោធៈ ការមិនក្រេវក្រោធចេះអត់អោន ។

-ភេទចង់គុំ រម្ងាប់ដោយធម៌ឈ្មោះករុណា ការអាណិតអាសូរ ។

-ភេទលុបគុណគេ រម្ងាប់ដោយធម៌ឈ្មោះកតញ្ញូកតវេទិតា ការដឹងគុណតបគុណ ។

-ភេទវាយឫកលើកខ្លួន, ភេទអំនួតអួតអាង, ភេទរឹងត្អឹងចចេសមុខរឹង និងភេទប្រណាំងប្រជែងវាសនា ទាំង ៤ មុខនេះ រម្ងាប់ដោយធម៌តែមួយឈ្មោះអត្តញ្ញុតា ការដឹងប្រមាណខ្លួន គឺដឹងឋានៈសមត្ថភាពរបស់ខ្លួន ។

-ភេទច្រណែនឫស្យា រម្ងាប់ដោយធម៌ឈ្មោះមុទិតា ការរីករាយគាប់ចិត្ត ចំពោះសុខលាភអ្នកដទៃមិនរើសមុខ ។

-ភេទកំណាញ់ រម្ងាប់ដោយធម៌ឈ្មោះចាគទានៈ ការបរិច្ចាគទាន ។

- រោគបិទបាំងទោសខ្លួនទុក  រម្ងាប់ដោយធម៌ឈ្មោះសច្ចៈ ការពិតត្រង់ ។

- រោគប្រកាន់ខ្លួននិងរោគមើលងាយគេ  ទាំងពីរនេះរម្ងាប់ដោយធម៌តែមួយឈ្មោះអបចាយនៈ  ការគោរពកោតក្រែង ។

- រោគស្រវឹងស្រវេងភ្លេច  រម្ងាប់ដោយធម៌ឈ្មោះសតិ ការប្រុងប្រយ័ត្នស្មារតី ។

- រោគធ្វេសប្រហែស  រម្ងាប់ដោយធម៌ឈ្មោះអប្បមាទ ការប្រុងខ្លួនមិនឲ្យភ្លាំងភ្លាត់ ។ ល ។

ត្រង់ចំណុចនេះ មិត្តអ្នកអានទាំងឡាយពិតជាមានសេចក្តីសង្ស័យថា  បើជម្ងឺរោគគឺកិលេសតណ្ហាមាននៅក្នុងចិត្ត, ធម៌សម្រាប់ព្យាបាលបំបាត់ជម្ងឺរោគនោះក៏មាននៅក្នុងចិត្ត  និងគ្រូពេទ្យក៏មាននៅក្នុងចិត្តដែរ  ហេតុអ្វីក៏ចិត្តនៅតែមានជម្ងឺរោគទៀត  បើក្នុងចិត្តនោះសុទ្ធតែធម៌  និងមានគ្រូពេទ្យប្រចាំការទៅហើយ ?

ន័យនេះមិនខុសគ្នាពីជម្ងឺរោគាក្នុងរូបកាយឡើយ, ដូចជារូបកាយរបស់គ្រូពេទ្យ ក្នុងផ្ទះខ្លួនសុទ្ធតែឱសថហើយខ្លួនទៀតក៏ជាគ្រូពេទ្យស្រាប់ ហេតុអ្វីក៏គ្រូពេទ្យនោះនៅតែឈឺស្លាប់ដែរ ។

ដើម្បីរិះរកសេចក្ដីពិតក្នុងរឿងនេះថែមទៀត សូមពិចារណាអំពីសកម្មភាពអចិន្ត្រៃយ៍របស់មនុស្សម្នាក់ៗ តើមានព្រឹត្តិការណ៍យ៉ាងណាខ្លះ ក្នុងដំណើរជីវិតរៀងៗខ្លួន នឹងបានជ្រាបភ្លាមតាមការណ៍ពិតថា:

ផ្នែករូបកាយមនុស្សម្នាក់ៗ មិនមែនសុទ្ធតែមានសុខភាពល្អគ្មានជម្ងឺរោគាទេ ហើយក៏មិនមែនសុទ្ធតែឈឺដែរ, ផ្នែកខាងផ្លូវចិត្តក៏មិនមែនសុទ្ធតែធ្វើអាក្រក់ទាំងអស់ទេ ហើយក៏មិនមែនសុទ្ធតែធ្វើល្អទាំងអស់ដែរ ដូចជាពួកចោរដែលជាភស្តុតាងនៃសេចក្ដីអាក្រក់ ក៏គង់មានពេលខ្លះ វាមានមេត្តាករុណាបរិច្ចាគទានសង្គ្រោះអ្នកដទៃដែរ ប៉ុន្តែវានៅធ្វើចោរដដែល ។ ពួកអ្នកនេសាទជាព្រានប្រមាញ់ប្រមង់ ក៏គេមានមេត្តាករុណាធ្វើ

បុណ្យដាក់ទាន សង្គ្រោះអ្នកក្រីក្រ ជួយស្រោចស្រង់អាយុជីវិតសត្វខ្លះដែរ ប៉ុន្តែគេនៅជាព្រានដដែល ។

ម្យ៉ាងទៀតពួកជនសប្បុរសមិនមែនចោរ មិនមែនអ្នកនេសាទដែលជាភស្តុតាងនៃសេចក្តីល្អនោះ ក៏មានពេលខ្លះចិត្តគេឃោរឃៅ ក្រោធខឹង គុំគួនព្យាបាទ កាប់សម្លាប់ ស៊ីសំណូក លួចប្លន់កេងកិប សាហាវជាងចោរ ជាងអ្នកនេសាទទៅទៀត ។ សូម្បីបព្វជិតអ្នកបួស ដែលបានប្តេជ្ញាដាច់ខាតថាមិនប្រព្រឹត្តអំពើអាក្រក់ឃោរឃៅនោះ ក៏គង់មានបព្វជិតខ្លះហ៊ានលួចប្លន់បោកប្រាស់ រហូតដល់ហ៊ានកេងកិបលួចគរុភណ្ឌទ្រព្យសង្ឃដែរ ។

ឧទាហរណ៍ខាងលើនេះ បញ្ជាក់ឲ្យឃើញច្បាស់ថាចិត្តនិងរូបកាយដែលកើតមកអំពីអវិជ្ជា គឺដីទឹកភ្លើងខ្យល់អាកាសនោះគ្មានការទៀងទាត់ឡើយ ដូចជាដីទឹកភ្លើងខ្យល់អាកាសដែលចេះតែប្រែប្រួលពីក្តៅទៅត្រជាក់ ពីត្រជាក់មកក្តៅ ពីរាំងទៅភ្លៀង ពីភ្លៀងមករាំងជាដើមដូច្នោះដែរ រកទីបំផុតចុងចប់មិន

ឃើញឡើយ ។

ត្រង់ចំណុចនេះហើយដែលនាំឲ្យឆ្ងល់ថា ក្នុងចិត្តមានឱសថមានគ្រូពេទ្យប្រចាំការជានិច្ច ហេតុអ្វីក៏មើលជម្ងឺរោគក្នុងដួងចិត្តខ្លួនមិនកើត? គឺមកពីចិត្តជាគ្រូពេទ្យ មិនស្គាល់នូវការមិនទៀងដែលចេះតែវិលវល់គ្មានចុងបញ្ចប់នោះឯង នាំឲ្យគ្រូពេទ្យខូចសមត្ថភាព វង្វេងទិសទី ខ្សោយកម្លាំងចិត្ត មិនអាចយកឱសថទៅព្យាបាលបំបាត់រោគ ដែលកើតឡើងក្នុងទីចំពោះមុខខ្លួនបាន ។ លុះតែចិត្តស្គាល់ច្បាស់ជាក់ស្តែងនូវការមិនទៀងនោះ ទើបព្យាបាលបំបាត់ជម្ងឺរោគក្នុងដួងចិត្តបាន ។

ការមិនទៀងនោះក្នុងព្រះធម៌ថាអនិច្ចំ ជាចំណុចយ៉ាងសំខាន់ ជាមេរៀនធំបំផុតប្រចាំជីវិតមនុស្សសត្វគ្រប់រូប ដែលមនុស្សលោកទាំងអស់មិនត្រូវស្អប់ខ្ពើម មិនត្រូវខ្លាច ត្រូវតែស្រឡាញ់ហើយយកចិត្តទុកដាក់សិក្សាស្រាវជ្រាវពិសោធ ឲ្យឃើញពិតជាមិនទៀងជាក់ស្តែងផ្ទាល់ខ្លួន កុំគ្រាន់តែសិក្សាឲ្យ

បណ្ណាល័យ LIBRARY BUDDHIST INSTITUTE

ចេះដឹងត្រឹមទ្រឹស្ដីនោះមិនបានការទេ ព្រោះការមិនទៀងនោះជាប្រភពនៃទុក្ខសោកក្នុងវដ្ដសង្សារផង ជាប្រភពនៃសេចក្ដីសុខសន្តិភាពក្នុងលោកនេះ និងក្នុងនិព្វានផង ។

ការស្គាល់អនិច្ចំ គឺការមិនទៀងនោះមិនច្បាស់ ជាហេតុឲ្យមានទុក្ខសោកក្នុងវដ្ដសង្សាររកទីបំផុតគ្មាន, ការស្គាល់អនិច្ចំជាក់ច្បាស់ ជាហេតុឲ្យបានសេចក្ដីសុខសន្តិភាពក្នុងលោកនេះ និងក្នុងព្រះនិព្វាន ។

សូមកុំច្រឡំថា អនិច្ចំ ការមិនទៀងដែលចេះតែកើតចាស់ ឈឺ ស្លាប់ មានក្រ សុខ ទុក្ខ វិនាស ចំរើននេះ ជាអកុសល ជាធម៌ថោកទាបឡើយ គឺជាកុសលធម៌ខ្ពង់ខ្ពស់បំផុត សំរាប់មនុស្សលោក ។ សូម្បីក្នុងព្រះធម៌ដែលព្រះពុទ្ធសំដែងអំពីត្រៃលក្ខណ៍ ក៏ព្រះអង្គចាប់សំដែងអំពីការមិនទៀងដែលហៅថាអនិច្ចំនេះ ទុកជាធម៌ទី១ដែរ ។

សូមពិចារណាមើលក្នុងលោកសព្វថ្ងៃ ដែលចំរើនរុងរឿង

គ្រប់វិស័យទាំងអស់ ក៏មកពីការមិនទៀងនេះឯង រុញច្រានមនុស្សលោកគ្រប់ៗគ្នាឲ្យទំប្រឹងធ្វើការ ប្រឹងសិក្សា ប្រឹងកសាង, ដូចជាខាងវិស័យសុខាភិបាល ដែលចំរើនរហូតដល់បេះកាត់តថ្លើមប្រមាត់ បេះបំបាត់រោគកាចសាហាវ បេះបណ្តុះធ្មេញ បេះកែសក់សឲ្យខ្មៅជាដើមនេះ ក៏មកពីមនុស្សលោកចង់ឲ្យមានសុខភាពទៀងទាត់ជានិច្ច ព្រោះមិនស្គាល់នូវអនិច្ចំនោះឯង ។

ប៉ុន្តែសេចក្ដីសុខចំរើនដែលកើតមានឡើង ព្រោះការប្រឆាំងនឹងការមិនទៀងបែបនេះ ត្រូវធ្លាក់ទៅក្នុងអនិច្ចំការមិនទៀងកាន់តែជ្រៅថែមទៀត បៀសមិនផុតគេចមិនរួច គឺសេចក្ដីសុខចំរើននោះមិនបានយូរប៉ុន្មានទេ នឹងប្រែជាទុក្ខសោកវិនាសអន្តរាយទៅវិញ ព្រោះមនុស្សលោកប្រើមធ្យោបាយខុសចំពោះអនិច្ចំ ទុកអនិច្ចំជាសត្រូវទៅវិញ ។

ក៏ហេតុនេះឯង នាំឲ្យមនុស្សលោករឹតតែមានការមិនទៀងតទៅទៀតរកទីបំផុតគ្មាន ព្រោះការប្រឆាំងនឹងអនិច្ចំ ឈ្មោះថា

ប្រឆាំងនឹងនិច្ចំដែរ , ព្បិតនិច្ចំមាននៅក្នុងអនិច្ចំនោះឯង ។

ចំណែកមធ្យោបាយល្អដែលត្រូវប្រើចំពោះអនិច្ចំ ការមិនទៀងនោះ ត្រូវអនុវត្តដូច្នេះ គឺត្រូវសិក្សាពិសោធមើលឲ្យចេះដឹងជាក់ច្បាស់ពិតប្រាកដនូវទ្រឹស្តីអនិច្ចំ យកអនិច្ចំជាមិត្រ ដោយយកវត្ថុធាតុទាំងអស់ដែលខ្លួនធ្លាប់ស្គាល់ជាមូលដ្ឋាន ជាពិសេសយកមិត្រមនុស្សសត្វដែលនៅជុំវិញខ្លួន និងខ្លួនយើងមកសិក្សាពិចារណាជាបឋមថា រូបកាយរបស់មនុស្សសត្វ ទៀងឬមិនទៀង? យើងមុខជាដឹងតាមទម្លាប់ភ្លាមថាមិនទៀងទេ , កាលពីក្មេងរូបកាយរាងរៅសាច់ ស្បែក សក់ ធ្មេញល្អ ដល់ចាស់ទៅអាក្រក់បាក់រស្តោះគួរយុរយារ ។ល។

កាលបើបានដឹងស៊ើៗ ដោយមធ្យោបាយត្រូវតាមទម្លាប់ដូច្នេះហើយគប្បីរក្សាទុកការដឹងនោះឲ្យស្ថិតនៅជាប់ក្នុងចិត្តជានិច្ច កុំឲ្យភ្លេចបាត់ទៅវិញតាមទម្លាប់ គឺត្រូវឧស្សាហ៍នឹកគិតឲ្យឃើញរាល់ថ្ងៃរាល់ពេលវេលារាល់នាទី បើឲ្យរឹតតែវិសេសទៅទៀត

គ្រឿងរឹករើញកល់ដើមចេញចូល, ដល់យូរទៅនាំទៅការ
ចេះចាំកើតមានពិតប្រាកដមិនប្រែរៀងក្រោយ, ដួងចិត្តដែលជាគ្រូ
ពេទ្យមានឈ្មោះតិរិតប៉ុន អាចព្យាបាលជម្ងឺកេត ដែលកើតមាន
ក្នុងចិត្តបាន ។ ដូចជាពេលចិត្តកើតកោតលោភលន់ឡើងអាច
យកកុសលឈ្មោះសន្តោសទៅរំងាប់បាន ដោយយកកំលាំងដួងចិត្ត
ខ្លួនដែលបានចេះចាំថា វត្ថុដែលបានលោភលន់ចង់បាននោះ
ជាអនិច្ចំមិនទៀង បើបានមកហើយមិនយូរប៉ុន្មានវត្ថុនោះត្រូវសុី
បាយអស់ ឬពុកផុយរលួយវិនាសបាត់បង់ទៅវិញដែរ តាំងឡ
ខូចកេរ្តិ៍ឈ្មោះមានទោសផង ព្រោះការលោភលន់បានមកនោះ
ខុសច្បាប់ទម្លាប់ តាំងខ្លួនអាត្មាអញក៏មិនទៀងត្រូវស្លាប់ក្នុងពេល
ដាច់ឬក៏យូរមិនខាន, វត់ទោះក្តាប់ទៅយកវត្ថុដែលអញកេង
កិបកេងបានស៊ីសល់ឬក៏បានមកនោះទៅផងមិនកើត ជាអកុសលផង
ការ បើបានបកក៏ស្ទូកជាមិនបានដែរ ម៉្យាងទៀតមានទោសកំបាំង
គិតទោសចំពោះសៅហ្មងរបស់ខ្លួនតែម៉្យាង ។ បើសិនជាចេះចិត្ត

បាំងទោសចំហបាន ក៏ចៀសមិនផុតពីទោសកំបាំងដែរ ព្រោះខ្លួនឯងដឹងច្បាស់ជាខ្លួនអញមានទោសប្រហារជីវិត ដោយបានលួចកេងកិបប្លន់ស៊ីសំណូកពីកាលនោះៗ ប្រាកដក្នុងចិត្តខ្លួន ដែលមានខ្លួនជាសាក្សីរបស់ខ្លួនស្រាប់ មិនអាចគិតគូរសូកបុគ្គលណាឲ្យជួយដោះសាបានឡើយ ។

កាលបើមនុស្សលោកមានចិត្តគំនិតជាបញ្ញាវន្តត្រឹមត្រូវ ចេះដឹងស្គាល់នូវទ្រឹស្ដីមិនទៀងបែបនេះហើយ នុសថឈ្មោះសន្ដោសការល្មមគ្រប់គ្រាន់តាមមានតាមបាន ជ្រាបចូលទៅក្នុងដួងចិត្ត បំបាត់នូវរោគលោភលន់បានមួយរំពេច មិនរំភើបញាប់ញ័រចិត្ត ព្រោះឃើញគេមានទ្រព្យយសសក្តិថ្កុំថ្កើងដោយការលោភលន់កេងកិបស៊ីសំណូកនោះឡើយ ត្រឡប់ជាមានចិត្តសង្វេគ សំគាល់អ្នកលោភលន់នោះជាមនុស្សល្ងង់ដូចសត្វមមាចទៅវិញ ។ ឯចិត្តអ្នកដែលមានជាតិថ្នាំសន្ដោសជ្រួតជ្រាបហើយនោះ ជាចិត្តល្អស្អាត មានរបៀបរបបសណ្ដាប់ធ្នាប់ត្រឹមត្រូវចង់

បានចង់មានចង់ធំតែតាមច្បាប់ទម្លាប់ យកសេចក្ដីចេះដឹងទាំងអស់ដែលខ្លួនមានប្រើតែតាមច្បាប់ទម្លាប់ អាចញ៉ាំងសេចក្ដីព្យាយាមរកព្យាយាមធ្វើឲ្យចំរើនឡើងជាអតិបរមា ព្រោះការរកការធ្វើតាមច្បាប់ទម្លាប់ត្រូវប្រើព្យាយាមធំ ទើបបានផលច្រើនសមតាមសេចក្ដីត្រូវការ ថែមទាំងមានចិត្តក្លាហានមិនចេះខ្លាចស្លាប់ទៀត ព្រោះដឹងច្បាស់ថាពិតជាត្រូវដាច់ខាតទៅហើយ ។

ចំណែកអ្នកដែលគ្មានធម៌សន្ដោស ដូចមនុស្សលោកភាគច្រើនសព្វថ្ងៃនេះ ជាមនុស្សទម្រន់ខ្ជិលចង់តែស្រណុកខ្លាចស្លាប់ មានព្យាយាមតិច ហើយមានការលោភលន់ចង់បានច្រើនលើសលប់ មិនអាចប្រើធម៌សន្ដោសកើតឡើយ ទាល់តែប្រើការរំលោភខុសច្បាប់ទម្លាប់ លួចប្លន់កេងកិបស៊ីសំណូក ឬលក់ខ្លួនលក់ជាតិ ទើបបានផលច្រើនដូចបំណង ទំយកចំណេះវិជ្ជាដែលខ្លួនមានទាំងប៉ុន្មានទៅបំរើតែសេចក្ដីលោភប៉ុណ្ណោះ ។ នេះជាសច្ចភាព មិនមែនដូចធ្លាប់យល់ស្មានថា អ្នកដែលមានធម៌

សន្តោសត្រេកអរតែតាមមានតាមបាននោះ ជាមនុស្សខ្ជិលទម្រន់ រុយទំរៃក្ករមិនបិទនោះឡើយ ។

ដូចនិយាយខាងលើនេះ គ្រាន់តែជាឧបាយបណ្តោះអាសន្ន ក្នុងពេលចិត្តមានជម្ងឺរោគា បណ្តាលឡើងម្តងម្កាល ប៉ុណ្ណោះទេ មិនមែនជាឧបាយ បំបាត់ជម្ងឺរោគាគឺកិលេសតណ្ហា ឲ្យសះជាដាច់ជ្រះស្រឡះពីដួងចិត្តបានឡើយ ។

ឯឧបាយសក្តិសិទ្ធិ សម្រាប់បំបាត់ជម្ងឺរោគាដួងចិត្តឲ្យផុតលេចសាបសូន្យ មិនឲ្យកើតមានទៀត គឺបំបាត់អំពើអាក្រក់ទាំងអស់ចេញ ធ្វើអំពើល្អម្យ៉ាងជាប់ជាគរនោះ ត្រូវសិក្សានិងពិសោធយ៉ាងហ្មត់ចត់តាមកម្មវិធីដូចតទៅនេះ៖

១-បដិបត្តិវិធីត្រូវសិក្សាពិសោធតាមរបៀបសីលសមាធិបញ្ញា ។

២-បដិវេធវិធី ត្រូវសិក្សាពិសោធតាមលំដាប់នៃមគ្គផលនិព្វាន ។

ទ្រឹស្តីនៃកម្មវិធីទាំងពីរនេះ មានន័យជ្រាលជ្រៅទូលំទូ-លាយណាស់ ត្រូវសិក្សាពិសោធច្រើនជាតិកំណើតទើបសម្រេច

ដល់កំរិតនៃទ្រឹស្ដីបាន ។ កាលបើបានសម្រេចដល់កំរិតហើយ អាចបំបាត់ចោលនូវការកើតចាស់ឈឺស្លាប់ និងទុក្ខសោកពោកភ័យទាំងអស់បាន មានតែបរមសុខម្យ៉ាងជានិច្ចំទៀងទាត់គ្មានការប្រែត្រឡប់ជានិច្ចំ ជាទុក្ខវិញឡើយ ។

ន័យនេះបញ្ជាក់ឲ្យយើងស្គាល់នូវសច្ចភាពរឹតតែច្បាស់ថែមទៀតថា „បរមសុខជានិច្ចំទៀងទាត់គឺនិព្វាន កើតមកពីការប្រតិបត្តិដល់កំរិតនៃកម្មវិធីទាំងពីរ, ថាមពលនៃចិត្តដែលអាចប្រតិបត្តិឲ្យដល់កំរិតនៃកម្មវិធីទាំងពីរបាន កើតមកពីការស្គាល់ច្បាស់នូវអនិច្ចំការមិនទៀង, អនិច្ចំកើតមកពីអវិជ្ជា ។

ត្រង់ចំណុចនេះសូមមិត្តអ្នកអានជ្រាបដោយទ្វីថែមទៀតថា "និច្ចំឬនិព្វានមាននៅក្នុងអនិច្ចំ ឬអវិជ្ជា បើចង់បានបរមសុខជានិច្ចំឬចង់បាននិព្វាន ត្រូវស្វែងរកក្នុងទ្រឹស្ដីអនិច្ចំអវិជ្ជានេះឯង ទើបបានសម្រេចដូចបំណង ។

( ចប់ហេតុដែលមនុស្សធ្វើអំពើអាក្រក់ច្រើនជាងល្អ )

## ហេតុអ្វីបានជាមនុស្សលោក
## មានសុខទុក្ខមានស្នេហាស្រឡាញ់ស្អប់?

បញ្ហានេះ មិត្រអ្នកអានមុខជាឆ្ងល់ថែមទៀតថា តើសេចក្ដីសុខទុក្ខនិងសេចក្ដីស្នេហាស្រឡាញ់ស្អប់នោះកើតពីណា ? ព្រះអាទិទេពផ្ដល់ឲ្យ ឬធម្មជាតិផ្ដល់ឲ្យ ? ព្រោះមនុស្សលោកទាំងអស់គ្រប់ឋានៈ គ្មាននរណាម្នាក់ប្រាថ្នាចង់បានទុក្ខឡើយ ហេតុអ្វីក៏ចេះតែកើតទុក្ខចៀសវាងមិនផុត ។

ដើម្បីស្រាវជ្រាវហេតុផលពិនិត្យរកដើមកំណើតសុខទុក្ខស្នេហាស្រឡាញ់ស្អប់នោះ សូមលើកយកមនោធាតុមកធ្វើជាមូលដ្ឋានដូចតទៅនេះ

ដូចបាននិយាយរួចទាំងដើមហើយថា មនោធាតុកើតមកពីអវិជ្ជានិងសង្ខារ, ក្នុងមនោធាតុនោះមានថាមពល ៣ គឺៈ មនៈប្រដាប់ស៊ាករេរកអារម្មណ៍១, វិញ្ញាណ ប្រដាប់ដឹងនូវអារម្មណ៍១, ចិត្តៈប្រដាប់គិតសន្សំនូវអារម្មណ៍ ១, និងមានសហជាតប្បច្ច័យ៩

យ៉ាងទៀត ជាប់ទាក់ទងជាមួយនឹងមនោធាតុនោះ គឺនាមរូប តួចិត្តចេតសិករូបកាយ១, អាយតនៈប្រដាប់ស្រូប១, ផស្សៈ ប្រដាប់ទទួលប៉ះ១, វេទនាការសោយអារម្មណ៍១, តណ្ហាការ ប៉ងប្រាថ្នា១, ឧបាទានសេចក្តីប្រកាន់១, ភពទីកំណើត១, ជាតិការកើត១, ជរាមរណៈការទ្រុឌទ្រោមនិងសេចក្តីស្លាប់១ ៗ មនោធាតុនិងសហជាតប្បច្ច័យនេះ មានក្នុងទ្រឹស្តីឈ្មោះបដិច្ច-សមុប្បាទ ៗ

ពេលពិនិត្យមើលក្នុងមនោធាតុនិងសហជាតប្បច្ច័យដូចរាប់ខាងលើនេះ មិនឃើញមានឈ្មោះថាសុខទុក្ខស្នេហាស្រឡាញ់ស្អប់ឡើយ, តើសេចក្តីសុខទុក្ខស្នេហាស្រឡាញ់ស្អប់នោះកប់នៅត្រង់ទីណា ? កើតឡើងបែបម៉េច? សេចក្តីសុខទុក្ខកើតពីអ្វីនិងអ្វី ? សេចក្តីស្នេហាស្រឡាញ់ស្អប់កើតពីអ្វីនិងអ្វី ?

ការដោះស្រាយបញ្ហានេះ ឲ្យបានច្បាស់លាស់កុំឲ្យមានការងឿងឆ្ងល់ ត្រូវដោះស្រាយជាពីរចំណុច គឺដោះស្រាយតាម

លំនាំទ្រឹស្តី១ ដោះស្រាយតាមរបៀបបច្ចេកទេស ១ ។

## ការដោះស្រាយតាមលំនាំទ្រឹស្តី

ក្នុងទ្រឹស្តីបដិច្ចសមុប្បាទ បើចាប់និយាយជាបដិលោម បញ្ច្រាសពីចុងមកដើមវិញឃើញថា: សេចក្តីសោក ការខ្សឹកខ្សួល សេចក្តីទុក្ខ ការតូចចិត្ត និងការតានតឹងចិត្ត កើតមានឡើងព្រោះជរាមរណៈ, ជរាមរណៈកើតមានឡើងព្រោះជាតិ, ជាតិកើតមានឡើងព្រោះភព, ភពកើតមានឡើងព្រោះឧបាទាន, ឧបាទានកើតមានឡើងព្រោះតណ្ហា, តណ្ហាកើតមានឡើងព្រោះវេទនា, វេទនាកើតមានឡើងព្រោះផស្សៈ, ផស្សៈកើតមានឡើងព្រោះអាយតនៈ, អាយតនៈកើតមានឡើងព្រោះនាមរូប, នាមរូបកើតមានឡើងព្រោះវិញ្ញាណ, វិញ្ញាណកើតមានឡើងព្រោះសង្ខារ, សង្ខារកើតមានឡើងព្រោះអវិជ្ជា ។

តាមលំនាំទ្រឹស្តីនេះ យើងរកឃើញកំណើតសេចក្តីទុក្ខជាដើមហើយថា កើតមកពីជរាមរណៈ, ឯជរាមរណៈនេះកើត

ត ៗ ពីអវិជ្ជាមក ។

ចម្លើយទី១ខាងលើនេះ មានមនុស្សជាច្រើនមិនយល់ចូលចិត្តជឿទេ ត្រឡប់ជាមានសេចក្ដីសង្ស័យថែមទៀតថា ១១- ជរាមរណៈ គឺការចាស់ឈឺស្លាប់នោះ ពិតជានាំឲ្យកើតទុក្ខសោកមែនហើយ ព្រោះមនុស្សទាំងអស់ខ្លាចចាស់ឈឺស្លាប់, តើសេចក្ដីទុក្ខសោកដែលកើតមានគ្រប់គ្នាសព្វថ្ងៃ មុនពេលចាស់ឈឺស្លាប់នោះកើតពីអ្វី? ព្រោះកូនក្មេងនិងយុវជនដែលមិនទាន់ចាស់ឈឺស្លាប់ ក៏កើតមានទុក្ខសោកដែរ! ។ ១២- តាមលំនាំទ្រឹស្ដីបដិច្ចសមុប្បាទនេះ ឃើញប្រាប់តែហេតុដែលនាំឲ្យកើតទុក្ខសោក, ឯហេតុដែលនាំឲ្យកើតសេចក្ដីរីករាយសប្បាយសុខស្រួលស្នេហានោះ មិនឃើញមានប្រាប់ផងសោះ ហាក់ដូចជាមនុស្សដែលមានជាតិកើតក្នុងលោកនេះ សុទ្ធតែមានទុក្ខគ្មានសុខឡើយ ។

សេចក្ដីឆ្លើយបែបនេះ ជាការល្អណាស់ បើគ្មានការឆ្ងល់

បែបនេះទេ នាំឲ្យស្លាប់គំនិត មិនអាចត្រិះរិះស្រាវជ្រាវរកសេចក្ដីពិតឃើញឡើយ ។

ឯសេចក្ដីធ្លាក់ក្នុងទី១នោះ មកអំពីមិនយល់ន័យវែងឆ្ងាយរបស់ពាក្យថា ជរាមរណៈ គ្រាន់តែយល់តាមទម្លាប់ថា រូបកាយចាស់ សក់ស្កូវ ធ្មេញបាក់ ស្បែកយុរយារ ភ្នែកងងឹត ត្រចៀកថ្លង់ និងការឈឺចាប់បាត់បង់ជីវិត ឈ្មោះថាជរាមរណៈ ។

ការយល់បែបនេះត្រូវហើយ ប៉ុន្តែនៅមានន័យជ្រៅឆ្ងាយទៅទៀត ដូចជាឧបសគ្គផ្សេងៗដែលនាំឲ្យទន់ខ្សោយកុសល-ចិត្ត ថយចុះសេចក្ដីសុខចំរើនលាភយស រអាក់រអួលស្នេហា ឬក៏នាំឲ្យខូចបាត់បង់ នូវសេចក្ដីសុខចំរើនលាភយសជាដើមនោះ ឈ្មោះថាជរាមរណៈដែរ ព្រោះនាំឲ្យក្រាំក្រាចិត្តគំនិត ឬនាំឲ្យស្លាប់គំនិត នាំឲ្យបាត់បង់ទ្រព្យលាភយស ។ វាស្រ័យហេតុជរាមរណៈមានន័យបែបនេះ ទើបមានភាសិតថា « ត្បៀ

ស្លាប់ខ្លួន កុំឲ្យស្លាប់គំនិត» ។

ការត្រាំត្រាចិត្ត ការថយចុះទ្រព្យសម្បត្តិលាភយស រអាក់រអួលស្នេហា ឬការខូចបង់ទ្រព្យសម្បត្តិ លាភ យស ជាដើមនេះ នាំឲ្យកើតសេចក្តីទុក្ខសោក ស្រណោះអាឡោះអាល័យ ទន្ទឹះទ្រូកខ្លួល, ទើបក្នុងទ្រឹស្តីបដិច្ចសមុប្បាទប្រាប់ថា «សេចក្តីសោកជាដើម កើតមកពីជរាមរណៈ» ។

ចំពោះសេចក្តីឆ្ងល់ត្រង់ទី១២ ដែលថារកមិនឃើញហេតុឲ្យកើតសេចក្តីសុខសប្បាយរីករាយនោះ ព្រោះសេចក្តីសុខសប្បាយរីករាយរបស់មនុស្សប្រុសស្រីសព្វថ្ងៃនេះ មាននៅជាប់ជាមួយនឹងសេចក្តីទុក្ខនោះឯង ជាសាមិសសុខ មានចំនួនតិចតួចស្តួចស្តើងជាងសេចក្តីសុខពេកណាស់ ដូចជាទឹកអំបិលយ៉ាងប្រៃមួយដប ហើយយកស្ករបន្តិចទៅចាក់ក្នុងដបនោះ គឺនឹងឲ្យឈ្មោះថាទឹកស្ករដងមិនកើត ព្រោះវាប្រៃ, ប៉ុន្តែស្ករមាននៅជាប់ជាមួយទឹកអំបិលក្នុងដបនោះដែរ ។

អាស្រ័យហេតុនេះ ទើបគន្ថទ្រឹស្តីបដិច្ចសមុប្បាទ ដែលប្រកបដោយន័យវិសេសខ្ពង់ខ្ពស់នោះ ព្រះអរហន្តសម្ពុទ្ធសំដែងប្រាប់សរុបតែអំពីហេតុដែលកើតទុក្ខ មិនបានប្រាប់ថាមានកើតសុខផងឡើយ លុះតែបំបាត់ចោលនូវជាតិកំណើតក្នុងវដ្តសង្សារបាន ទើបកើតសុខ ។

ដូចនិយាយខាងលើនេះ ជាការដោះស្រាយតាមលំនាំទ្រឹស្តី ឯការដោះស្រាយតាមរបៀបបច្ចេកទេសនោះ គំយកទ្រឹស្តីបដិច្ចសមុប្បាទដែលនេះឯងមកធ្វើជាមូលដ្ឋាន គ្រាន់តែកែរែកញែកប្រៀបធៀបរកប្រភពឫសគល់ ពិនិត្យមើលប្រតិកម្ម ដែលនាំឲ្យកើតសុខទុក្ខស្នេហាស្រឡាញ់ស្អប់ ឲ្យឃើញប្រាកដមួយៗថាកើតចេញពីមូលដ្ឋានណា ដូចតទៅនេះ ៖

## ការដោះស្រាយតាមរបៀបបច្ចេកទេស

ជាបឋមសូមជ្រាបថា គន្ថទ្រឹស្តីបដិច្ចសមុប្បាទដែលមានរាប់ឈ្មោះហេតុបច្ច័យចំនួន១២ ចាប់ពីអវិជ្ជាសង្ខារដល់ជរាមរណៈ

សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈនិងឧបាយាសនោះ មិនមែនជាមគ្គអានមកជា ឬ ជាធម៌អាថ៌កំបាំង យកមកពីនិព្វានជាតសួគ៌ ពីវត្តលោកសង្ឃ ឬ យកមកពីបរលោកស្រុកខ្មោចឡើយ គឺជាទ្រឹស្តីកើតមានប្រចាំរូបកាយមនុស្សក្នុងពិភពលោកនេះឯង ជាកំពូលទ្រឹស្តីមានន័យជ្រាលជ្រៅហួតចត់ខាងការវែកញែកបញ្ហាញនូវសេក្តីពិត គឺសច្ចការៈក្នុងខ្លួនមនុស្សដែលពួកបញ្ញាវ័ន្តក្នុងពិភពលោកដឹងមិនបាន ស្មានមិនត្រូវ រកមិនឃើញ ។ បើនិយាយឲ្យងាយស្តាប់ ជាទ្រឹស្តីប្រាប់ឲ្យដឹងពិតអំពីការកើតឡើងនិងរលត់ទៅវិញ នៃចិត្តវិញ្ញាណរូបកាយ និងសេក្តីសុខទុក្ខស្នេហាស្រឡាញ់ស្អប់ របស់មនុស្សសត្វទាំងឡាយក្នុងពិភពលោកនេះឯង ។

ចំពោះការកើតឡើងនៃចិត្តវិញ្ញាណរូបកាយ របស់មនុស្សសត្វ បាននិយាយខាងដើមរួចហើយ, ក្នុងទីនេះចាប់និយាយអំពីការកើតឡើង នៃសេចក្តីសុខ ទុក្ខ ស្នេហា ស្រឡាញ់ ស្អប់

តទៅទៀត ។

សូមរាយរាប់ឈ្មោះហេតុបច្ច័យក្នុងប្រតីត្យសមុប្បាទទាំង ១២ គឺជាមូលដ្ឋានសិន :

| | |
|---|---|
| ១- អវិជ្ជា | ជាបច្ច័យនៃសង្ខារ |
| ២- សង្ខារ | " វិញ្ញាណ |
| ៣- វិញ្ញាណ | " នាមរូប |
| ៤- នាមរូប | " អាយតនៈ |
| ៥- អាយតនៈ | " ផស្សៈ |
| ៦- ផស្សៈ | " វេទនា |
| ៧- វេទនា | " តណ្ហា |
| ៨- តណ្ហា | " ឧបាទាន |
| ៩- ឧបាទាន | " ភព |
| ១០- ភព | " ជាតិ |
| ១១- ជាតិ | " ជរាមរណៈ |

១៦- ជរាមរណៈ ជាបច្ច័យ នៃសោកបរិទេវទុក្ខ-ទោមនស្សៈនិងឧបាយាសៈ ។

## ការចែកហេតុផលក្នុងកាលទាំង ៣

អវិជ្ជានិងសង្ខារ ជាអតីតហេតុ; វិញ្ញាណ នាមរូប, អាយតនៈ, ផស្សៈ និងវេទនា ជាបច្ចុប្បន្នផល; តណ្ហានិង ឧបាទាន ជាបច្ចុប្បន្នហេតុ; ជាតិ, ជរាមរណៈនិងសោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ ឧបាយាសៈ ជាអនាគតផល ។

សេចក្ដីសុខទុក្ខស្នេហាស្រឡាញ់ស្អប់ ដែលចាប់កើតមានឡើងក្នុងរូបកាយមនុស្សម្នាក់ៗ អាស្រ័យដោយវិញ្ញាណ នាមរូប អាយតនៈ ផស្សៈ និងវេទនា ដែលចាត់ជាបច្ចុប្បន្នផលនេះឯង ។

ឯបឋមហេតុ ដែលចាប់ផ្ដួចផ្ដើមបុិចពន្ធកមុនបំផុតនោះ គឺ អាយតនៈខាងក្នុងនិងអាយតនៈខាងក្រៅ, កាលបើអាយតនៈទាំងពីរនេះប៉ះទង្គិចមានប្រតិកម្មជាមួយគ្នាហើយផស្សៈនិងវេទនា

ក៏កើតឡើងផលិតចេញជាសុខ ឬទុក្ខតាមលក្ខណៈនៃប្រតិកម្ម នោះៗ មានចំនួនប្រហែលគ្នានឹងការប៉ះទង្គិចរវាងឧស្ម័នអុកស៊ី-ហ្សែន និងអ៊ីដ្រូហ្សែន ដែលប្រតិកម្មនៃឧស្ម័នទាំងពីរនេះ បាន ផលិតចេញមកជាឧស្ម័នទឹកដែរ, ដូចមាននិយាយក្នុងទ្រឹស្តី វិទ្យាសាស្ត្រស្រាប់ ។

តើអាយតនៈនោះគឺអ្វី? មានប្រតិកម្មដូចម្តេច?

អាយតនៈគឺប្រដាប់ស្រូបនូវសម្ភារៈនៃអារម្មណ៍មាន ១២៖

| អាយតនៈក្នុងខ្លួនមាន ៦ គឺ: | អាយតនៈក្រៅខ្លួនមាន៦គឺ |
|---|---|
| ១– ភ្នែក | ១–រូប |
| ២– ត្រចៀក | ២– សម្លេង |
| ៣ ច្រមុះ | ៣ - ក្លិន |
| ៤– អណ្តាត | ៤– រស |
| ៥– កាយ | ៥– ផោដ្ឋព្វៈ(១) |

១-ផោដ្ឋព្វៈ=ការផ្ដល់ផ្សប់ផ្សងវិញ្ញាណបានដឹងថា ក្តៅត្រជាក់រឹងទន់ជាដើម ។

៦- មនះ　　　　　　៦- ធម្មៈ(១) ។

# របៀបប្រតិកម្ម

អាយតនៈក្នុង ស្រូបយកអាយតនៈក្រៅតាមនាទីរបស់ខ្លួន យកមកផ្តល់ឲ្យសរសៃវិញ្ញាណ, វិញ្ញាណក៏ចាប់យកអាយតនៈក្រៅជាអារម្មណ៍គឺ:

- ភ្នែក ស្រូបរូបមក, ចក្ខុវិញ្ញាណទទួលរូប កើតជារូបារម្មណ៍,

- ត្រចៀកស្រូបសម្លេងមក, សោតវិញ្ញាណទទួលសម្លេង កើតជាសទ្ទារម្មណ៍,

- ច្រមុះស្រូបក្លិនមក, ឃានវិញ្ញាណទទួលក្លិន កើតជាគន្ធារម្មណ៍,

- អណ្តាតស្រូបរសជាតមក, ជីហ្វាវិញ្ញាណទទួលរសជាត កើតជារសារម្មណ៍,

---

១.ធម្មៈ = អ្វី ៗ ដែលមនៈអាចចាប់យកជាអារម្មណ៍បាន ។

- កាយស្រូបផោដ្ឋព្វៈមក, កាយវិញ្ញាណទទួលផោដ្ឋព្វៈ កើតជាផោដ្ឋព្វារម្មណ៍, ។

- មនះស្រូបធម្មៈមក, មនោវិញ្ញាណទទួលធម្មៈ កើតជាធម្មារម្មណ៍ ។

ទើបផស្សៈ គឺប្រជាប់ប៉ះទង្គិចអារម្មណ៍ទាំងនោះកើតឡើងភ្លាម បើភ្នែកស្រូបរូបមក ចក្ខុវិញ្ញាណទទួលយកជារូបារម្មណ៍ ហើយ ផស្សៈក៏កើតឡើងប៉ះទង្គិចនឹងរូបារម្មណ៍នោះ ទើបវេទនាកើតឡើងបន្ទាប់ផស្សៈនោះទៀត ផលិតចេញជាសុខទុក្ខ ឬស្រឡាញ់ស្អប់តាមចំណុចចិត្ត ។ ផស្សៈបែបនេះ ហៅថា ចក្ខុសម្ផស្ស គឺផស្សៈអាស្រ័យនឹងភ្នែក ។ ឯសោតសម្ផស្ស ឃានសម្ផស្ស ជិវ្ហាសម្ផស្ស, កាយសម្ផស្ស និងមនោសម្ផស្ស នោះ ក៏មានន័យដូចគ្នាដែរ ។

ផស្សៈនេះកើតឡើងឯកឯងមិនបានឡើយ លុះតែប្រកបដោយអង្គ ៣ គឺ: អាយតនៈក្នុង១, អាយតនៈក្រៅ១, និង

វិញ្ញាណ១ បានទាក់ទងគ្នាហើយទើបផស្សៈកើតឡើងបាន ។

ចំពោះតែអាយតនៈនិងផស្សៈទាំងពីរនេះ មិនទាន់ឲ្យកើតជាសុខទុក្ខឬស្នេហាស្រឡាញ់ស្អប់បានឡើយ ព្រោះគ្រាន់តែជាភ្នាក់ងារ ជាធ្នាំទ្វាររបស់ចិត្ត ដូចជាសរសៃរបស់សត្វពីងពាងដែលវាត័ទ្ធពាសឡើងជាសំណាញ់, កាលបើមានសត្វអ្វីៗទៅប៉ះសំណាញ់ ទើបពីងពាងដឹងភ្លាម ស្ទុះទៅរកកន្លែងប៉ះនោះ ។ ឯចិត្តដូចសត្វពីងពាង ។

ធម្មតាចិត្តរបស់មនុស្សលោកបុថុជ្ជន ជាចិត្តសៅហ្មងជាប់ជំពាក់ដោយកិលេសកាមទាំង៦គឺៈរាគៈតម្រេក, លោភៈចណង់, ឥច្ឆាសេក្តីប្រាថ្នា, អសន្តោសៈមិនស្កប់ស្កល់, ឫស្យាច្រណែនប្រច័ណ្ឌ និង អរតិមិនចាប់អារម្មណ៍ចំពោះអំពើល្អ ។

ចិត្តបែបនេះត្រូវការខ្លាំងណាស់ចំពោះវត្ថុកាមគឺរូប, សម្លេងក្លិន, រស និងផោដ្ឋព្វៈ ព្រោះកាមទាំងពីរគឺកិលេសកាមនិងវត្ថុកាម នេះ ជាអញ្ញមញ្ញបច្ច័យ ត្រូវការប្រស្រ័យទាក់ទងគ្នាជា

ចាំបាច់ ។

កាលបើកិលេសកាមបណ្ដាលឡើង ជាហេតុនាំឲ្យមនុស្សប្រុសស្រីស្វែងរកវត្ថុកាម មានបំណងចង់បាននូវរូប សម្លេង ក្លិន រស សម្ផស្ស អំពីវត្ថុមានចិត្តវិញ្ញាណនិងឥតចិត្តវិញ្ញាណ ដូចជាចង់បានរូបបុរសស្ត្រី មាសប្រាក់ពេជ្រ គ្រឿងប្រើប្រាស់ស្លៀកពាក់ ចំណីអាហារ និងបុណ្យស័ក្តិមុខតំណែងធំតូចជាដើម ។

ចិត្តកំពុងតែស្រេកឃ្លានដូច្នេះ ស្រាប់តែអាយតនៈនិងផស្សៈបានទទួលប៉ះអារម្មណ៍ណាមួយតាមភ្នែកឬត្រចៀកជាដើម ដូចជាភ្នែកបានឃើញរូបបុរសស្ត្រី ចិត្តក៏ស្ទុះទៅរករូបារម្មណ៍កាម, បើរូបារម្មណ៍នោះមិនត្រូវចំណុចចិត្ត មិនសមតាមបំណងទេ បណ្ដាលឲ្យកើតទោមនស្សវេទនា អាក់អន់ចិត្តលះបង់អារម្មណ៍នោះចោលទៅ, បើរូបារម្មណ៍នោះត្រូវចំណុចចិត្តសមតាមបំណង បណ្ដាលឲ្យកើតសោមនស្សវេទនា មានតម្រេកត្រេកត្រអាលចង់បានរូបនោះមកជារបស់ខ្លួន បណ្ដាលឲ្យចិត្ត

ប៉ុនប៉ងលួចកាន់អន្ទះសាប្រាស់ប្រាល់ទ្វល់ខ្វាយចំពោះរូបនោះដរាប ដល់ក្ស័យបាយទឹក ដេកមិនលក់ក៏មាន, បើមិនបានដូចបំណងទេ សេចក្តីទុក្ខកើតមានឡើង, បើបានដូចបំណង សេចក្តីសុខក៏កើតមានឡើង, បើវត្ថុផលបានហើយកំពុងតែគាប់ចិត្តសុខស្រួលនោះវិនាសបាត់បង់ទៅវិញ សេចក្តីទុក្ខក៏កើតមានឡើងទៀត បេះតែវិលត្រឡប់ត្រឡិនដូចកង់ត្រាចកង់ជន់ រកទីបប់គ្មាន ។

សូមនាំឧទាហរណ៍មកបញ្ជាក់ដូចតទៅនេះ ៖

## កំណើតនៃសេចក្តីសុខទុក្ខ

## ឧទាហរណ៍

សុជា បានឃើញមិត្ររបស់ខ្លួនពាក់ចិញ្ចៀន ហើយចង់បានដូចមិត្រ, បានខ្ចីចិញ្ចៀនមិត្រមកពាក់លមើល ឃើញថាសមនឹងដៃខ្លួនណាស់ក៏ប្រាប់ម្តាយខ្លួនឲ្យទិញឲ្យ ។

កាលសុជាបានចិញ្ចៀនពាក់ហើយ មានសេចក្តីសប្បាយ

រីករាយសុខកាយសុខចិត្តណាស់ មុខស្រស់ញញឹម, ស្រឡាញ់ចិញ្ចៀននោះយ៉ាងក្រៃលែង ទំថ្នាក់ថ្នមថែរក្សាពាក់ជាប់នឹងដៃ មិនហ៊ានឲ្យអ្នកដទៃប៉ះពាល់ខ្លាចខូចបាត់បង់ ។

ថ្ងៃមួយ សុផា ទៅហែលទឹកលេង ស្រាប់តែជ្រុះចិញ្ចៀននោះបាត់ទៅ, ដល់ត្រឡប់មកផ្ទះវិញ មើលដៃមិនឃើញចិញ្ចៀន ក៏កើតទុក្ខតូចចិត្តមុខក្រៀម ទំរត់ទៅមុជរាវរកក្នុងទឹកមិនឃើញ ចាប់ពីពេលនោះមក សុផាកើតទុក្ខព្រោះរកចិញ្ចៀនមិនឃើញដូចបំណងផង ព្រោះនឹកស្តាយអាលោះអាល័យចំពោះចិញ្ចៀនដែលធ្លាប់ពាក់ផង ។ល។

## ការវែកញែក

ក្នុងពេលដែលសុផា បានឃើញចិញ្ចៀនរបស់មិត្តខ្លួន, អាយតនៈខាងក្នុងគឺភ្នែករបស់សុផា ស្រូបបាននូវអាយតនៈខាងក្រៅ គឺរូបចិញ្ចៀនរបស់មិត្ត, ចក្ខុវិញ្ញាណរបស់សុផា ស្ទុះមកទទួលរូបចិញ្ចៀននោះ កើតជារូបារម្មណ៍, ផស្សៈរបស់សុផា

កើតភ្លាមឡើងទទួលប៉ះនូវរូបារម្មណ៍នោះ កើតជាចក្ខុសម្ផស្ស, ចិត្តរបស់សុជា ដែលប្រកបដោយកិលេសកាម ក៏បណ្ដាលឲ្យសោមនស្សវេទនាកើតឡើង គាប់ចិត្តចំពោះចក្ខុសម្ផស្សនោះ, តណ្ហាចំណង់ប៉ងប្រាថ្នាក៏កើតឡើង នាំឲ្យសុជាចង់បានចិញ្ចៀនដូចមិត្រ ដកចង់ខ្ចីមិត្រមកពាក់លមើល គិតទៅប្រាប់ម្ដាយឲ្យទិញឲ្យ, កាលសុជាបានចិញ្ចៀនដូចបំណងហើយ សោមនស្សវេទនាញុំាងចិត្តសុជាជាថ្មីទៀត សុខចិត្តសុខកាយរីករាយមានទឹកមុខស្រស់ញញឹម, ឧបាទានគឺសេចក្ដីប្រកាន់ថាចិញ្ចៀននោះជារបស់អញក៏កើតឡើង បណ្ដាលឲ្យសុជាយកចិត្តទុកដាក់ថែរក្សាថ្នាក់ថ្នមចិញ្ចៀននោះ មិនឲ្យគេប៉ះពាល់ក្ដាចខូចខាតបាត់បង់ ។

ពេលដែលសុជាត្រឡប់ពីលេងទឹក មើលដៃមិនឃើញចិញ្ចៀននោះ, អាយតនៈក្នុងគឺភ្នែកសុជាស្រូបបាននូវអាយតនៈក្រៅគឺរូបដៃបាត់ចិញ្ចៀន, ចក្ខុវិញ្ញាណរបស់សុជា ស្ទុះមក

ទទួលរូបដែលបាត់ចិញ្ចៀននោះកើតជារូបារម្មណ៍, ផស្សៈរបស់សុផាកើតឡើងភ្លាមទទួលប៉ះនូវរូបារម្មណ៍នោះកើតជាចក្ខុសម្ផស្ស ចិត្តសុផា ដែលកំពុងមានឧបាទានប្រកាន់ហួងហែងចិញ្ចៀនដែលបាត់នោះ បណ្តាលឲ្យកើតជាទោមនស្សវេទនា មានទុក្ខសោកស្តាយស្រណោះអាឡោះអាល័យ ចំពោះចិញ្ចៀនដែលបាត់បង់នោះ បើតណ្ហានិងឧបាទាន ដែលភ្ជាប់ប្រាថ្នាប្រកាន់ចំពោះចិញ្ចៀនបាត់នោះ នៅតែកើតមានក្នុងចិត្តសុផាជានិច្ចនៅឡើយ, សេចក្តីទុក្ខសោកក៏នៅតែមានជានិច្ចដែរ លុះតែតណ្ហាឧបាទានស្ងប់រម្ងាប់ទៅ ទើបសេចក្តីទុក្ខសោកស្ងប់រម្ងាប់ទៅបាន ។

ឯកំណើតនៃសេចក្តីសុខទុក្ខ ចំពោះហេតុដទៃៗទៀត ក៏មានលំនាំដូចខាងលើនេះដែរ ។

## កំណើតនៃសេចក្តីស្នេហាស្រឡាញ់ស្អប់

សេចក្តីស្នេហាស្រឡាញ់ស្អប់ក្នុងទីនេះ សំដៅយកស្នេហារវាងបុរសស្ត្រីក្នុងផ្លូវកាមតណ្ហា, ឯសេចក្តីស្នេហាជាតិគ្រួសារ

ទ្រព្យសម្បត្តិជាដើមនោះ ក៏មានលំនាំប្រហែលគ្នាដែរ គ្រាន់តែមានឥទ្ធិពលខ្សោយជាងប៉ុណ្ណោះ ។

## ឧទាហរណ៍

សុជាត បានឃើញនារីម្នាក់ជាគ្រាដំបូង គ្រាន់តែក្រឡេកមើលតម្នា ដឹងថាជាស្រីក្រមុំក៏ហើយទៅ, ពេលក្រោយសុជាតបានឃើញនារីនោះទៀតដោយអចេតនា ក៏នឹកឃើញថា នារីនេះអញបានឃើញមុនម្តង តើនារីនេះនៅឯណា ក៏តាមសង្កេតមើលនារីដរាបបានដឹងស្គាល់ផ្ទះពិតប្រាកដ ។

ចំណែកនារីវិញ ដោយបានឃើញសុជាតចេះតែតាមមើលនាងៗក៏បានឃើញរូបកាយលក្ខណៈសម្រស់សុជាតច្បាស់ហើយនឹកក្នុងចិត្តថា ប្រហែលគេស្រឡាញ់នាង, នាងក៏ហាក់ដូចជាចូលចិត្តសុជាតដែរ ។

ក្នុងចិត្តអ្នកទាំងពីរចេះតែស្រមៃឃើញរូបគ្នាទៅវិញទៅមកចង់ជួបមើលមុខគ្នាម្តងទៀត. ដល់ពេលបានជួបគ្នា ក៏លួច

សំឡឹងសំឡក់គ្នាដោយដើមភ្នែកកន្ទុយភ្នែក សង្កេតគាប់យកចូរ និមិត្តនិងអនុព្យញ្ជនៈរវាងភេទនិងភេទ, សេចក្ដីស្នេហាក្នាក៏ចាប់កើតឡើង នាំឲ្យឃើញរូបកាយម្នាក់ៗកាន់តែល្អស្អាតឡើងរៀងខ្លួន ហើយចង់ពាក់ទងគ្នាដោយពាក្យសំដីទៀត ។

ចំណែកសុផាតជាបុរស មិនសូវមានសេចក្ដីអៀនខ្មាសដូចនារី ក៏ដាច់ចិត្តសាកសួរពីនេះពីនោះដោយអាការៈធម្មតា ជាការចាប់ផ្ដើមពាក់ទង ។ នារីបដិសេធសំនួរសុផាតមិនកើត ព្រោះនាងចូលចិត្តសុផាតដែរ ក៏ឆ្លើយទាំងអៀនខ្មាសតាមសំនួរ ដោយពាក្យសំដីនិងទឹកមុខមានរសជាតិស្នេហ៍ ធ្វើឲ្យសុផាតមានសង្ឃឹម រឹតតែមានសេចក្ដីស្នេហាខ្លាំងឡើងទៀត ។

ចាប់ពីបានសាកសួរគ្នា បានស្ទាបស្ទង់ចិត្តគ្នាទៅវិញទៅមក បានដឹងខ្លះៗនោះ សេចក្ដីស្នេហាកាន់តែចំរើនឡើងជាងពេលមុនៗ, មួយថ្ងៃៗគេនឹកឃើញគ្នាជាញឹកញាយ នាំឲ្យមានចំណង់ចង់ជួបគ្នាក៏ញយៗដែរ ។ ឯចំណង់ក្នុងក្ដីនរស សម្ផស្ស ក៏

ចាប់កើតឡើងបន្តបន្ទាប់គ្នានាំឲ្យសុផាតនិងនារីកាន់តែស្និទ្ធស្នាល និងគ្នា ហ៊ាននិយាយផ្ដោះផ្ដងគ្នាឥតញញើត ។ ពេលនោះ ស្នេហាកាមទេព គឺល្បែងស្នេហាកាម ក៏បញ្ចេញឥទ្ធិពលកាន់តែខ្លាំងឡើងៗ ជម្រុលឲ្យសុផាតនិងនារីហ៊ានប្ដេជ្ញាសន្យាសម្រេចចិត្តជាមួយគ្នា លះបង់ព្រហ្មចារីជីវិតរូបកាយ ប្រគល់ជូនគ្នាទៅវិញទៅមក ។

ក្នុងពេលដែលសេចក្ដីស្នេហាកំពុងចំរើននេះ កាយ វាចា ចិត្តរបស់សុផាត និងនារីប្រព្រឹត្តទៅតាមចលនាស្នេហាទាំងអស់, កាយ និងចិត្តគេទាំងពីរនាក់ ទំទាក់ក្បាច់តាមសន្ទាក់ស្នេហាឥតខ្ពោះ, ឯវាចាគេ ទោះនិយាយក្ដី ច្រៀងក្ដី សុទ្ធតែមានន័យថា ស្រឡាញ់តែមួយ, ស្រឡាញ់ណាស់, ល្អណាស់ ស្មោះត្រង់ណាស់ ស្ម័គ្រស្លាប់រស់ជាមួយគ្នាអស់មួយជីវិត ។ល។ សូមមិត្តអ្នកអានពិនិត្យស្ដាប់មើលនូវចម្រៀងស្នេហា ដែលធ្លាប់បានឮរាល់ថ្ងៃ គឺគ្មានន័យអ្វីក្រៅពីពាក្យពីរបីម៉ាត់នេះឡើយ ។

បណ្ណាល័យ LIBRARY BUDDHIST INSTITUTE

ជាប្រពៃណីរបស់សេចក្តីស្នេហា កាលបើបើកចំហឲ្យចំរើនដល់កំណត់ហើយ មិនយូរប៉ុន្មាន វិបត្តិស្នេហាក៏កើតឡើងជាបន្ទាន់នោះដែរ ។

សុជាតនិងនារី ដោយរំលោភសេចក្តីស្នេហាឡើងដល់កំរិត នាំឲ្យមានសេចក្តីលោភ, តណ្ហា សេចក្តីប្រាថ្នា, អសន្តោស មិនចេះស្កប់ស្កល់ និងឫស្យា ប្រណែនប្រចណ្ឌក៏កើតមានឡើង នាំឲ្យអស់សេចក្តីទុកចិត្តគ្នា ឃើញគ្នាទៅវិញទៅមក ចេះតែបណ្តាលឲ្យសង្ស័យថាក្បត់ ថាមិនស្មោះត្រង់ ថាប្រែចិត្ត បែកចិត្ត ថាមិនស្រឡាញ់, វិបត្តិស្នេហាក៏ចាប់កើតមានឡើងបែកចិត្ត បែកកាយពីគ្នា ស្អប់ខ្ពើមគ្នា មើលងាយគ្នា ភ្លេចអតីតកាលអស់ ។

ពេលនោះហើយ ដែលសុជាតនិងនារីត្រូវវិបត្តិស្នេហាជិះជាន់យ៉ាងខ្លាំង លះបង់ភាពប្រក្រតីអស់ តានតឹងក្តៅក្រហាយចិត្ត មុខក្រៀមក្រំស្រងូតស្រងាត់ បាយមិនឆ្អែតទឹកមិនត្រេក

ចូលចិត្តមើលទេសភាពស្ងប់ស្ងាត់លង្វែងលង្វោច, វាចាគេគោះ និយាយក្តី ច្រៀងក្តី ក្តុំកោកគន្ល័យថា ភាក់ហើយ លាហើយ ស្ងប់ណាស់ ខ្ទើមណាស់ ព្រាននារី ស្រីភាពី មិនឲ្យជួបទៀតឡើយ លាហេតុអវិសាន ។ល។

សូមមិត្តអ្នកអានពិនិត្យស្តាប់មើល នូវបទច្រៀងវិបត្តិស្នេហា ដែលធ្លាប់បានឮរាល់ថ្ងៃ គឺគ្មានន័យអ្វីក្រៅពីពាក្យប៉ុន្មានម៉ាត់ខាងលើនេះឡើយ ។ មានបុរសស្ត្រីខ្វះដោះស្រាយបញ្ហាវិបត្តិស្នេហានេះមិនរួច ក្លាយទៅជាអ្នកប្រមឹកជាស្រីផ្កាមាស ប្រុសផ្កាប្រាក់ ឬក៏លោតទឹក ចអក លេបថ្នាំសម្លាប់ខ្លួនក៏មាន ។

## ការរំចេកញៀក

ក្នុងពេលសុផាត ឃើញនារីលើកដំបូង អាយតនៈក្នុងគឺភ្នែកសុផាតស្រូបរូបនារី, ចក្ខុវិញ្ញាណកើតឡើង, ផស្សៈការទទួលប៉ះនូវប្រតិកម្មរបស់ភ្នែក រូបនិងចក្ខុវិញ្ញាណនោះ, ឧបេក្ខាវេទនាគឺការសោយអារម្មណ៍ជាកណ្តាល មិនស្រឡាញ់ស្អប់ក៏កើតឡើង

ទើបសុជាតមិនយកចិត្តទុកដាក់ធ្ងន់នៅក្នុងពេលនោះ គ្រាន់តែដឹងថាស្រីក្រមុំប៉ុណ្ណោះ ។

លុះដល់សុជាត ឃើញនារីក្នុងលើកទី ២ អាយតនៈ, វិញ្ញាណនិងផស្សៈ មានលក្ខណៈដូចទី ១ ដែរ ប្លែកតែសោ-មនស្សវេទនាកើតមានឡើង បណ្ដាលឲ្យសុជាត មានការចាប់អារម្មណ៍ចំពោះរូបនារី ដោយអំណាចសុភនិមិត្ត សំគាល់ថាល្អសមរម្យ ដែលជាចំហាយចេញមកពីកិលេសកាមទៅថ្កក់ជាប់នឹងរូបនារី ទើបសុជាតទំស្វះស្វែងតាមរកមើលឲ្យស្គាល់ផ្ទះទីកន្លែងរបស់នារី, ពន្លកស្នេហាក៏ចាប់កើតមានឡើង ។

សូមជ្រាបថា សេចក្ដីស្នេហាចំពោះកាមតណ្ហានេះ បានជាមានឥទ្ធិពលសាហាវជាងការស្នេហាអ្វីៗនោះ ព្រោះមានមោហាកុញ៉ីឈ្មោលស្រូបបន្ថែមផង នាំឲ្យកិលេសកាមឆេះរក្ការ មានប្រតិកម្មយ៉ាងខ្លាំង ។

អាស្រ័យហេតុនេះ ទើបក្នុងពេលដែលនារី បានឃើញ

សុជាតតាមមើល នាំឲ្យនាងចូលចិត្តថា សុជាតស្រឡាញ់នាង ក៏មានចិត្តស្រឡាញ់គេវិញដែរ គឺរាំស្រូបគ្នាចូលគ្នាឯង, រាគៈ តម្រេកត្រេកត្រអាលចំពោះរូបទៅវិញទៅមក ក៏កើតមានឡើង លោភៈចំណង់ចង់ឃើញគ្នា, ឥច្ឆា សេចក្ដីប្រាថ្នាគ្រប់យ៉ាងក៏កើតបន្ថែមឡើង ចង់ស្ដាប់ ចង់ដឹង ចង់ពាក្យសំដីគ្នាទៀត ទើបបណ្ដាលឲ្យសុជាតដាច់ចិត្តសួរទាក់ទងនារីៗ ក៏ឆ្លើយឆ្លងទាក់ទងទៅវិញ ។

ពេលដែលសុជាត និងនារីនិយាយឆ្លើយឆ្លងគ្នា, អាយតនៈ គឺត្រចៀកសុជាតនិងនារី បានស្រូបសម្លេងគ្នាទៅវិញទៅមក សោតវិញ្ញាណកើតឡើង, ផស្សៈការទទួលប៉ះនូវប្រតិកម្មរបស់ត្រចៀក សម្ព័ន្ធនិងវិញ្ញាណនោះ, សោមនស្សវេទនា គឺការសោយអារម្មណ៍ជាទីត្រេកអរស្រឡាញ់គាប់ចិត្តក៏កើតឡើងយ៉ាងខ្លាំង ចង់តែជួបនិយាយគ្នា, ឯសេចក្ដីចំណង់ក្នុងក្លិនរស សម្ផស្ស ក៏កើតមានឡើង នាំឲ្យហ៊ាននិយាយផ្ដោះផ្ដងសួរចិត្តគ្នាទៅវិញ

ទៅមក ។

កាមគុណទាំង ៥ គឺរូប សម្លេង ក្លិន រស និងសម្ផស្ស ក៏បញ្ចេញឥទ្ធិពលយ៉ាងខ្លាំងក្លាគ្រប់ទាំង ៥ នាំឲ្យញៀនញ៉ាមញយ ដក់ចិត្តគំនិត, ឯកិលេសកាមគឺ រាគៈ តម្រេក, លោភៈ លោភ, ឥច្ឆា សេចក្តីប្រាថ្នា ក៏កើតឡើងយ៉ាងខ្លាំង បណ្តាលឲ្យកើតអសន្តោសៈ គ្មានសន្តោសអត់ទ្រាំ, ឫស្យា ប្រណែន ប្រច័ណ្ឌ និងអរតិគ្មានការចាប់អារម្មណ៍ចំពោះសេចក្តីល្អ ក៏កើតមានឡើង នាំឲ្យមានវិបត្តិស្នេហា ។

ក្នុងពេលកើតវិបត្តិស្នេហានោះ អាយតនៈគឺភ្នែកសុដាច និងនារីស្រូបគ្នាទៅវិញទៅមក ចក្ខុវិញ្ញាណកើតឡើង, ផស្សៈ ការទទួលប៉ះ, ទោមនស្សវេទនា ការសោយអារម្មណ៍មិនគាប់ចិត្តក៏កើតឡើងនាំឲ្យស្អប់ ដោយអំណាចអសន្តោសៈ ឫស្យានិងអរតិបណ្តាលឡើង ។ ឯអាយតនៈ ៤ ទៀតគឺ ត្រចៀកប្រមុះ កាយនិងមនៈកាលបើប៉ះទង្គិចគ្នាហើយសុទ្ធតែកើតជាទោមនស្ស

វេទនាទាំងអស់ នាំឲ្យស្អប់ ធុញទ្រាន់ មិនចង់ឮសម្លេង មិនចង់ឃើញ មិនចង់ប៉ះពាល់ កើតជាការគុំគួនសងសឹកព្យាបាទ កាប់សម្លាប់គ្នាទៅវិញទៅមក ឬសម្លាប់ខ្លួនឯង ។ នេះជាលទ្ធផលចុងបំផុតនៃសេចក្ដីស្នេហាចំពោះកាមតណ្ហា ។

## សេចក្ដីបញ្ចប់

សូមជ្រាបជាពិសេសថា សេចក្ដីស្នេហាស្រឡាញ់ស្អប់ចាប់កើតពីអាយតនៈក្នុងក្រៅ មានភ្នែកនិងរូបជាដើម មិនមែនចាប់កើតឡើងពីចិត្ត ស្រេចតែចិត្តនោះឡើយ ។ អាស្រ័យហេតុនេះហើយ ទើបក្នុងលោកនេះត្រូវមានវិន័យ សម្រាប់ប្រដៅខ្លួនតែត្រឹមកាយនិងវាចាពីរមុខប៉ុណ្ណោះ មិនបានប្រដៅដល់ចិត្តផងឡើយ ទោះវិន័យគឺច្បាប់រដ្ឋក៏ដោយ សាសនាក៏ដោយ ព្រោះថារូបកាយដូចជានគរ, ចិត្តដូចព្រះរាជា ជាធំក្នុងនគរនោះ, អាយតនៈ មានភ្នែកជាដើម ដូចពួកសេវកាមាត្យបុចាបុរស ៗ ធម្មតាព្រះរាជាក្នុងនគរមួយ ៗ មិនអាចសម្រេចការផែនដីតែមួយ

ព្រះអង្គឯងបានឡើយ រាំចសម្រេចបានតែតាមពុតហ្នឹយតាមការទូលស្នើរបស់ពួកសេវកាមាត្យ ឬពួកហោរបុរស ព្រោះព្រះរាជា មិនអាចជ្រាបកិច្ចការផែនដីផ្ទាល់ព្រះអង្គឯងទាំងអស់បានឡើយ ។

អាស្រ័យសភាវៈពិតនេះ បើចង់ចៀសវាងសេចក្តីស្នេហាស្រឡាញ់ស្អប់ជាដើមនេះ គប្បីប្រុងប្រយ័ត្នកាយវាចិត្តចាក់ស្និទ្ធស្នាល កុំទាក់ទង កុំចង់មើលឃើញ កុំចង់ស្តាប់ឮ, បើមិនស្និទ្ធស្នាល មិនទាក់ទង មើលមិនឃើញ ស្តាប់មិនឮហើយ សេចក្តីស្នេហាស្រឡាញ់ស្អប់ជាដើមនោះ ក៏កើតមិនបានដែរ ។

## ការដោះស្រាយវិបត្តិស្នេហា

ធម្មតាមនុស្សដែលកើតក្នុងពិភពស្នេហានេះ តែងតែមានការជួបប្រទះវិបត្តិស្នេហាស្ទើរតែគ្រប់គ្នា បើមិនជួបវិបត្តិស្នេហាក្នុងគ្រួសារ ក៏ជួបវិបត្តិស្នេហាក្រៅគ្រួសារដែរ ។

វិបត្តិស្នេហាក្នុងគ្រួសារ រវាងភរិយាស្វាមី ដែលមាតាបិតា

ញាតិមិត្របានរៀបចំតាមប្រពៃណីនោះជាវិបត្តិងាយដោះស្រាយ ព្រោះមានមធ្យោបាយច្រើន ដោយមាតាបិតាញាតិមិត្រជួយដោះស្រាយផង ដោយមានកូនប្រុសស្រីជាចំណងផង អាចញ៉ាំងការតាស់តែងខ្វែងគំនិតវិបត្តិស្នេហានោះ ឲ្យផុតរលត់ទៅឆាប់រហ័សបាន ។

ឯវិបត្តិស្នេហាក្រៅគ្រួសារដោយលួចលាក់រត់ក្រមុំកម្លោះ ឬអ្នកមានគ្រួសារហើយទិលខូចនោះជាវិបត្តិបិទមុខ ច្រើនតែខ្វះមធ្យោបាយដោះស្រាយ ព្រោះអ្នកដទៃមិនដឹងការពិត មិនអាចជួយដោះស្រាយកើតមានតែខ្លួនដោះស្រាយខ្លួនឯងទើបបាន ។

វិបត្តិស្មុគស្មាញនេះដោះស្រាយបាន ដោយការប្រៀបធៀបខ្លួនទៅនឹងវត្ថុធាតុដែលមាននៅជុំវិញខ្លួនយើង ឲ្យឃើញដំណើរប្រព្រឹត្តិទៅនៃវត្ថុធាតុទាំងនោះ និងដំណើរប្រព្រឹត្តិទៅនៃខ្លួនយើងថា តើដូចគ្នាឬផ្សេងគ្នា, បើឃើញដូចគ្នា វិបត្តិនោះឈ្មោះថាបានដោះស្រាយរួចហើយ មិនយូរប៉ុន្មាន សេចក្តីទុក្ខ

ព្រួយយ៉ាងខ្លោចផ្សារនោះ ក៏នឹងរលត់បាត់ទៅផាល់ផាប់ដែរ ។ ព្រោះវត្ថុធាតុទាំងអស់នៅជុំវិញខ្លួនយើង មានដំណើរប្រព្រឹត្តទៅក្នុងផ្លូវតែមួយដូចខ្លួនយើង គឺមុនដំបូងចាប់កកើតឡើង, កើតហើយត្រូវចំរើន, ចំរើនដល់កំណត់ហើយ ត្រូវថយចុះវិញ ។ ដូចព្រះអាទិត្យព្រះចន្ទជាដើម កាលបើរះពីទិសខាងកើតហើយត្រូវចំរើន, ចំរើនដល់កំណត់ហើយ ត្រូវថយចុះលិចបាត់ទៅវិញ ។ ឯសេចក្តីសុខទុក្ខក្តី ស្នេហាក្តី វិបត្តិស្នេហាក្តី តែចំរើនដល់កំរិតហើយ ត្រូវថយចុះដោយស្វ័យប្រវត្តិ បាត់ស្នេហា បាត់វិបត្តិស្នេហា បាត់សុខ បាត់ទុក្ខទៅវិញជាពិតប្រាកដ មិនដែលមានល្បីថា ស្នេហានៅតែស្នេហារហូត វិបត្តិស្នេហានៅតែវិបត្តិរហូត សុខនៅតែសុខរហូត ទុក្ខនៅតែទុក្ខរហូតនោះឡើយ ។ ចំណែកព្រះអាទិត្យព្រះចន្ទវិញ ក៏មិនដែលល្បីថា រះឡើងហើយនៅតែរះរហូត ឬលិចបាត់ទៅវិញនៅតែលិចរហូតនោះដែរ ។

អ្នកដែលមានគំនិតយល់ត្រូវតាមសភាវៈពិតបែបនេះ, កាលបើសុខទុក្ខ ស្នេហា វិបត្តិស្នេហា កើតឡើង អាចអត់ទ្រាំបានមិនបណ្ដោយឲ្យមានសេចក្ដីត្រេកអរ ឬតក់ស្លុតហួសពីដំណើរឡើងចុះរបស់វា គឺអាចប្រើចិត្តឲ្យមានចលនាស្មើគ្នា នឹងដំណើរឡើងចុះនៃសុខទុក្ខស្នេហា វិបត្តិស្នេហានោះបាន ឥតមានគ្រោះថ្នាក់ដល់ជីវិតឡើយ គឺថាបើកើតទុក្ខសោកហើយ អាចបើកដៃឲ្យទុក្ខសោកតាមយថាហេតុ ក្នុងស្មារតីសង្រួមតាមសភាវៈពិតថាតែងដល់កំណត់វានឹងចុះបាត់ទៅឯង ។

ឯអ្នកដែលគ្មានគំនិតយល់ត្រូវតាមសភាវៈពិតនេះ តែងតែខំបង្កើនទុក្ខសោកនោះឲ្យហួសពីសន្ទុះរបស់វា ដរាបដល់ទៅសម្លាប់ខ្លួនឲ្យជាប់រួចទុក្ខសោកនោះទៅវិញ ដែលជាការឆោតល្ងង់ខ្លៅពេកណាស់ ព្រោះសេចក្ដីស្លាប់នោះ ស្លាប់តែត្រឹមរូបកាយដែលឥតចេះទទួលទុក្ខសោកប៉ុណ្ណោះ, ឯចិត្តដែលកំពុងទុក្ខសោកនោះនៅតែទុក្ខសោកដដែល ត្រូវទៅចាប់ជាតិក្នុងកន្លែងទុក្ខសោកកាន់

តែច្រើនថែមទៀត មានចាំនរកប្រេតជាដើម ព្រោះ "គ្រាប់ស្វាយត្រូវតែដុះជាដើមស្វាយ, ចិត្តកំពុងមានទុក្ខសោក ត្រូវតែកើតក្នុងកន្លែងមានទុក្ខសោក" នេះជាសច្ចភាព ។

សូមប្រាប់យ៉ាងខ្លីថា បើនៅស្រុកមនុស្ស ដោះទុក្ខមិនរួចហើយ ដល់ទៅស្រុកខ្មោច រឹតតែដោះមិនរួចទាល់តែសោះ ព្រោះខ្មោចវាអន់ជាងមនុស្ស ។

## ហេតុអ្វី បានជាមនុស្សចេះសើច ចេះយំ

រឿងសើចនិងយំនេះ បើមិនបានជាគិត ហាក់ដូចជាការធម្មតាងាយដោះស្រាយសោះ គ្រាន់តែឆ្លើយថា "បានជាសើច ព្រោះគេសប្បាយ ត្រូវចំណុចចិត្ត នាំឲ្យរីករាយនៅស្ងៀមមិនបាន, បានជាយំ ព្រោះគេកើតទុក្ខ ព្រួយចិត្ត ស្រណោះអាលោះអាល័យ ឬឈឺចាប់កាយខ្លាំងអត់ទ្រាំមិនបាន" ឆ្លើយតែប៉ុណ្ណោះ ក៏ចប់ស្រេចទៅហើយ ។

ប៉ុន្តែបើពិនិត្យស្រាវជ្រាវរកឫសគល់នៃការសើចនិងយំនេះ

ឃើញថាស្មុគស្មាញណាស់ មានន័យជ្រាលជ្រៅ គេមិនសូវចាប់គិត ព្រោះសុទ្ធតែជាបរមត្ថ ហើយជាអរូបីទៀតផង ។

ក្នុងបញ្ហានេះមានចម្ងល់ច្រើនយ៉ាងគឺ ៖

ក-អ្វីដែលនាំឲ្យមនុស្សសើច, នាំឲ្យមនុស្សយំ ?

ខ-ហេតុអ្វីបានជាមនុស្ស គ្រប់ជាតិសាសន៍ ទាំងអស់ក្នុងលោក មានសូរស័ព្ទសើចនិងយំដូចៗគ្នា?

គ-ហេតុអ្វីបានជាការសើចយំនេះ មានចេញទឹកភ្នែកផង? អ្វីដែលនាំឲ្យទឹកភ្នែកហូរចេញមក ?

ឃ-ការសើចនិងយំនេះជាបុណ្យឬជាបាប ?

ដើម្បីសើរើដោះស្រាយរកសេចក្តីពិតក្នុងរឿងនេះ ឲ្យបានច្បាស់លាស់ សូមដោះស្រាយជាពីរបែប គឺដោះស្រាយតាមលំនាំទ្រឹស្តី ១ បែប, តាមរបៀបបច្ចេកទេស ១ បែប ។

## ដោះស្រាយតាមលំនាំទ្រឹស្តី

ក) អ្វីដែលនាំឲ្យមនុស្សសើច, នាំឲ្យមនុស្សយំ ?

មុននឹងដោះស្រាយបញ្ហានេះ សូមជ្រាបអំពីប្រភេទនៃការសើចរបស់មនុស្សលោកចុប្បន្នសព្វថ្ងៃនេះសិន, ការសើចមាន ៦ បែបគឺៈ

១– សើចញញឹម, ពាក្យក្នុងទ្រឹស្តីបរមត្ថថា ( សិតំ );

២– សើចស្ញាញ គឺសើចទើបបបូរមាត់ឃើញធ្មេញ, (ហសិតំ);

៣– សើចលាន់ឮសម្លេង,– (វិហសិតំ );

៤– សើចរលាក់សម្លេងញ័រទាំងក្បាល, (ឧបហសិតំ);

៥– សើចក្អាកក្អាយហូរទឹកភ្នែកបែកញើស,–(អបហសិតំ);

៦– សើចរីកដក់មាត់ញាក់សស់ទាំងខ្លួន,–(អតិហសិតំ) ។

ចលនានៃការសើចទាំង៦ប្រភេទនេះ កើតមកពីអាយតនៈ ផស្សៈ វេទនា ជាទីនាប់ចិត្ត បណ្តាលឲ្យកើតរីករាយក្នុងអំពើល្អមាន ៤ (កុសលចិត្ត ជាសោមនស្សវេទនា ៤ ), បណ្តាលឲ្យចិត្តរីករាយក្នុងអំពើអាក្រក់មាន៤ (អកុសលចិត្ត ជាសោមនស្សវេទនា ៤ ) រួមត្រូវជា ៨, ចិត្តទាំង ៨ នេះហើយ ដែលនាំឲ្យ

មនុស្សសើច ។

## ចិត្តឆាវ៉ខ ៨នោះគឺ

ផែកល្អមាន ៤

១- ចិត្តប្រកបដោយប្រាជ្ញា រីករាយសប្បាយចំពោះអំពើល្អ ដោយខ្លួនឯង ហើយសើចឡើង ។ ចិត្តបែបនេះ ក្នុងទ្រឹស្តី បរមត្ថឈ្មោះ ( សោមនស្សសហគតញ្ញាណសម្បយុត្តអសង្ខារិក) សរសេរអក្សរកាត់ឲ្យងាយចំណាំឈ្មោះចិត្តថា (ស.ញ.ស.អ.)។

ឧទាហរណ៍ ដូចអ្នកជំនាញការម្នាក់គិតឃើញដោយគំនិត ខ្លួនថា ក្នុងស្រុកកូមិខ្វះមន្ទីរពេទ្យ ក៏ចាប់កសាងមន្ទីរពេទ្យឡើង ហើយមានចិត្តរីករាយសើចសប្បាយ ចំពោះអំពើល្អរបស់ខ្លួន នោះ ។

២- ចិត្តប្រកបដោយប្រាជ្ញា រីករាយសប្បាយចំពោះអំពើ ល្អតាមអ្នកដទៃ ហើយសើចឡើង ។ ចិត្តនេះឈ្មោះ (សោ- មនស្សសហគតញ្ញាណសម្បយុត្តសសង្ខារិក) អក្សរកាត់ថាចិត្ត

ឈ្មោះ (ស.ញ.ស.ស.) ។

ឧទាហរណ៍ ដូចអ្នកជំនាញការម្នាក់ដែរ ប៉ុន្តែគ្មានសកម្មភាពផ្ទុះពីគំនិតខ្លួន លុះតែមានគេបបួលឲ្យធ្វើអំពើល្អណាមួយ ក៏ធ្វើតាមគេ ហើយមានសេចក្ដីត្រេកអររីករាយសើចសប្បាយជាមួយគេ ។

៣ – ចិត្តប្រាសចាកប្រាជ្ញា រីករាយសប្បាយចំពោះអំពើល្អដោយខ្លួនឯងហើយសើចឡើង ។ ចិត្តនេះឈ្មោះ (សោមនស្សសហគតញាណវិប្បយុត្តអសង្ខារិក) អក្សរកាត់ថាចិត្តឈ្មោះ (ស.ញ.វ.អ.) ។

ឧទាហរណ៍ ដូចមនុស្សល្ងង់ម្នាក់ មិនចេះច្រើស្ដីសីល គ្រាន់តែសំគាល់ថារក្សាសីលបានបុណ្យប៉ុណ្ណោះ ហើយមានចិត្តរីករាយសើចសប្បាយចំពោះការរក្សាសីល ដែលខ្លួនបានរក្សាហើយ ។

៤ – ចិត្តប្រាសចាកប្រាជ្ញា រីករាយសប្បាយចំពោះអំពើល្អ

តាមអ្នកដទៃហើយសើចឡើង ។ ចិត្តនេះឈ្មោះ (សោមនស្ស សហគតញាណវិប្បយុត្តសសំខារិក ) អក្សរកាត់ថាចិត្តឈ្មោះ (ស.ញ.វ.ស. ) ។

ឧទាហរណ៍ ដូចមនុស្សល្ងង់ម្នាក់មិនចេះធ្វើបុណ្យអ្វីឡើយ លុះមានគេនាំធ្វើក៏ជ្រះថ្លារីករាយសើចសប្បាយ ពេញចិត្តចំពោះការធ្វើបុណ្យនោះ ។

## ផ្នែកអក្សរកាត់ទាន ៤

១- ចិត្តប្រកបដោយការយល់ខុស រីករាយសប្បាយចំពោះអំពើអាក្រក់ដោយខ្លួនឯង ហើយសើចឡើង ។ ចិត្តនេះឈ្មោះ (សោមនស្សសហគតទិដ្ឋិគតសម្បយុត្តអសំខារិក ) អក្សរកាត់ថាចិត្តឈ្មោះ (ស.ទ.ស.អ. ) ។

ឧទាហរណ៍ ដូចមនុស្សមិនជឿបុណ្យបាបម្នាក់ ឃើញទន្សាយមួយរត់កាត់មុខ ក៏សប្បាយរីករាយ សើចហើកញ្ញៀវដេញសម្លាប់ទន្សាយនោះ ។

២-ចិត្តប្រកបដោយការយល់ខុស រីករាយសប្បាយចំពោះអំពើរាក្រក់ តាមអ្នកដទៃ ហើយសើចឡើង ។ ចិត្តនេះឈ្មោះ (សោមនស្សសហគតទិដ្ឋិគតសម្បយុត្តសសំខារិក)អក្សរកាត់ថា ចិត្តឈ្មោះ(ស.ទ.ស.ស.)

ឧទាហរណ៍ ដូចមនុស្សមិនជឿបុណ្យបាបម្នាក់ គេបបួលទៅផឹកសុរា ក៏រីករាយសើចសប្បាយ ស៊ីផឹកតាមគេទៅ ។

៣-ចិត្តប្រាសចាកការយល់ខុស រីករាយសប្បាយចំពោះអំពើអាក្រក់ដោយខ្លួនឯងក៏សើចឡើង ។ ចិត្តនេះឈ្មោះ (សោមនស្សសហគតទិដ្ឋិគតវិប្បយុត្តអសំខារិក) អក្សរកាត់ថាចិត្តឈ្មោះ(ស.ទ.វ.អ.) ។

ឧទាហរណ៍ ដូចបុរសម្នាក់ដឹងបាបបុណ្យដែរ ឃើញគេយកសំណូកមកសូក ក៏សើចញញឹមទទួលយកសំណូកនោះ ។

៤-ចិត្តប្រាសចាកការយល់ខុស រីករាយសប្បាយចំពោះអំពើអាក្រក់តាមអ្នកដទៃ ហើយសើចឡើង ។ ចិត្តនេះឈ្មោះ

(សោមនស្សសហគតទិដ្ឋិគតវិប្បយុត្តសសង្ខារិក) អក្សរកាត់ថា ចិត្តនេះ(ស.ទ.វ.ស.)

ឧទាហរណ៍ ដូចមនុស្សម្នាក់ដឹងថាបាបបុណ្យដែរ មានមិត្ត ដឹកនាំបបួលឲ្យស៊ីសំណូក ឬឃើញគេមានឡាន មានផ្ទះថ្ម មាសពេជ្រ ដោយការស៊ីសំណូក ក៏រីករាយសើចញញឹម ទទួល សំណូកតាមគេទៅ ។

បណ្តាចិត្តទាំង៨នេះ ចិត្តណាមួយកើតឡើងនាំឲ្យមនុស្ស បុថុជ្ជនក្នុងលោកនេះ មានសំណើចខ្លាំងឬតិចតាមសន្ទុះចិត្ត ដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ទាំង៦មានរូបារម្មណ៍ជាដើម ។

ចំណែកព្រះអរិយៈជាសេខបុគ្គល ៧ពួក មានសោតាបន្ន-បុគ្គលជាដើម ដែលមិនទាន់បានជាព្រះខីណាស្រពនោះលោក សើចញញឹមរីករាយដោយចិត្ត ៦ គឺកុសលចិត្តជាសោមនស្សវេទនា៤ និងអកុសលចិត្តជាទិដ្ឋិគតវិប្បយុត្ត ប្រកបដោយសោមនស្សវេទនា២ ។

បណ្ណាល័យ LIBRARY BUDDHIST INSTITUTE

ឯព្រះខីណាស្រពទាំងឡាយ លោកញញឹមប្រិមប្រិយ ដោយកិរិយាចិត្ត៥គឺ សហេតុកកាមាវចរកិរិយាចិត្តប្រកបដោយសោមនស្សវេទនា ៤ និងអហេតុកកិរិយាចិត្ត ១ ។

ចំណែកព្រះសម្ពុទ្ធទាំងឡាយ ព្រះអង្គញញឹមដោយមហាកិរិយាចិត្ត ៤ ។

ខ្ញុំមិនបាននាំចិត្តទាំងនោះមកសរសេរទៀតឡើយ ដើម្បីកុំឲ្យអ្នកអានភាគច្រើន ដែលស្ដាប់ភាសាបរមត្ថមិនបាន មានការធុញទ្រាន់ ។

## អំពីការយំ

យំគឺកិរិយាបញ្ចេញទឹកភ្នែក ព្រមទាំងសូរសព្ទ ព្រោះសេចក្ដីសោកស្ដាយអាល័យ ឬតូចចិត្ត អាក់អន់ចិត្ត ឬក៏ព្រោះឈឺចាប់កាយខ្លាំង ។ យំមានច្រើនយ៉ាងគឺ យំទារ យំរអុក, យំយែក, យំសោក និងយំអណ្ដឺតអណ្ដក ជាដើម (សូមមើលសេចក្ដីពន្យល់ក្នុងវចនានុក្រមខ្មែរ) ។

ការយំទាំងអស់នេះកើតមកពីអាយតនៈ ផស្សៈ វេទនា មិនជាទីគាប់ចិត្ត បណ្ដាលឲ្យទោសចិត្តកើតឡើង មានសេចក្ដីថ្នាំងថ្នាក់អាក់អន់តូចចិត្ត ៗ ទោសចិត្តនេះហើយដែលនាំឲ្យមនុស្សយំ ៗ

## ទោសចិត្តមាន ២ គឺ

១ - ចិត្តប្រកបដោយកំហុស មានការថ្នាំងថ្នាក់អាក់អន់កើតឡើងហើយយំ ៗ ចិត្តបែបនេះ ក្នុងទ្រឹស្ដីបរមត្ថឈ្មោះ (ទោមនស្សសហគតបដិឃសម្បយុត្តអសំខារិក) អក្សរកាត់ថាចិត្តឈ្មោះ (ទ.ប.ស.អ.) ៗ

ឧទាហរណ៍ ដូចកុមារម្នាក់ចង់បាននំស៊ី មាតាបិតាហាមឃាត់មិនឲ្យ, កុមារនោះមានការថ្នាំងថ្នាក់អាក់អន់តូចចិត្ត ទឹងហើយយំ ព្រោះខុសបំណង ៗ

២ - ចិត្តប្រកបដោយកំហុស មានការថ្នាំងថ្នាក់កើតឡើងតាមអ្នកដទៃដឹកនាំហើយយំ ៗ ចិត្តនេះឈ្មោះ (ទោមនស្ស-

សហគតបដិឃសម្បយុត្តលលំទារិក) អក្សរកាត់ថាចិត្តឈ្មោះ (ទ.ប.ស.ស. ) ។

ឧទាហរណ៍ ដូចកុមារម្នាក់ទៅលេងទឹក តាមមិត្តដឹកនាំ ហើយជ្រុះខោបាត់រកមិនឃើញ ក៏មានចិត្តឆាំងឆ្នាក់អាក់អន់ សោកស្តាយហើយយំ ព្រោះរកមិនឃើញដូចបំណង ។

ម្យ៉ាងទៀត ហេតុដែលនាំឲ្យយំនេះ ក្នុងទ្រឹស្តីព្រះសូត្រ មាននិយាយពាក់ព័ន្ធស្តាប់ថា «សេចក្តីសៅហ្មង៨ យ៉ាងគឺ ជម្លោះ, វិវាទ, ការយំខ្សឹកខ្សួល, សេចក្តីសោក, សេចក្តីកំណាញ់, សេចក្តីប្រកាន់, ការមើលងាយ និងការញុះញង់ កើតមកអំពីសភាវៈជាទីស្រឡាញ់ ២ យ៉ាងគឺពួកសត្វនិងពួកសង្ខារ ។

ពួកសត្វ= បានដល់មាតាបិតា បុត្រភរិយា ស្វាមីគោ ក្របី ដំរី សេះជាដើម ដែលជាទីគាប់ចិត្ត ។

ពួកសង្ខារ= បានដល់ រូប សម្លេង ក្លិន រស ផោដ្ឋព្វ ដែលជាទីគាប់ចិត្ត ។

មានន័យថា បើស្រឡាញ់គាប់ចិត្តចំពោះ រូប សម្លេងជាដើមរបស់ពួកសត្វ មានមាតាបិតា បុត្រភរិយា ស្វាមីជាដើមហើយ ផល់ពួកសត្វនោះវិនាសបាត់បង់ ឬប្រែប្រួលទៅ ដោយឧបស័គ្គណាមួយ នាំឲ្យកើតជម្លោះ កើតវិវាទ និងកើតការយំជាដើមៗ

១) ហេតុអ្វីបានជាមនុស្សគ្រប់ជាតិសាសន៍ក្នុងលោក មានការសើចយំដូចគ្នា?

បញ្ហានេះគួរឲ្យឆ្ងល់ដែរ ព្រោះសំដីភាសារបស់មនុស្សគ្រប់ជាតិ សាសន៍ក្នុងលោក បើមិនបានសិក្សាហាត់រៀននិយាយស្តាប់គ្នាមិនបានឡើយ, ចំណែកខាងការសើចនិងយំ អាចស្តាប់គ្នាបានទៅវិញទៅមកគ្រប់ជាតិសាសន៍ មិនបាច់មានវិជ្ជាស្ថានសិក្សាឲ្យចេះស្តាប់ភាសាសើចយំនេះឡើយ កើតមកពីហេតុអ្វី ? គឺមកពីការសើចយំនេះ ជាភាសាធម្មជាតិ កើតមកពីសរសៃវិញ្ញាណ ដែលផ្សាយចេញពីប្រភពចិត្ត, ឯមនុស្សគ្រប់ជាតិសាសន៍ក្នុងលោកនេះសុទ្ធតែមានចិត្តជាការចាំបាច់ដូចគ្នា, ចិត្ត

មនុស្សម្នាក់ៗតែមួយទេ ប៉ុន្តែមានឈ្មោះដល់ទៅ ១២១, ក្នុងឈ្មោះចិត្តទាំង ១២១ នេះ មានឈ្មោះចិត្ត ១០ ដែលនាំឲ្យមនុស្សសើចឬយំ តាមថាមពលនៃអាយតនៈ ផស្សៈ វេទនា នាំមកផ្ដល់ឲ្យចិត្ត ទើបចិត្តបញ្ចេញចលនាសើចយំតិចច្រើន តាមសរសៃវិញ្ញាណ ឲ្យឃើញច្បាស់ដោយផ្លូវកាយ ។

ឈ្មោះចិត្ត១០ដែលនាំឲ្យសើចយំនេះបានរាប់និងអធិប្បាយខ្លីៗខាងដើមរួចហើយ សូមរាប់ឈ្មោះតាមអក្សរកាត់ម្ដងទៀតៗ

## ឈ្មោះចិត្ត ១០ នោះគឺ

| | | | | | |
|---|---|---|---|---|---|
| ១– | ចិត្តឈ្មោះ | ស.ញ.ស.អ., | ៦– | ចិត្តឈ្មោះ | ស.វ.ស.ស, |
| ២– | " | ស.ញ.ស.ស., | ៧– | " | ស.វ.វ.អ., |
| ៣– | " | ស.ញ.វ.អ., | ៨– | " | ស.វ.វ.ស., |
| ៤– | " | ស.ញ.វ.ស.; | ៩– | " | ឧ.ប.ស.អ., |
| ៥– | " | ស.វ.ស.អ., | ១០– | " | ឧ.ប.ស.ស.។ |

ឈ្មោះចិត្តទាំង ១០ នេះមានតាំងពីមនុស្សនៅក្នុងផ្ទៃមាតា

ម្ល៉េះ អាស្រ័យហេតុនេះទើបមនុស្សប្រសូតភ្លាមចេះយំភ្លាម ។

ត្រង់ចំណុចនេះគួរឲ្យឆ្ងល់ថែមទៀតថា ចិត្តទាំង ១០ ឈ្មោះនេះ មានក្នុងខ្លួនមនុស្ស តាំងពីនៅក្នុងផ្ទៃមាតាម្ល៉េះ, ចិត្តនាំឲ្យសើចមានដល់ទៅ ៨ ឈ្មោះ, ឯចិត្តនាំឲ្យយំមានតែ ២ ឈ្មោះទេ, ហេតុអ្វីពេលមនុស្សប្រសូតមកភ្លាម មិនដែលឮសើចសោះ គេឮតែយំទាំងអស់គ្នាក្នុងពិភពលោកនេះ ?

បញ្ហានេះជាសាមញ្ញងាយដោះស្រាយទេ ព្រោះពេលប្រសូតនោះ ទារកក្នុងផ្ទៃមាតាកំពុងរងទុក្ខវេទនា យ៉ាងខ្លាំងក្លាបំផុត ដែលហៅថាគព្ភិជាយនមូលកទុក្ខ, ធម្មតាមនុស្សកំពុងមានទុក្ខក៏មិនអាចសើចបានឡើយ ។ ពេលកំពុងរងទុក្ខនោះមិនមែនជាឱកាសរបស់សោមនស្សចិត្តទាំង ៨ ទេគឺជាឱកាសរបស់ទោសចិត្ត ២ ទើបមនុស្សប្រសូតមកភ្លាម ស្រែកយំភ្លាម, លុះកាលទារកខ្វះរងទុក្ខដល់សន្លប់បាត់ស្មារតី រកតែស្រែកយំមិនទាំងកើតទៀតផង ។

ក) ហេតុអ្វីបានជាការយំនិងសើចនេះ មានចេញទឹកភ្នែក? អ្វីដែលនាំឲ្យទឹកភ្នែកហូរចេញមក ?

ការចេញទឹកភ្នែក បណ្ដាលមកពីចិត្តមានចលនាខ្លាំង ដែលហៅថារំភើបចិត្តខ្លាំង ឬតក់ស្លុតខ្លាំង ។ កាលបើចិត្តមានចលនាខ្លាំងដូច្នេះហើយ បេះដូងក៏ដើរខ្លាំងដែរ ការបញ្ចេញបញ្ចូលឈាមរបស់បេះដូងក៏ញាប់ដែរ បណ្ដាលឲ្យបេះដូងកំរើកខុសប្រក្រតី ។ ក្នុងពេលនោះ បើយើងដាក់ត្រចៀកចំទ្រូង ហើយស្ដាប់ នឹងឮសូរបេះដូងកំរើកញាប់ៗយ៉ាងញឹកញាប់, ឈាមដែលបេះដូងបញ្ចេញបញ្ចូលយ៉ាងញឹកញាប់នោះ ផ្សព្វផ្សាយយ៉ាងខ្លាំង ទៅគ្រប់សរសៃឈាមទាំងអស់ក្នុងរូបកាយ នាំឲ្យភ្នែកប្រមុះឡើងក្រហម, ឯសរសៃចក្ខុវិញ្ញាណក៏កំរើកខ្លាំង ប៉ះដល់ថង់ទឹកភ្នែក គឺអស្សុប្រភព (Glande lacrymale) បណ្ដាលឲ្យទឹកភ្នែកហូរចេញមកក្រៅ តាមរន្ធភ្នែកនិងរន្ធប្រមុះ នឹងបណ្ដាលឲ្យទឹកញើសហូរចេញពីរូបកាយផងក៏មាន ។

ឃ) ការសើចនិងយំនេះ ជាបុណ្យឬជាបាប ?

ការសើច ចាត់ជាបុណ្យផង ជាបាបផង ព្រោះផ្នែកកុសលចិត្តក៏នាំឲ្យសើច ផ្នែកអកុសលចិត្តក៏នាំឲ្យសើចដែរ ៗ ឯការយំជាបាបសុទ្ធ ព្រោះកើតមកពីទោសចិត្ត ជាអកុសលតែម្យ៉ាង ។

អាស្រ័យការយំ ជាបាបអកុសលនេះ ទើបសប្បុរសជនទាំងឡាយ មានពុទ្ធមាមកជនជាដើម មិននិយមយកការយំជាមង្គលសួស្ដីឡើយ ។

ប៉ុន្តែក្នុងលោកនេះ មានអ្នកប្រទេសជាច្រើន ដូចជនជាតិចិនយួនជាដើម គេនិយមយកការយំនេះ ជាមង្គលសិរីសួស្ដីទៅវិញ ។

ឧទាហរណ៍ ជនជាតិចិនយួនខ្លះ៖ ពេលឪពុកម្ដាយស្លាប់ គេយំខ្លួញក្នុងមួយថ្ងៃឲ្យបានពីរបីដង គឺពេលសែនទឹកតែ ពេលសែនបាយព្រឹកល្ងាចគេនាំជនក្នុងគ្រួសារទៅអង្គុយជិតសពហើយរំរែស្រែកខ្លួញយ៉ាងខ្លាំងគួរឲ្យព្រឺក្បាលខ្លាច និងពេលហែសព

ទៅបញ្ចុះ បើគេមិនសូវប៉ុនយំ គេជួលអ្នកប៉ុនយំ ឲ្យយំជូនដំណើរសពផង ។ គេយល់ថាធ្វើយ៉ាងនេះជាមង្គល ឈ្មោះថាដឹងគុណ តបគុណ សងគុណឪពុកម្ដាយគេ ។ ចំណែកភៀវចិនយួន ដែលមានជំនឿដូចគ្នា គេនាំគ្នាអួតសរសើរថាកូនចៅគ្រួសារនេះដឹងគុណ ស្រឡាញ់ឪពុកម្ដាយណាស់ ចេះយំខ្លួញគួរឲ្យកោតសរសើរ ។

មានចិនមួយពួកទៀត ពេលរៀបមង្គលការ គេឲ្យកូនក្រមុំទំយំខ្លួញបោកខ្លួនប្រាណយ៉ាងខ្លាំងចំនួនបីថ្ងៃ មុនពេលកូនកម្លោះមកដឹកនាំយកទៅ ការដែលកូនក្រមុំចិនយំខ្លួញនេះ គេថាមិនមែនយំចង់បានប្ដីទេ គឺយំខ្លួញតបស្នងសងគុណមាតាបិតាដែលបានចិញ្ចឹមមក ព្រោះខ្លួនជិតព្រាត់ប្រាសចោលឪពុកម្ដាយទៅតាមប្ដីហើយ ។ ដល់ពេលកូនក្រមុំរៀបចេញពីផ្ទះទៅតាមប្ដី គេយកសំពត់រុំមុខកូនក្រមុំជិត ឲ្យជិះអៀវលើខ្នងស្រីម្នាក់ដែលគេរាប់អាន នាំចេញពីបន្ទប់យកទៅប្រគល់ឲ្យកូនកម្លោះ

ត្រឹមមាត់ទ្វារ, ពេលនោះគេនាំគ្នាទួញទ្រហឹងពេញផ្ទះ បាចអង្ករទៅលើកូនក្រមុំហើយអុចផាវ ដូចជាគេបាចអង្ករបណ្តេញពួកខ្មោចដូច្នោះដែរ ។ នេះជាលទ្ធិយំនិយមមួយក្នុងលោក ។

## ការដោះស្រាយតាមរបៀបបរប្រទេស

ការដោះស្រាយនេះ គ្រាន់តែបញ្ជាក់ថែមលើការដោះស្រាយតាមលំនាំទ្រឹស្តី ដោយមានការវែកញែក ត្រង់ចំណុចសំខាន់ៗឲ្យឃើញច្បាស់តាមទស្សនៈបច្ចុប្បន្ន ។

សូមបញ្ជាក់ថា ការកើតនិស្ស័យនេះ មិនមែនចាប់កើតពីចិត្តទាំង ១០ នោះតែម្តងទេ, មុនបំផុត គឺអាយតនៈក្នុងក្រៅស្រូបគ្នា បណ្តាលឲ្យមានប្រតិកម្ម ប៉ះទង្គិចគ្នា កើតផស្សៈវេទនាឡើង, ត្រង់វេទនានេះហើយ ជាសកម្មភាពរបស់ចិត្ត គឺរូប សម្លេង ក្លិន រស សម្ផស្ស ធម្ម ដែលអាយតនៈស្រូបបានមកប៉ះទង្គិចគ្នា នឹងភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និងមនៈកើតជាផស្សៈ, ចិត្តបានដំណឹងព្រោះការប៉ះទង្គិចនោះទើបទទួល

ពិនិត្យផលិតចេញជា សើចប្អុយ ឬយ៉ាងណាៗទៅ ដែលស្លាប់ ហៅថាសោយនូវអារម្មណ៍ គឺវេទនានេះឯង ។

អាយតនៈប្រៀបដូចប្រដាប់អាកាស របស់វិទ្យុទូរទស្សន៍, ផស្សៈ វេទនាប្រៀបដូចតួវិទ្យុទូរទស្សន៍, កាលប្រដាប់អាកាស នោះស្រូបរូបសំឡេងមកប៉ះនឹងខ្សែហើយ វិទ្យុទូរទស្សន៍ទទួល រូបសម្លេងពីខ្សែនោះ ផលិតចេញមក មានលក្ខណៈផ្សេងៗតាម លំនាំដែលប្រដាប់អាកាសស្រូបបានមកនោះឯង ។

ម្យ៉ាងទៀត អាយតនៈ ផស្សៈ វេទនានេះ ជាឈ្មោះ សកម្មភាពរបស់សរសៃវិញ្ញាណ ដែលមានចិត្តជាអ្នកប្រតិបត្តិ ការ, ព្រោះថាក្នុងរូបកាយមនុស្សយើងនេះ មានសរសៃនា ឡិកាចំនួន ៩០០ គឺសរសៃធំចំនួន ៦០ ពីខ្នងដល់ជើងខាងឆ្វេង ៥ ស្តាំ ៥ ពីខ្នងខាងឆ្វេង ៥ ស្តាំ ៥, ពីដៃឆ្វេង ១០ ស្តាំ ១០ ត្រូវ ជាសរសៃធំ ៦០ រួមប្រជុំនៅត្រង់ក ។ ឯសរសៃតូចៗចំនួន ៨៤០ ទៀត បែកចេញពីសរសៃធំនោះ រុំព័ទ្ធពាសពេញក្នុង

ខ្លួនតាំងមូល សម្រាប់នាំឈាម ផ្សព្វផ្សាយក្នុងរូបកាយ ។ ឯសរសៃវិញ្ញាណតាំងអស់មាន ៩ កោដិ សម្រាប់ដឹងសុខទុក្ខ ក្តៅត្រជាក់ស្រេកឃ្លានជាដើម ។

## ភាពច្បាស់នៃសរសៃវិញ្ញាណនោះប្រើងមានសណ្ឋាន បែបនេះ



ក្នុងទ្រឹស្តីវិទ្យាសាស្ត្រ គេបានពិនិត្យឃើញភាពសរសៃវិញ្ញាណ ដែលស្ថិតនៅទាក់ផងក្នុងរូបកាយ ភាគសំខាន់ជាងគេសម្រាប់ដឹងក្តៅត្រជាក់ ឈឺស្រួល ស្រេកឃ្លាន ភ័យអរ និយាយស្តី យំសើច ដេក អង្គុយ ឈរ ដើរជាដើម គឺសរសៃជាប្រភពនៃចលនារូបកាយរបស់មនុស្សគ្រប់បែបណា នោះដូចរូបភាពខាងមុខនេះ ។


๑
๒
๓
๔
๕
๖
๗
๘

# ន័យរបស់រូបតាមលំដាប់លេខរៀង

១- ខួរក្បាល Cerveau ។ ២- ខួរឆ្អឹងកញ្ចឹងក Bulbe rachidien ។ ៣- សរសៃវិញ្ញាណទាក់ទងនឹងខួរឆ្អឹងកញ្ចឹងក Nerf pneumogastrique ( parasympathique) ។ ៤- ខួរឆ្អឹងខ្នង Moelle épinière ។ ៥- សរសៃវិញ្ញាណទាក់ទងនឹងខួរឆ្អឹងខ្នង Nerf cardiaque (orthosymbathique) ។ ៦- បេះដូង Cœur ។ ៧- កម្រងកូនកណ្ដុរនៃសរសៃវិញ្ញាណ Chaine ganglionnaire orthosympathique ។ ៨- ទីប្រជុំកូនកណ្ដុរ សម្រាប់ទាក់ទងគ្នា នៃសរសៃវិញ្ញាណទាំងពីពួក Ganglions pêriphèriques et plexus ។

ឯសរសៃវិញ្ញាណដែលទាក់ទងនឹងខួរឆ្អឹងខ្នង សម្រាប់ញុំាងចលនារូបកាយមានចលនាបេះដូងជាដើម ឲ្យដើរញឹកញាប់ឆាប់រហ័ស, ចំណែកសរសៃវិញ្ញាណដែលទាក់ទងនឹងខួរឆ្អឹងកញ្ចឹងក សម្រាប់បន្ថយល្បឿនចលនានោះៗ ឲ្យមានគុណភាពប្រក្រតីឡើងវិញ ។

ឧទាហរណ៍ ពេលយើងឃើញ ឬឮអ្វីចម្លែក ដែលនាំឲ្យតក់ស្លុតភ្ញាក់ ឬក៏ ពេលទើបនឹងរៀននិយាយសុន្ទរកថា ឬ ទេសនាក្នុងទីប្រជុំធំ ហើយស្ទន់ញាក់ញ័រស្លុកពោះ ដែលធ្លាប់ហៅថាប្រាបជាក់ ពេលនោះញ័រកើតក្នុងទ្រូង គឺបេះដូងដើរញាប់ ដោយអំណាចសរសៃវិញ្ញាណដែលទាក់ទងនឹងខួរឆ្អឹងខ្នង បណ្ដាលឡើងខ្លាំង ព្រោះភាពទន់ខ្សោយរបស់ចិត្តដែលមិនបានហ្វឹកហាត់, យូរបន្តិចមកស្រាប់តែបានស្រួលធម្មតាឡើងវិញ ដោយអំណាចសរសៃវិញ្ញាណដែលទាក់ទង

និងខ្សែភ្លើងខ្លួនកញ្ចែក មកបន្ថយល្បឿនដែលដើរញាប់នោះជាធម្មតៈ ត្រឡប់ដើរ មានគុណភាពវិញ ។ នេះធម្មតាធម៌ ជាអញ្ញមញ្ញប្បច្ច័យ ដែលសង្ខារតាក់តែង មក ។ ល ។

រឿងឈរស្រែវិញ្ញាណក្នុងក្នុងរូបនេះ មានន័យវែងឆ្ងាយណាស់ ជាប់ទាក់ទងគ្នា ពីខួរមកខ្លួន មកឈាមឈាម មកពោះវៀន មកស្បែក ។ល។ ដូចខ្សែ ជាប់តគ្នានឹក ឡើងស្រេកឃ្លាន ដឹងឈឺស្រួលជាដើម ។

(តំនូរនិពន្ធខនេះរបស់ ពាន់ ប៉េងយុន និស្សិតប្រទេសបារាំង)

## របៀបប្រតិកម្មដែលនាំឱ្យសើច និងយំ

ដូចបាននិយាយខាងដើមហើយថា ការសើចនិងយំនេះមិនមែនជាប់កើតពីចិត្តផ្ទាល់មកឡើយ គឺដំបូង អាយតនៈ និងផស្សៈ កើតសិន ទើបចិត្តដែលនាំឲ្យសើចឬយំនោះកើតក្រោយ ។

ឧទាហរណ៍ បុរសម្នាក់ឃើញរាជបុរសកំពុងចាប់កូនខ្លួនកាត់កសម្លាប់ ព្រោះកូននោះ ប្រព្រឹត្តអំពើឧក្រិដ្ឋ ក៏តាំងយំស្រែក ញាប់ញ័របបូរទឹកភ្នែកទឹកសំបោរ ។

ពេលមុនបុរសនោះយំ ភ្នែកបុរសគឺអាយតនៈក្នុងប៉ះទង្គិច

ស្រូបបានអាយតនៈក្រៅគឺរូបកូនដែលរាជបុរសកំពុងសម្លាប់,ចក្ខុ-វិញ្ញាណ គឺសរសៃវិញ្ញាណរបស់ភ្នែកទទួលចាប់យកអាយតនៈ គឺទិដ្ឋភាពដែលរាជបុរសកំពុងសម្លាប់កូននោះជាអារម្មណ៍, ការប៉ះទង្គិចអាយតនៈបែបនេះឈ្មោះថាផស្សៈ, ចិត្តបានដំណឹងដោយផស្សៈនេះឯង, ដំណឹងនោះមិនជាទីគាប់ចិត្ត (ជាអនិដ្ឋារម្មណ៍) ទោមនស្សវេទនាកើតមានឡើង គឺកើតចិត្តឈ្មោះ ទ.ប.ស.អ-បណ្ដាលឲ្យបេះដូងកំរើកញ័រញាប់ញ័រខ្លាំងខុសប្រក្រតី ដែលយើងស្ដាប់ហៅថាតក់ស្លុតចិត្ត ញ័រភឹបៗក្នុងទ្រូង គឺមកពីអានុភាពចិត្តឈ្មោះ ទ.ប.ស.អ.នោះ ញុំាងសរសៃវិញ្ញាណ ដែលទាក់ទងនឹងខួរក្បាលឆ្អឹងខ្នង (Nerf cardiaque) ឲ្យកំរើកខ្លាំង ទើបសរសៃវិញ្ញាណនោះ ញុំាងបេះដូងឲ្យដើរខ្លាំង, ចរន្តឈាមក៏ធ្វើការខ្លាំង នាំឲ្យកំរើករំពើកដល់សរសៃក្នុងភ្នែក ដែលទាក់ទងនឹងថង់អស្សុប្រភព កន្លែងសម្រាប់បញ្ចេញទឹកភ្នែក (Glande lacrymale) ធ្វើឲ្យទឹកភ្នែកហូរបញ្ចេញមក តាមភ្នែកផង តាម

ប្រមុះផង ដែលធ្លាប់និយាយថា យំហូរទឹកភ្នែកទឹកសំបោរ ។

អស្សុប្រភពនោះ ស្ថិតនៅក្រោមឆ្អឹងភ្នែកខាងលើជាប់នឹងសាច់ភ្នែកទាំងពីរ សម្រាប់ផ្សើមភ្នែកឲ្យសើមជានិច្ចផង សម្រាប់បញ្ចេញទឹកភ្នែក ក្នុងពេលយំនឹងសើចផង និងក្នុងពេលដែលភ្នែកត្រូវកំដៅខ្លាំង ឬភ្នែកប៉ះទង្គិចនឹងអ្វីៗ ឬក៏ភ្នែកប៉ះជាតិហឹរ ជូរ ប្រៃជាដើម ទឹកភ្នែកក៏ហូរចេញមកដែរ ដូចរូបទាំងពីរនេះ ។

## រូបភាពទី ១




រូបភ្នែកខាងក្នុងមើលឃើញពីចំហៀង

## រូបភាពទី ២




រូបភ្នែកខាងក្រៅមើលមិនឃើញចំពីមុខ

### ន័យរបស់រូបតាមលំដាប់លេខរៀង

១- សរសៃនាំឈាម ។ ២- សរសៃចក្ខុប្បសាទ ។ ៣- ដុំអស្សុប្រភព គឺ កន្សែងបញ្ចេញទឹកភ្នែក (Clande lacrymale) ។ ៤- សរសៃទាក់ទងនឹងដុំ អស្សុប្រភព។ ៥- កន្សែងអស្សុប្រភពស្ថិតនៅ ។ ៦- រន្ធបញ្ចេញទឹកភ្នែកតាមភ្នែក។ ៧- រន្ធបញ្ចេញ ទឹកភ្នែកតាមច្រមុះ ។ ៨-រន្ធច្រមុះ ។

អំពីប្រតិកម្មដែលនាំឲ្យសើចហើយចេញទឹកភ្នែកនោះ ក៏មានលំនាំប្រហែលគ្នានឹងយំដែរ ព្រោះការកើតទុក្ខ និងការសប្បាយជាគូគ្នាគឺ ទោមនស្សជាគូនឹងសោមនស្ស, កាលកើតទុក្ខល្មម មិនបណ្ដាលឲ្យយំបានឡើយ លុះតែកើតទុក្ខធំតក់ស្លុតចិត្តខ្លាំង បេះដូងនិងសរសៃឈាមធ្វើការខ្លាំងកំរើកប៉ះដល់អស្សុ-ប្រភព ទើបបណ្ដាលឲ្យទៅជាយហូរទឹកភ្នែកទឹកសំបោរចេញមក, បើតក់ស្លុតចិត្តខ្លាំងហួស បេះដូងដើរញាប់ហួសកំរិត ទៅជាតាំងសន្លប់ក៏មាន ។ ឯការសើចក៏ដូច្នោះដែរ បើគ្រាន់តែសប្បាយរីករាយល្មម សើចក៏ល្មមមិនបណ្ដាលឲ្យចេញទឹកភ្នែកទឹកសំបោរឡើយ លុះតែសប្បាយរំភើបចិត្តខ្លាំង ទើបសើចខ្លាំងធ្វើឲ្យបេះដូងនិងសរសៃឈាមធ្វើការខ្លាំង កំរើកប៉ះដល់អស្សុ-ប្រភព ទឹកភ្នែកទឹកសំបោរក៏ហូរចេញមកជាមួយសំណើចនោះ, បើរំភើបចិត្តខ្លាំងហួស បេះដូងដើរញាប់ហួសកំរិត ទៅជាតាំងសន្លប់ក៏មាន ដូចកាលជក្សត្រក្នុងរឿងវេស្សន្តរ បានជួបគ្នា

សប្បាយរីករាយហួស ទៅជាសន្លប់ទាំង ៦ ព្រះអង្គ ។

(សំដែងអំពីហេតុដែលនាំឲ្យមនុស្សសើចយំសង្វេគពេប៉ុណ្ណោះ)

## អំពីសង្គម

**ហេតុអ្វីមនុស្សសត្វនិងរុក្ខជាតិចូលចិត្តរស់នៅផ្តុំគ្នាក្នុងលោកនេះ?**

បើស្រាវជ្រាវរកឫសគល់ដើមបំផុត ដែលបណ្តាលឲ្យកើតជាសង្គមឡើង ឃើញថា កើតមកពីអវិជ្ជានិងសង្ខារដែរ ព្រោះអវិជ្ជានិងសង្ខារនេះហើយ ដែលប្រមូលផ្តុំផ្គុំគ្នាក្នុងដីទឹកភ្លើងខ្យល់អាកាសឲ្យរួបរួមគ្នាជាពួកក្រុមជាសង្គម ក៏កើតបន្តៗគ្នាពីតិណជាតិរុក្ខជាតិ មកជាសត្វល្អិត ពីសត្វល្អិតមកសត្វធំ ពីសត្វធំមកជាមនុស្ស ។

ដូច្នេះឃើញថា សង្គមក្នុងពិភពលោកនេះមានបីគឺ

១- សង្គមរុក្ខជាតិ,

២- សង្គមសត្វតិរច្ឆាន,

៣- សង្គមមនុស្ស ។

អាស្រ័យពូជដើមរបស់ពិភពលោក មាននិស្ស័យបែបនេះ ទើបវត្ថុធាតុទាំងអស់ក្នុងលោកចំរើនលូតលាស់បានដោយសារតែ សង្គម គឺការផ្តុំផ្គុំ សាមគ្គីរួបរួមគ្នា ព្រោះមានការចាំបាច់ ត្រូវពឹងពាក់គ្នា ដើម្បីរស់រៀងខ្លួន ។ កុំនិយាយឡើយដល់ទៅវត្ថុមានចិត្តវិញ្ញាណដូចមនុស្សសត្វជាដើម សូម្បីវត្ថុគ្មានចិត្តវិញ្ញាណ ដូចតិណជាតិ រុក្ខជាតិជាដើមនេះ ក៏ត្រូវការសង្គមជាចាំបាច់ដែរ ដើម្បីជីវិតវា ។

## ១) អំពីសង្គមរុក្ខជាតិ

ពួកស្មៅឈើវល្លិ៍ មិនដែលដុះនៅទីវាលស្រឡះតែម្នាក់ឯងឡើយ ព្រោះខុសពូជនិស្ស័យរបស់វា រស់នៅមិនកើត, វាចូលចិត្តដុះ រស់នៅជ្រៀតជ្រែកជិតៗគ្នា ជាពួក ជាក្រុម ជាសង្គម ។

សង្គមរុក្ខជាតិនេះ មានសកម្មភាពយ៉ាងសំខាន់ គួរឲ្យចាប់អារម្មណ៍ យកចិត្តទុកដាក់ត្រិះរិះពិចារណាណាស់ដែរ ព្រោះ

សង្គមរុក្ខជាតិនេះ ជាសង្គមដើមទី១ របស់សង្គមមនុស្សសត្វ ។

សព្វថ្ងៃ ទីណាដែលវាលស្រឡះ គ្មានស្មៅឈើវល្លិដុះសោះនោះ គេបង្កើតសង្គមរុក្ខជាតិឡើង គឺយកពូជស្មៅឈើវល្លិទៅដាំនៅទីនោះឲ្យបានច្រើនដើម ដល់យូរខែឆ្នាំបន្តិចទៅ ទីនោះនឹងក្លាយទៅជាព្រៃធំ ព្រោះពូជស្មៅឈើវល្លិដទៃៗទៀត ដែលគេមិនបានដាំសោះ ក៏ចេះតែកើតមានដុះលូតលាស់ឡើងព្រោងព្រាត ដោយអំណាចជីវជាតិ និងធាតុអាកាសដែលកើតមានអំពីសង្គមរុក្ខជាតិដែលគេបានបង្កើតឡើងនោះ ។

សូមមិត្រអ្នកអានពិចារណាមើល ! ស្មៅឈើវល្លិតូចៗត្រូវការពឹងពាក់ស្រូបជញ្ជក់យកជីវជាតិនិងធាតុទឹកត្រជាក់ ពីស្មៅឈើវល្លិធំៗ ដែលដុះមុន ព្រោះឫសដើមមែកស្លឹកស្មៅឈើវល្លិធំៗនោះ ស្រូបយកជីវជាតិនិងធាតុទឹកពីអាកាស ពីចំហាយព្រះអាទិត្យ និងពីផែនដី មកធ្វើជាចំណីអាហារ និងញ៉ាំងបរិយា-កាសក្នុងព្រៃនោះ ឲ្យមានសីតុណ្ហភាពងាយស្រួលដល់ការដុះ

លូតលាស់, លុះឫសដើមមែកស្លឹកស្មៅឈើវល្លិធំៗនោះ ងាប់ បាក់ជ្រុះទៅ រលួយកើតជាជីរ ធ្វើឲ្យផែនដីក្នុងព្រៃនោះធូរជាយ ស្រួលដល់ឫសស្មៅឈើវល្លិ ធ្វើដំណើរចាក់ក្រុកត្រុកវះលូន ទៅគ្រប់ទិសទី ដើម្បីស្វែងរកចំណីអាហារចិញ្ចឹមជីវិត ។

ឯស្មៅឈើវល្លិនោះវាមានជីវិត មានការស្រេកឃ្លាន មានការស្វែងរកចំណីអាហារ មានញីមានឈ្មោល មានម៉ែឪមានកូនចៅ មានការងារធ្វើ ដើម្បីចិញ្ចឹមជីវិតវារាល់ពេលវេលា វាមិនខ្ជិលច្រអូស វាគ្មានពេលឈប់សម្រាកដូចមនុស្សសត្វឡើយ វាធ្វើការជានិច្ចគ្រប់គាទីដើម្បីរស់នៅ ផ្តល់ផលប្រយោជន៍ឲ្យសង្គមរបស់វា និងសង្គមមនុស្សសត្វក្នុងលោកនេះ ។

ក្នុងក្បួនវិទ្យាសាស្ត្រ ផ្នែករូបសាស្ត្រនៃរុក្ខជាតិជា ស្មៅឈើវល្លិ វាស៊ីចំណីអាហារតាមឫសនិងតាមស្លឹក គឺវាត្រូវយកចំណីអាហារអំពីផែនដីតាមឫស វាត្រូវយកចំណីអាហារអំពីអាកាសតាមស្លឹក ។ ឫសវាដូចជាដៃជើងមនុស្សសត្វមានជីវិត

ចេះរុករាវឫសរើករសិបទៅក្នុងផែនដី, ទីណាមានជីវជាតិ មាន ធាតុទឹកសើម វារុកត្រួកលូនទៅរកទីនោះ ដើម្បីស្រូបជញ្ជក់ ស៊ីចំណីអាហារ, បើទីណាមានឧបសគ្គ ដូចជាដុំថ្មឬដីរឹងខ្លាំង ឬទឹកច្រើនពេក ឬក៏ដីមានជាតិប្រៃជូរហួសជាដើម ឫសវាគេចវាង ចេញពីទីនោះ មិនលូនវារទៅជិតឡើយ ហាក់ដូចជាមានចិត្ត វិញ្ញាណស្គាល់ខុសត្រូវដែរ ។

ឯចំណីអាហាររបស់ឈើវល្លិនោះ គឺវត្ថុធាតុទាំងឡាយដែល មាននៅក្នុងផែនដី និងក្នុងអាកាស ដូចជាធាតុ អុកស៊ីហ្សែន អាកាសធាតុក្ល័រ អាហ្សូត ហ្វូសហ្វាត ប៉ូតាស និងវត្ថុធាតុផ្សេងៗ ទៀតជាច្រើន ដូចជាតិកំបោរ ដែក ស្ពាន់ធ័រ ម៉ាញ៉េស៊ីយ៉ូម ក្លរ ស៊ូដ ប៉រ និងម៉ង់កាណែស ។ល។ វត្ថុធាតុទាំងអស់នេះសុទ្ធតែជា ទ្រព្យសម្បត្តិមាសប្រាក់ ជាវត្ថុបំណងរបស់ស្មៅឈើវល្លិទាំង ឡាយ ដែលវាធ្វើការរុកត្រួកលូនវាររកគ្រប់ទិសទីឥតឈប់ឈរ ដូចជាមនុស្សខំធ្វើការរកស៊ី ដើម្បីបានមាសប្រាក់ដូច្នោះដែរ ។

ដើម្បីស្វែងរកបាននូវវត្ថុធាតុទាំងអស់នេះ អាស្រ័យសង្គម ទើបស្មៅឈើវល្លិទាំងឡាយ ត្រូវការបេក្ខមជាចាំបាច់ បើគ្មានសង្គមទេស្មៅឈើវល្លិទាំងឡាយក៏គ្មានដែរ ដូចបាននិយាយខាងដើមហើយថា សង្គមរុក្ខជាតិនាំឲ្យផែនដីមានជីវជាតិ មានធាតុអាកាសល្អ មានភ្លៀងច្រើន គឺនាំឲ្យកើតមានវត្ថុធាតុទាំងឡាយ មានធាតុអុក្សីហ្សែនជាដើម ដែលរុក្ខជាតិត្រូវការនោះឯង ។ ស្មៅឈើវល្លិធំ ៗ មិនគ្រាន់តែផ្តល់វត្ថុធាតុ ឲ្យស្មៅឈើវល្លិតូច ៗ ប៉ុណ្ណោះឡើយ ថែមទាំងជួយថែរក្សាការពារឲ្យស្មៅឈើវល្លិតូចៗ នោះរួចផុតពីឧបសគ្គផ្សេងៗមានខ្យល់ព្យុះនិងកំដៅព្រះអាទិត្យជាដើមទៀត ដូចមនុស្សសត្វជួយការពារគ្រួសាររបស់ខ្លួនដូច្នោះដែរ ។

ពេលមានខ្យល់ព្យុះសង្ឃរាខ្លាំងម្តងៗ ស្មៅឈើវល្លិធំ ៗ ចេញមុខទទួលឧបសគ្គនោះភ្លាម សុខចិត្តស៊ូទប់ទល់ យកខ្លួនប៉ះទង្គិចប្រវាយប្រតប់វាយ ជាមួយព្យុះសង្ឃរានោះ ទោះបីព្យុះ

សន្សារ បោកត្រូវប្រេតប្រោតរបួសបាក់បែកជ្រុះស្លឹកយ៉ាងណា ក៏ ស្មៅឈើវល្លិធំៗ នោះ មិនរត់ចោលឡើយ សុខចិត្តក្រាញតស៊ូ ការពារស្មៅឈើវល្លិតូចៗ ដរាបដល់រយៈមែកបាក់ដើម រលំ ដួលស្លាប់នៅកន្លែង ។ ចំពោះការតស៊ូនឹងកំដៅព្រះអាទិត្យ វិញ ក៏សុខចិត្តទ្រាំក្តៅធ្វើព្រងើយគ្រប់នាទី ដរាបដល់ស្វិត ក្រយជ្រុះស្លឹក ស្ងួតដើមស្លាប់ឥតប្ដូរឡើយ ដើម្បីឲ្យស្មៅឈើ វល្លិតូចៗបានជម្រកត្រជាក់ ដុះលូតលាស់បានស្រួល ។

ឯស្មៅឈើវល្លិធំៗវិញ ក៏ត្រូវការពឹងពាក់ស្រូបជញ្ជាក់យក ជីវជាតិ, និងកិច្ចការពារឧបសគ្គ អំពីស្មៅឈើវល្លិតូចៗជាការ ចាំបាច់ដែរ គឺត្រូវការចំពោះសង្គមដូចគ្នា បើគ្មានសង្គមទេ ស្មៅ ឈើវល្លិធំៗនោះដុះលូតលាស់ធំឡើងមិនកើត នឹងត្រូវខ្យល់ព្យុះ បក់ដៅព្រះអាទិត្យបោកបក់ឲ្យរលំ ធ្វើឲ្យស្វិតក្រៀមស្លាប់មិន ខាន ។ សូម្បីស្មៅឈើវល្លិ ដែលកំពុងដុះលូតលាស់ល្អក្នុងសង្គម រុក្ខជាតិ មានដើមធំមាំខ្ពស់យ៉ាងណាហើយក៏ដោយ បើគេកាប់

ស្មៅឈើវល្លិតូចៗជុំវិញអស់រលីងហើយ ស្មៅឈើវល្លិធំនោះក៏មិនអាចមានជីវិតរស់នៅយូរឡើយ ងើររលំបាក់ស្វិតស្លាប់មិនខាន ព្រោះស្មៅឈើវល្លិតូចៗ ដែលដុះចោមរោមជុំវិញនោះ ដូចជារនាំងឬជំបូលគ្របបិទបាំងផែនដី ឲ្យស្មៅឈើវល្លិធំៗបានត្រជាក់គល់ មិនឲ្យត្រូវកំដៅព្រះអាទិត្យខ្លាំង រក្សាធាតុទឹកទុកឲ្យដីសើមបានយូរ និងទប់ទុកនូវកំទេចដីរជាតិមិនឲ្យហូរទៅតាមទឹក ឬហើរទៅតាមខ្យល់បាន និងជារនាំងជួយការពារព្យុះសង្ឃរា មិនឲ្យបោកបក់ត្រូវខ្លាំង ។

ដោយអានុភាពសង្គមរុក្ខជាតិ ដែលចេះជួយការពារគ្នា ជួយផ្តល់ប្រយោជន៍សុខចំរើនឲ្យគ្នា គឺពួកស្មៅឈើវល្លិធំៗជួយការពារសង្គ្រោះយឹតយោងស្មៅឈើវល្លិតូចៗ, ពួកស្មៅឈើវល្លិតូចៗ ជួយការពារផ្តល់ប្រយោជន៍ឲ្យស្មៅឈើវល្លិធំនេះឯង នាំឲ្យពួកតិណជាតិ រុក្ខជាតិគញ្ញជាតិទាំងឡាយចោមរោមដុះលូតលាស់កាន់តែច្រើន, ឯពួកទេវតាមនុស្សសត្វ ក៏មានចិត្តរីករាយ

ចូលទៅរកសង្គមរុក្ខជាតិនោះ ដើម្បីអាស្រ័យនៅ និងចិញ្ចឹមជីវិតដោយផលព្រៃឈើនោះ ។ សូម្បីមហាមេឃក៏ហាលចាញ់អានុភាពសង្គមរុក្ខជាតិដែរ ព្រោះសង្គមរុក្ខជាតិ ដែលគ្មានចិត្តវិញ្ញាណនេះត្រូវបបួលពពកយកទឹកភ្លៀង មកបំពេញសង្គមខ្លួនបានដោយងាយ ។ គួរអស្ចារ្យលោកយកគម្រប់តាមសង្គមរុក្ខជាតិដែលមានលក្ខណៈគុណសម្បត្តិល្អបែបនេះកុំខាន ។

ឯគុណវិបត្តិនៃសង្គមរុក្ខជាតិនេះក៏មានខ្លះដែរ, បើមិនបានជាតិតែហាក់ដូចជាសង្គមរុក្ខជាតិ មានសាមគ្គីស្រុះស្រួលស្មោះត្រង់នឹងគ្នាណាស់ គ្មានការក្បត់ គ្មានអំពើអកុសលជិះជាន់សង្កត់សង្កិនលួចប្លន់ ដណ្តើមទឹកដី ឋានស័ក្តិ ស៊ីសំណូកប្រកាន់ពួកបក្ស សម្លាប់បំបាត់ជីវិតគ្នាឡើយ, ប៉ុន្តែបើពិនិត្យសង្កេតឲ្យល្អិតល្អន់ទៅឃើញថា មានអំពើអកុសលពុករលួយ ដូចសង្គមមនុស្សសត្វដែរ គ្រាន់តែមិនសូវជាក់ស្តែងប៉ុណ្ណោះ ព្រោះរុក្ខ-ជាតិគ្មានចិត្ត គ្មានរូបកាយចេះនិយាយស្តី ។

អំពីការជិះជាន់សង្កត់សង្កិនដណ្ដើមឋានៈយសសក្ដិក្នុងសង្គមរុក្ខជាតិ៖ ពួកស្មៅឈើវល្លិជាច្រើន ដែលមានលក្ខណៈអាក្រក់ទិលខូចដូចមនុស្សសត្វដែរ មានដើមជ្រៃ បញ្ញើក្អែក និងពួកវល្លិខ្លះទៀត, ពួកឈើនេះមិនចង់ដុះនៅទីឋានទាបផ្ទាល់នឹងដីដូចឈើដទៃឡើយ ចង់តែដុះនៅទីខ្ពង់ខ្ពស់ ជិះជាន់សង្កត់សង្កិនលើសិទ្ធិឈើដទៃ ដូចជាដើមជ្រៃទៅដណ្ដើមដុះលើឈើដែលមានឋានៈធំខ្ពង់ខ្ពស់ស្រាប់ មានដើមត្នោតជាដើម កាលបានដុះលើគេហើយ ទំលួតរិតបឺតជញ្ជក់យករសជាតិគេមកចិញ្ចឹមជីវិតខ្លួន ឲ្យបានធាត់ធំរស់នៅក្នុងទីខ្ពង់ខ្ពស់ ដែលគេទំរស់មកជាយូរឆ្នាំហើយនោះ, ដល់ខ្លួនបានធាត់ធំ ក៏សម្លាប់គេចោលទៅ គឺជិះជាន់បឺតជញ្ជក់យករសជាតិគេ និងដណ្ដើមយកឋានៈធំខ្ពង់ខ្ពស់របស់គេហើយ សម្លាប់ម្ចាស់គេចោលទៀត ។

ឯដើមបញ្ញើក្អែកក៏ដូច្នោះដែរ ខ្លួនជាពូជឈើតូចទាបគ្មានយសស័ក្ដិ ធំខ្ពង់ខ្ពស់ច្រើនដូចឈើដទៃ ទំទៅដុះបន្តឹតលើចុង

កំពូលគេ ដើម្បីបានប្រើសយកសតក្តិធក់ក្តត់ដូចពូជឈើធំៗ, លុះ ចំណាប់សិប់លើចុងកំពូលហើយ ក៏ទំស្រូបជញ្ជក់យករសជាតិគេ ចិញ្ចឹមជីវិតខ្លួន សម្លាប់គេចោលទៅ ។ នេះជាអំពើអកុសល អយុត្តិធម៌មួយ ក្នុងសង្គមរុក្ខជាតិ ។

អំពីការរុករកឧក្រានចំលួចប្លន់សម្លាប់ដណ្តើមយកទឹកដីក្នុង សង្គមរុក្ខជាតិ= ពួកឈើជាច្រើនដែលមានលក្ខណៈជាចក្រពត្តិ អាក្រក់បែបនេះមានដើមឧក្រានខេត្ត ល្គា ស្បូវ កំពោក ត្រើមជា ដើម, ពួកឈើនេះ បើដុះនៅទីណាហើយ តែងកតត្បាតលួច ប្លន់សម្លាប់ដណ្តើមយកទឹកដីក្នុងទីនោះ ក្មេងៗឈើដែលដុះក្នុងទី នោះមុន វិនាសអន្តរាយរត់ចោលស្រុកភូមិអស់, ដូចដើមល្គា ស្បូវ ឧក្រានខេត្តជាដើម បើវាដុះនៅទីណាហើយ ពួកឈើ ស្មៅស្លឹកក្នុងទីនោះ ត្រូវវិនាសអន្តរាយអស់ ទីដីនោះត្រូវបាន ជាកម្មសិទ្ធិរបស់វា ។ ឯកំពោក ត្រើមជាដើម ដែលដុះក្នុងបឹង ត្រពាំងក៏ដូច្នោះដែរ បើវាដុះក្នុងត្រពាំងណាហើយ វាតែងរាត

ពុទ្ធសាសនបណ្ឌិត្យ បណ្ណាល័យ LIBRARY BUDDHIST INSTITUTE

ត្បាតរុក្ខជាតិ គ្រាន់តែជិះជាន់ពួកផលជាតិទាំងឡាយ មានឈូក ព្រលិតជាដើម ដែលដុះក្នុងទីនោះ បុនឲ្យវិនាសអន្តរាយអស់, ទឹកក្នុងបឹងត្រពាំងនោះត្រូវបានជាកម្មសិទ្ធិរបស់វា ។ នេះជាអំពើអយុត្តិធម៌ក្រក់មួយក្នុងសង្គមរុក្ខជាតិ ។

អំពីការស៊ីសំណូកលំអៀងប្រកាន់ពួកប័ក្សក្នុងសង្គមរុក្ខជាតិ= ស្មៅឈើវល្លិទាំងឡាយ ពិតមែនតែគ្មានចិត្តវិញ្ញាណដូចមនុស្សសត្វ ប៉ុន្តែចេះស៊ីសំណូក ចេះលំអៀងប្រកាន់ប័ក្សពួកដែរ ដូចជាស្មៅគ្រប់ប្រភេទ និងឈើវល្លិទាំងឡាយពួកខ្លះ ដែលដុះក្នុងស្រែចម្ការ ក្នុងសួនផ្កាជាដើម, ពួកស្មៅឈើវល្លិទាំងនេះ វាសុខចិត្តឲ្យដុះលូតលាស់មានជីវិតរាក់ធំបាន តែស្មៅឈើវល្លិណាជាប័ក្សពួកវា ដែលមានកម្លាំងជាតិពូជប៉ុនស្រូបជញ្ជក់យកសំណូកគឺជីជាតិ មកជួលចែកឲ្យវាផង ទុករស់នៅខ្លួនឯងបានផង, ឯរុក្ខជាតិដទៃដូចដើមពោត សណ្តែក ស្រូវ កប្បាសជាដើម ដែលមានកម្លាំងខ្សោយ មិនអាចចែករំលែកសំណូកគឺជី-

ជាតិឡើងបាននោះ  វាសត្វទាំងនេះវាក៏មិនឲ្យផុះលូតលាស់ធាត់ធំបានឡើយ  ព្រោះមិនមែនបក្សពួកវា  ។  នេះជាអំពើអយុត្តិធម៌ពុករលួយមួយ  ក្នុងសង្គមរុក្ខជាតិ  ។

ពួកស្មៅឈើវល្លិណា  ដែលចិលខូចប្រព្រឹត្តអំពើអកុសលពុករលួយក្នុងសង្គមរុក្ខជាតិ  ដូចខាងលើនេះ  ត្រូវមានទោសជាទម្ងន់ដល់ប្រហារជីវិត  ដូចដើមព្រៃ  បញ្ញើក្អែក  ស្បូវ  ស្គា  ស្មៅជាដើម  ត្រូវមនុស្សលោកស្អប់ខ្ពើម  កាប់គាស់បំផ្លាញលុបឡប់ចោលឥតត្រាប្រណីឡើយ  ព្រោះវាជាអ្នកក្បត់សង្គមរុក្ខជាតិ  ។  មនុស្សលោកទាំងឡាយ  មិនត្រូវយកគម្រាប់តាមពួកឈើចិលខូចនេះឡើយ  ។

## ២)  សង្គមសត្វតិរច្ឆាន

ពួកសត្វតិរច្ឆានទាំងឡាយ  ដែលរស់នៅលើគោកនិងក្នុងទឹក  មានគោក្របីដំរីសេះ  ឆ្កែឆ្មាស្រមោចស្រមើមត្រីបង្កងជាដើម  មិនដែលរស់នៅទីស្ងាត់តែម្នាក់ឯងឡើយ  ចូលចិត្តរស់

នៅរួមគ្នា ជាពួកជាក្រុម ជាសង្គម ដើម្បីជីវិតរស់ ព្រោះជីវិតសត្វតិរច្ឆាន ត្រូវការសង្គមជាចាំបាច់ ជាងជីវិតរុក្ខជាតិទៅទៀត ។

ពួកស្មៅឈើវល្លិទាំងឡាយ ត្រូវការចំណីអាហារតែមួយបែបដូចគ្នា គឺដី ទឹក ជីរជាតិ និងធាតុអាកាស ។ ឯពួកសត្វតិរច្ឆាន ត្រូវការចំណីអាហារច្រើនបែបផ្សេងៗគ្នា សត្វខ្លះបើស្មៅឈើវល្លិជាចំណីអាហារ សត្វខ្លះស៊ីដីជាចំណីអាហារ សត្វខ្លះស៊ីសាច់សត្វមនុស្សជាអាហារ សត្វខ្លះទៀតស៊ីបាយចំណីដូចពួកមនុស្សដែរ ។ ចំណីអាហារទាំងអស់នេះ កើតមានតែក្នុងសង្គម ទើបសត្វតិរច្ឆានត្រូវការសង្គមជាចាំបាច់ខានមិនបាន ។

សង្គមតិរច្ឆាននេះ ជាសង្គមអនាធិបតេយ្យ ឥតច្បាប់ទម្លាប់ គ្មានធម្មនុញ្ញការពារសិទ្ធិសេរីភាពសត្វក្នុងសង្គមឡើយ មានតែកម្លាំងដៃជើង កម្លាំងស្នែងនិងចង្កូម ជាគ្រឿងការពារសិទ្ធិសេរីភាពរៀងៗខ្លួន ។ សត្វណាមានកម្លាំងច្រើនបានស្នែងស្រួច មានចង្កូមមុតមានពិស សត្វនោះមានសិទ្ធិសេរីភាពច្រើន

មានចំណីអាហារគ្រប់គ្រាន់ មានគេគោរពកោតខ្លាចច្រើន, សត្វណាខ្សោយគ្មានស្នែងគ្មានបក្ខពួកខ្វះការតស៊ូ សត្វនោះត្រូវគេបៀតបៀនជិះជាន់សម្លាប់ចោល និងត្រូវជាចំណីគេ ។

សូមពិចារណាមើលចុះ សត្វធំស៊ីសត្វតូច សត្វមានអានុភាព ស៊ីសត្វគ្មានអានុភាព ដូចត្រីធំស៊ីត្រីតូច ត្រីតូចស៊ីសត្វល្អិតតូចៗ ដូចដង្កូវទឹក បង្គារ កំពិសជាដើមតទៅទៀត, ក្រពើក្រពា ស៊ីត្រីទាំងធំទាំងតូច, សត្វស្លាសំពោចស៊ីមាន់ទា, មាន់ទាស៊ីសត្វតូចៗ ដូចដង្កូវ កន្ធេន កណ្តូប ចង្រិតជាដើម, សត្វខ្លា ស៊ីគោ ក្របី ដំរី សេះ ក្តាន់ រមាំង ឈ្លូស ប្រើស ចៀម ពពែជាដើម, សត្វខ្លាធំៗដែលមានអានុភាព ស៊ីខ្លាដែលទន់ខ្សោយនោះទៀត ។ ឃើញច្បាស់ថា សត្វតិរច្ឆានត្រូវការសង្គមជាចាំបាច់ខ្លាំងណាស់ ព្រោះសង្គមជាចំណីអាហាររបស់វាៗមានជីវិតរស់នៅបាន អាស្រ័យសាច់ឈាមរសជាតិ របស់សង្គម; ដូចសត្វខ្លា បើវាកើតឡើងក្រៅសង្គម គឺកើតក្នុងទី

ស្ងាត់តែម្នាក់ឯងគ្មានសត្វអ្វីនៅជិតវាសោះនោះ វាពិតជាស្លាប់មិនខាន ។

ក្នុងសង្គមសត្វតិរច្ឆាននេះ បើមិនបានជាពិនិត្យឲ្យហ្មត់ចត់ ឃើញថាសង្គមពុករលួយអាក្រក់ពេកណាស់, ប៉ុន្តែ បើពិនិត្យឲ្យជិតដល់ទៅឃើញថា ក្នុងសង្គមនេះ មានសេចក្ដីល្អខ្លះដែរ ដូចពួកសត្វខ្លះវាមានចរិយាល្អជាងពួកមនុស្សទៅទៀត ។

ពួកសត្វស្រមោច កណ្ដៀរ វាមានសាមគ្គីធម៌ ចេះស្ដាប់បង្គាប់តាមមេបាវ មានសេចក្ដីព្យាយាម ចេះប្រមូលសន្សំសំចៃទុកទ្រព្យសម្បត្តិ ជាងពួកមនុស្សភាគច្រើនឆ្ងាយណាស់ ។

ដូចធ្លាប់ឃើញស្រាប់ ពួកកណ្ដៀរ វាស្រុះស្រួលចិត្តគ្នា ចេះស្ដាប់បង្គាប់តាមមេបា ចេះធ្វើការហត្ថកម្ម ដំពាំនដី ម្នាក់ៗ ដំពាំនមួយដុំបានតែបន្តិចប៉ុនចុងម្ជុល យកទៅគរពូនធ្វើវិមានប្រាសាទច្រើនជាន់ច្រើនថ្នាក់ មានល្វែងបន្ទប់រាប់មិនអស់ សម្រាប់គ្រួសារវាជ្រកនៅ យូរៗកើតជាដំបូកយ៉ាងធំប៉ុនកូនភ្នំ, ឃើញថា

គ្រាន់បើជាងមនុស្សពួកខ្លះ ដែលគិតតែស៊ីចាយហ៊ឺហា រកដំបូលផ្ទះរបស់ខ្លួនជ្រកនៅគ្មាន ។

ពួកសត្វស្រមោចក៏ដូច្នោះដែរ រដូវរាំងស្ងួតវាចេះរួមសាមគ្គីតាមមេបាវ ខំប្រមូលផ្គានចំណីអាហារ មានគ្រាប់ស្រូវអង្ករជាដើម ដើរហូរហែយកទៅគរទុកក្នុងឃ្លាំងរបស់វា, ដល់ពេលមានភ្លៀងរលឹមសើមដី មិនអាចរកចំណីអាហារបាន វានាំគ្នាចិញ្ចឹមជីវិតដោយស្បៀង ដែលបានសន្សំទុកនោះដោយស្រួល , ឃើញថាមានគំនិតមារយាទប្រះសើរខ្ពង់ខ្ពស់ ជាងមនុស្សពួកខ្លះដែលខ្ជិលច្រអូស ស៊ីចាយខ្ជះខ្ជាយមិនចេះសំចៃទុក ដល់ពេលឃ្លានហើយអត់ គើចុកបោកទាល់បំផុតទៅសុំទានគេ ឬខ្ចីបុលស្រូវអង្ករអំបិលប្រហុកគេ យកមកបន្តជីវិត ។ មនុស្សបែបនេះអន់ជាងសត្វស្រមោចទៅទៀត ។

ពួកសត្វអក ក៏មានចិត្តគំនិតស្មោះត្រង់ តស៊ូចំពោះគ្រួសារវាណាស់ដែរ វាមានសេចក្ដីស្នេហាស្រឡាញ់កូននឹងញី

ឈ្មោលវា ស្មោះស្ម័គ្រស្មើជីវិត, បើកូនវាស្លាប់ ឬញីឈ្មោលវាស្លាប់ឬព្រាត់ប្រាសគ្នាដោយហេតុណាមួយ វាស្រែកយំ វាមិនស៊ីចំណីអាហារ ហើយហើរយ៉ាងខ្ពស់ទម្លាក់ដោកខ្លួនសម្លាប់ឲ្យស្លាប់តាមដែរ ។ ឃើញថាក្រាន់បើជាងមនុស្សពួកខ្លះ ដែលមានចិត្តវៀចផិតក្បត់ ស្វាមីភរិយាខ្លួន ជាមនុស្សសាវ៉ា មានប្ដីហើយ មានប្រុសសហាយទៀត ឬមានប្រពន្ធហើយ មានស្រីសហាយទៀត គឺឯក្រាន់បើជាងម៉ែឪខ្លះ ដែលមិនចេះថែរក្សាកូន បង្កើតកូនហើយធ្វើបាបវាយតប់ជួចទុំកំផរ យកកូនទៅលក់ឲ្យគេ ឬយកកូនទៅបោះចោលក្នុងគំនរសម្រាមជាដើម ។ មនុស្សបែបនេះ អន់ជាងសត្វអកទៅទៀត ។

ពួកសត្វកេងកងញី ក៏មានសេចក្ដីស្នេហា ស្រឡាញ់ស្មោះស្ម័គ្រចំពោះឈ្មោល និងកូនវាណាស់ដែរ, កាលបើវាមានកូនខ្ចីហើយ វាមិនឲ្យឈ្មោលវាចេញទៅរកស៊ីឡើយ វាខ្លាចមានសហាយ ឲ្យឈ្មោលវានៅក្រុងកូនក្នុងរូងឈើ ហើយវា

ពាំដីស្អិត យកមកបិទជិតទុកតែរន្ធបញ្ចុកចំណី គឺវាសុខចិត្តតស៊ូនឿយលំបាករកចំណីចិញ្ចឹមឈ្មោលវាផង កូនផង ដរាបដល់គំជុះស្លាបហើរបាន ទើបវាចឹកបំបែកដី ឲ្យហើរចេញទាំងកូនទាំងផុយមក ។ ឃើញថាគ្រាន់បើជាងស្ត្រីខ្លះ ដែលកាចកាឡកណ្ណីផតចេះស្រឡាញ់ប្ដីនិងកូនសោះ គិតតែពីប្រមាថជេរវាយតប់ឈ្មោះរករឿង ហើយប្រើប្ដីនិងកូនឲ្យបំរើខ្លួនដូចទាសកម្មករ ។ ស្ត្រីបែបនេះ អន់ជាងសត្វកេងកងញីឆ្ងាយណាស់ ។

ពួកសត្វប្រទាលកាលញី ក៏មានសេចក្ដីស្នេហាស្រឡាញ់បំរើផ្គាប់ចិត្តថាក់ថ្នមឈ្មោលវាណាស់ដែរ វាមិនឲ្យឈ្មោលវាទៅរកស៊ីឃ្លាតឆ្ងាយពីខ្លួនឡើយ គឺវាសុខចិត្តបញ្ចិះឈ្មោលវាលើខ្នង ដើរទៅរកស៊ីជាមួយគ្នា, កាលរកបានចំណីហើយ បញ្ចុកឈ្មោលឲ្យស៊ីមុន ទើបវាស៊ីក្រោយ ។ ឃើញថាគ្រាន់បើមែនទែនជាងស្ត្រីពួកខ្លះ ដែលខ្វិលគិតតែតុបតែងខ្លួន និងស៊ីចាយហ៊ុហាជិះជាន់កប្ដី បន្តិចទារអាវសំពត់ថ្មី បន្តិចទារមាសពេជ្រ

បង្អិចតារឡាន បង្អិចតារលុយស៊ីបាយមើលកុនល្ខោន ធ្វើឲ្យប្តី ឲ្យចាំស៊ីសំណូក ឲ្យចាំធ្វើការរបោម នឿយហត់កពេលឈប់ សម្រាកគ្មាន, បើតាប្តីមិនបានដូចចិត្ត រករឿងលែងលះគ្នា ទៅរកប្តីថ្មីទៀត ។ ស្ត្រីបែបនេះអន់បំផុតជាងសត្វប្រឡាំងកាស ញីទៅទៀត ។

ពួកសត្វមាន់ ក៏មានចរិយាល្អណាស់ដែរ ចេះគោរពពេលវេលាទៀងទាត់ មិនខ្ជិលដេកទម្រន់ឲ្យហួសពេលវេលាឡើយ គឺបើដល់ពេលជិតភ្លឺហើយ វាចាំស្រែករងាវដាស់មិត្រភក្តិវា និងម្ចាស់វា ឲ្យក្រោកឡើងធ្វើការងារ ។ ឃើញថាគ្រាន់បើជាងមនុស្សពួកខ្លះ ជាអ្នកដេកនិយម ល្មោភដេកច្រើន យកមុងកន្ទេលខ្នើយធ្វើពួកម៉ាក, ថ្ងៃរះពាក់កណ្តាលមេឃហើយ ក៏នៅតែបើកភ្នែកមិនរួច ទន់ប្រាយសាច់ឆ្អឹងសរសៃអស់ ក្រោកមិនបាន បណ្តាលឲ្យពេលវេលាដែលសុទ្ធតែមាសប្រាក់នោះ ធ្វើដំណើរទៅចោលអស់ ។ មនុស្សបែបនេះអន់ជាងសត្វមាន់

ទៅទៀត ។

ពួកសត្វព្រាប ក៏មានគំនិតមារយាទល្អខ្លះដែរ បើវារស់នៅក្នុងទីកន្លែងណា វាស្រឡាញ់ជាប់ចិត្តក្នុងទីកន្លែងនោះ វាចាំទិសចាំផ្លូវទៅទីកន្លែងនោះច្បាស់ ពិតប្រាកដមិនវង្វេងភ្លេច ទោះបីគេចាប់វាយកទៅលែងចោលនៅទីឆ្ងាយក៏ដោយ វាអាចហើរមករកទីកន្លែងវាបាន មិនភាន់ច្រឡំឡើយ ។ ឃើញថាគ្រាន់តាងមនុស្សពួកខ្លះ ដែលរកទីកន្លែងជ្រះសំបែងនៅពិតប្រាកដមិនបាន ចេះតែដើរអាវ៉ាសែ គ្មានអាលយដ្ឋានពិតប្រាកដ ម្តងបង់នៅភូមិស្រុកនេះ ម្តងបង់នៅភូមិស្រុកនោះ ចេះតែដើរទេសរសាត់អណ្តែតក្បែកភូមិស្រុក ដូចសំណាត់អណ្តែតទឹក តាំងពីក្មេងដល់ចាស់ រកទីភូមិឋានស្រេចការច្បាស់ណាក៏គ្មាន ។ មនុស្សបែបនេះ អន់ជាងសត្វព្រាបទៅទៀត ។

ពួកសត្វត្រដេវវ៉ិច ជាសត្វមានចរិយាល្អ២យ៉ាងគឺ១-វាមានការប្រុងប្រយ័ត្នជានិច្ច សូម្បីវាដេក ក៏យកជើងឡើងលើដែរ

ក្រែងមេឃធ្លាក់សន្ធក់ក, ៦- ជាសត្វចេះប្រុងប្រយ័ត្នថែរក្សា ស៊ុត(ពង) របស់វាជានិច្ចបក្សីទាំងអស់ ។ ឃើញថាគ្រាន់បើជាងមនុស្សពួកខ្លះ ដែលគ្មានការប្រុងប្រយ័ត្នសោះ ធ្វើការអ្វី និយាយស្តីអ្វី ចេះតែរហ៊ាំងរហេករហោករហាក ធ្វើឲ្យរួចតែពីដៃ និយាយឲ្យរួចតែពីមាត់ នាំឲ្យមានការខុសឆ្គង ក្រាំងភ្លាត់មកខូចខាតប្រយោជន៍ខ្លួននឹងប្រយោជន៍អ្នកដទៃ ។ មនុស្សបែបនេះ អន់ជាងសត្វត្រដេវវិចទៅទៀត ។

ពួកសត្វហាមរី ជាសត្វចតុប្បាទមាឌធំ ចូលចិត្តនៅទីត្រជាក់ ជិតកំហិមាល័យ វាមានចរិយាល្អណាស់ដែរ ជាសត្វចេះថែរក្សារោមកន្ទុយរបស់វា មិនឲ្យប្រឡាក់សៅហ្មងដោយធូលីអ្វីឡើយ, ទីណាដែលមានភក់ជ្រាំក្រខ្វក់ សូម្បីស្រេកទឹកឃ្លានចំណីយ៉ាងណា ក៏វាមិនចូលទៅទីនោះដែរ ។ ឃើញថាគ្រាន់បើជាងមនុស្សភាគច្រើន ដែលបណ្តោយកាយវាចាចិត្តឲ្យប្រឡាក់សៅហ្មង ដោយអំពើទុច្ចរិត អបាយមុខ មានលួចប្លន់

ស៊ីស៊ល្អកកេងកិប និងលេងល្បែងភ្នាល់ជាដើម ព្រោះតែសេចក្ដីលោភស្រេកឃ្លាន ចង់មានទ្រព្យសម្បត្តិយសសក្ដិ ចង់សប្បាយ ។ មនុស្សបែបនេះ អន់ជាងសត្វចាមរីធ្វាយណាស់ ។

ពួកសត្វជីងចក់ ក៏ជាតំរូមួយយ៉ាងល្អ វាចេះផ្លាស់ពណ៌សម្បុរទៅតាមទីកន្លែង បើវានៅក្នុងផ្ទះឈើផ្ទះស្លឹក ឬទីដែលមានពណ៌ខ្មៅ ខ្លួនវាប្រែពណ៌ខ្មៅ បើវានៅក្នុងផ្ទះថ្ម ឬទីដែលមានពណ៌ស ខ្លួនវាប្រែពណ៌ស, ជាសត្វទាន់សម័យ ចេះផ្លាស់ប្ដូររូបកាយតាមកាលៈទេសៈស្ថាន ។ឃើញថាគ្រាន់បើជាងមនុស្សពួកខ្លះ ដែលមានកាយវាចាចិត្តក្គងល្ងើយ មិនទាន់សម័យ ឬជាអ្នកទាន់សម័យហួសហេតុ គឺក្នុងកាលៈទេសៈ ឬក្នុងទីប្រជុំដែលត្រូវស្លៀកពាក់ និយាយស្ដី ឈរអង្គុយបែបនេះ ខ្លួនធ្វើបែបនោះ ខុសប្លែកពីគេ នាំឲ្យគេសើច គេត្មះតិះដៀល ។ ម្យ៉ាងទៀត ដូចអ្នកចូលទៅសេពគប់នឹងមនុស្សល្អត្រឹមត្រូវហើយ ខ្លួននៅតែធ្វើអំពើអាក្រក់ផ្ដេសផ្ដាស មិនផ្លាស់ចិត្តគំនិតតាមគេ

ណោះ ។ មនុស្សបែបនេះ អន់ជាងសត្វជីងចក់ទៅទៀត ៕

ពួកឆ្កែ ក៏វាមានចិត្តស្មោះត្រង់ ដឹងគុណណាស់ដែរ អ្នកណាដែលស្រឡាញ់វា ចិញ្ចឹមវា ឲ្យបាយវាស៊ី វាក៏ចាំមកវា គ្រាន់តែឃើញមុខអ្នកនោះ វាចេះត្បាតរមែ បក់កន្ទុយ បន្ទាបខ្លួន បន្ទន់ស្លឹកត្រចៀក ថ្ងូរសោកក្តីគោរព ស្រឡាញ់ស្មោះស្ម័គ្រអស់ពីដួងចិត្ត វាជួយឃ្វាលយកចិត្តទុកដាក់ ជួយធ្វើការថែរក្សាផ្ទះកម្មឋាន ចាប់កណ្តុរ ការពារសត្រូវមិនឲ្យបៀតបៀនបាន មិនបាច់ស្តីប្រដៅបង្ខំចិត្តប្រើឲ្យវាជួយឡើយ ៕ ហើយជាគ្រាន់បើជាងមនុស្សពួកខ្លះ ជាអកតញ្ញូ ដែលប្រមាថប្រទូសព្យាបាទស្អប់ខ្ពើម មិនចង់ចួបមុខអ្នកមានឧបការគុណរបស់ខ្លួន ដោយយកលេសផ្សេងៗមកលុបបំបាត់គុណគេចោល ។ មនុស្សបែបនេះ អន់គំរក់ជាងសត្វឆ្កែទៅទៀត ៕

ពួកសត្វស្លាបខ្លះ ដូចស្មោញប្រវឹកជាដើម វាមានសណ្តាប់ធ្នាប់ប្រសើរណាស់ ក្នុងពេលវាហោះហើរត្រដ់អាកាស មាន

របៀបរបបសណ្ដាប់ធ្នាប់ជាជួរត្រឹមត្រង់ឥតខ្ចោះ គឺវាហើររៀងរាយគ្នាតាមលំដាប់មេកោយមុនក្រោយ បណ្ដាយបន្តបន្ទាប់គ្នា មើលទៅត្រង់ក្នុងដូចបន្ទាត់ គ្មានរប៉ាត់រប៉ាយ រយីករយាក ព្រោងព្រាតប្របូកប្របល់ឡើយ ។ ឃើញថាគ្រាន់បើជាងមនុស្សពួកខ្លះ ដែលឥតសណ្ដាប់ធ្នាប់ គ្មានសុជីវធម៌ក្នុងការដើរនិងអង្គុយ ។ ការឥតសណ្ដាប់ធ្នាប់របស់ពួកនេះ សូម្បីគ្នាតែពីរបីនាក់ ក៏ដើរនិងអង្គុយមិនត្រឹមត្រង់ជួរគ្នាដែរ ចេះតែអង្គុយផ្ដេសផ្ដាស ដើរទទឹសទទាសពាសពេញផ្លូវ គ្មានចេះគោរពច្បាប់ចរាចរ, ទីកន្លែងគេមិនឲ្យដើរអង្គុយ ខ្លួនដើរអង្គុយ, កន្លែងគេឲ្យឈប់ខ្លួនដើរ កន្លែងគេឲ្យដើរខ្លួនឈប់, ផ្លូវគេឲ្យដើរទៅ ខ្លួនដើរមក ផ្លូវគេឲ្យដើរមកខ្លួនដើរទៅ ។ល។ មនុស្សបែបនេះ អន់ជាងសត្វស្មោញប្រវឹកជាដើមនោះទៅទៀត ។

ដូចនិយាយមកខាងលើនេះ បញ្ជាក់ឲ្យឃើញច្បាស់ថា ក្នុងសង្គមសត្វតិរច្ឆាន ដែលជាសង្គមអនាធិបតេយ្យ ឥតច្បាប់

ទម្លាប់សោះនោះ ក៏មានឧត្តមគតិ មានសេចក្ដីល្អខ្លះដែរ, ដូចសង្គមសត្វស្រមោច កណ្ដៀរជាដើម ជាសង្គមមានសាមគ្គីនិងសេចក្ដីព្យាយាមល្អប្រសើរ ជាងសង្គមមនុស្សខ្លះនោះដែរ ។

## ៣) សង្គមមនុស្ស

ការជួបជុំគ្នា ការរួមរួមគ្នា ការរស់នៅជាមួយគ្នាតាំងពីពីរនាក់ឡើងទៅ ហៅថាសង្គម ។ សង្គមមនុស្សជាសង្គមដ៏ប្រសើរវិសេសជាងសង្គមរុក្ខជាតិ និងសង្គមសត្វតិរច្ឆាន ព្រោះមនុស្សមានសតិបញ្ញា មានការចេះដឹង ស្គាល់ខុសត្រូវច្រើនបំផុត ជាងសត្វតិរច្ឆាន និងរុក្ខជាតិ ជាសង្គមមានច្បាប់ទម្លាប់មានអង្គការ មានបញ្ហាច្រើន ។

ពួកមនុស្សទាំងឡាយ ត្រូវការសង្គមជាចាំបាច់ជាងពួករុក្ខជាតិ និងពួកសត្វតិរច្ឆានទៅទៀត ព្រោះលោកសក្ការៈកេរ្តិ៍ឈ្មោះយសសក្តិ សេដ្ឋកិច្ច ទ្រព្យសម្បត្តិមាសប្រាក់ វឌ្ឍនធម៌ សុជីវធម៌ វប្បធម៌ សីលធម៌ អារ្យធម៌ និងចំណីអាហារ

កើតមានមកពីសង្គមនេះឯង, បើគ្មានសង្គមទេ លាភសក្ការៈជាដើមនោះ ក៏គ្មានក្នុងលោកនេះដែរ ។

## សង្គមជាប្រភពនៃលាភសក្ការៈកេរ្តិ៍ឈ្មោះ យសសក្តិ

មនុស្សណា ដែលមានចរិយាមារយាទល្អថ្លៃថ្នូរត្រឹមត្រូវមានមេត្តាករុណា ជួយទុក្ខធុរៈរាប់អានមិត្រមនុស្ស ដែលនៅរួមក្នុងគ្រួសារ ក្នុងស្រុកភូមិ ក្នុងប្រទេស ឬក្រៅប្រទេស, អ្នកដែលបានទទួលជំនួយ ទទួលការរាប់អានទាំងអស់នោះ តែងមានចិត្តស្រឡាញ់រាប់អានចែកជូនបូជាដោយលាភសក្ការៈផ្សេងៗ មានគ្រឿងឧបភោគបរិភោគ បាយទឹកនំចំណីជាដើម ចំពោះមនុស្សនោះវិញ ហើយតែងនិយាយអួតសរសើរកេរ្តិ៍ឈ្មោះ គឺគុណនៃសេចក្តីល្អរបស់មនុស្សនោះឲ្យល្បីសុះសាយទូទៅ តែងគោរពកោតក្រែងលើកតម្កើងយសសក្តិមនុស្សនោះ ឲ្យបានជាធំជាមេបា ជាមិត្រ ទុកជាទីគោរពរៀងខ្លួន ។

បើមនុស្សនោះ កើតក្រៅសង្គម នៅក្នុងទីស្ងាត់តែម្នាក់ឯង

គ្មាននរណានៅផិតទេ លាភសក្ការៈកេរ្តិ៍ឈ្មោះយសសក្តិ ក៏គ្មានដែរ, បើទុកជាមនុស្សនោះកើតមកបំរុងនឹងមានលាភសក្ការៈកេរ្តិ៍ឈ្មោះយសសក្តិធំប៉ុណ្ណា ក៏ជាមនុស្សទទេ ព្រោះគ្មាននរណាផ្តល់លាភសក្ការៈឲ្យ គ្មាននរណារាប់អានអួតសរសើរផ្សាយកេរ្តិ៍ឈ្មោះឲ្យ គ្មាននរណាគោរពកោតខ្លាចលើកតម្កើងជានាគុណភាពយសសក្តិនោះ ។ សូម្បីមនុស្សដែលកើតនៅក្នុងសង្គមហើយ ប៉ុន្តែជាអត្តទត្តបុគ្គល មានចិត្តគំនិតចរិយាមារយាទក្រៅសង្គម គិតត្រឹមតែប្រយោជន៍ផ្ទាល់ខ្លួនម្នាក់ឯងនោះ ក៏មិនអាចទទួលលាភសក្ការៈកេរ្តិ៍ឈ្មោះយសសក្តិឡើយ, បែរជាបានទទួលការនិន្ទាតិះដៀលប្រមាថមើលងាយ អំពីពួកមនុស្សទៅវិញ ។

ដូច្នេះ ពួកមនុស្សកើតក្នុងសង្គម ដែលមានសេចក្តីត្រូវការសង្គមជាចាំបាច់នោះ ត្រូវមានចិត្តគំនិតចរិយាមារយាទជាអ្នកសង្គមផង ស្រឡាញ់សង្គម ជួយលើកតម្កើងសង្គមជាចាំបាច់

ថែមទៀត គឺយើងត្រូវជួយសង្គមផង ទើបសង្គមជួយយើងបាន ។

តើត្រូវជួយសង្គមបែបណា? សង្គមជួយយើងវិញបែបណា?

ការជួយគ្នាទៅវិញទៅមកនោះយ៉ាងនេះ ៖

ក- សង្គមគ្រួសារ ជាសង្គមថ្នាក់តូច, ក្នុងសង្គមនេះមាន មាតាបិតា និងបុត្រធីតា, បើមាតាបិតាមិនបង្កើតបុត្រធីតា ឬ មិនថែរក្សា មិនជួយទំនុកបំរុងចិញ្ចឹមបុត្រធីតាឲ្យមានជីវិតរស់នៅទេ បុត្រធីតាពិតជាគ្មាន បើគ្មានបុត្រធីតាហើយ ឋានៈជាមាតាបិតានោះក៏គ្មានដែរ ។ លុះតែយើងជួយឲ្យកើតជាកូនឡើង ទើបកូនជួយយើងឲ្យកើតជាម៉ែ ឪ ដែរ។ បើមានកូនគឺងមានឋានៈជាម៉ែឪហើយ ប៉ុន្តែម៉ែឪនោះមិនជួយលើកតម្កើងកូន ឲ្យមានកេរ្តិ៍ឈ្មោះយសសក្តិ គឺមិនទំនុកបំរុងឲ្យរៀនសូត្របានចេះដឹង មានឋានៈជាសេដ្ឋីគហបតី ជាតាម៉ឺនទេ, កូននោះក៏មិនអាចជួយលើកតម្កើងម៉ែឪឲ្យថ្កើងមានឋានៈកេរ្តិ៍ឈ្មោះយសសក្តិ ជាម៉ែឪសេដ្ឋីគហបតី ជាម៉ែឪ ឯកឧត្តមដែរ ។ នេះជាការជួយសង្គម

សង្គមជួយយើងមួយបែប ។

ខ–សង្គមគ្រូនិងសិស្ស ជាសង្គមថ្នាក់កណ្ដាល, ក្នុងសង្គមនេះ មានអ្នកបង្រៀនគឺគ្រូអាចារ្យ និងអ្នករៀនគឺសិស្សនិស្សិត ។ អ្នកដែលមានចំណេះវិជ្ជា អាចធ្វើជាគ្រូអាចារ្យបាននោះ បើមិនជួយបង្ហាត់បង្រៀន ដោយយកចិត្តទុកដាក់ទំនុកបំរុងល្អមឲ្យគេរៀនពីខ្លួនកើតទេ, សិស្សនិស្សិតក៏គ្មានដែរ, បើសិស្សនិស្សិតគ្មានហើយ ឋានៈជាគ្រូអាចារ្យនោះក៏គ្មានដែរ។ ចំណែកសិស្សនិស្សិតវិញ បើមិនជួយគ្រូអាចារ្យគឺមិនយកចិត្តទុកដាក់ប្រតិបត្តិតាមដំបូន្មាន និងចំណេះវិជ្ជាដែលគ្រូអាចារ្យបង្ហាត់បង្រៀននោះទេ ឋានៈជាសិស្សនិស្សិតក៏គ្មានដែរ ។ រួមឲ្យខ្លីថា បើមានតែអ្នកបង្រៀនគ្មានអ្នករៀន ឬមានតែអ្នករៀនគ្មានអ្នកបង្រៀននោះ សង្គមគ្រូនិងសិស្សក៏គ្មានដែរ ។ នេះជាការជួយសង្គម សង្គមជួយយើងមួយបែប ។

គ– សង្គមជាតិ ជាសង្គមធំ, ក្នុងសង្គមនេះមានរាស្ត្រ

មានអ្នករាជការ ឬអ្នករដ្ឋការ ។ អ្នករាជការ ឬអ្នករដ្ឋការ ត្រូវមានសេចក្តីស្មោះត្រង់សុចរិតយុត្តិធម៌ ប្រព្រឹត្តឲ្យបានត្រឹមត្រូវតាមច្បាប់ទម្លាប់ ជួយរក្សាការពាររាស្ត្រតាមដំណើរច្បាស់ ទើបរាស្ត្រមិនក្តៅក្រហាយស្អប់ខ្ពើម មិនដកដេញចេញពីដំណែង ឬក៏មិនឲ្យកើតអនាធិបតេយ្យ ខូចសង្គមជាតិ ។ ឯពួករាស្ត្រក៏ត្រូវជួយអ្នករាជការ ឬអ្នករដ្ឋការវិញ គឺត្រូវមានចិត្តស្មោះត្រង់បង់ពន្ធអាករ តាមច្បាប់ទម្លាប់ ជួយរក្សាការពារសម្បត្តិជាតិ មិនចូលដើម ដៃ នឹងសត្រូវរបស់សង្គមជាតិ ។ ការជួយគ្នាទៅវិញទៅមកយ៉ាងនេះ ឈ្មោះថាយើងជួយសង្គម សង្គមជួយយើងវិញ ។ បើគ្មានការជួយគ្នានេះទេ គឺផ្នែកខាងរាស្ត្រគិតតែបំផ្លាញអ្នករាជការ ឬអ្នករដ្ឋការ មានការស៊ុមគ្រលុំយកសំណូកទៅសូក ឬលួចរត់ពន្ធគយជាដើម ។ ឯអ្នករាជការឬអ្នករដ្ឋការវិញ បែរជាឆ្មើងឆ្មៃ មិនចង់មើលមុខ និយាយគួរសមចំពោះរាស្ត្រដែលគ្នាមិនបានសូក មើលងាយជិះជាន់សង្កត់សង្កិន

ធ្វើបាបកស្ត្រនោះ ដូចជាខ្ញុំកញ្ជះខ្លួន ទំយកគម្រោប់តាមសម័យ អាណានិគម មកប្រើក្នុងសង្គមជាតិខ្លួន ដោយយកអំណាច ច្បាប់ដែលមហាក្សត្រ ឬប្រមុខរដ្ឋ បានប្រគល់ឲ្យមក ធ្វើជា ខែលបាំងមុខនោះ ឈ្មោះថាអាត្មាបំផ្លាញសង្គមជាតិទៅវិញ និងឈ្មោះថាយើងកំពុងជីករុសគល់របស់ខ្លួន បំផ្លាញខ្លួនយើង ផងដែរ ព្រោះបើយើងមិនជួយសង្គមហើយ សង្គមក៏ជួយយើង មិនកើតដែរ ។

## សង្គមជាប្រភពនៃសេដ្ឋកិច្ចទ្រព្យសម្បត្តិ មាសប្រាក់

ការតាំងមុខរបរទាំងឡាយ មានកសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្មជាដើម សម្រាប់យកផលធ្វើជំនួញជួញដូរ លក់ទិញ យកចំណេញគរទ្រព្យសម្បត្តិមាសប្រាក់ ជាមុខសេដ្ឋកិច្ច នោះ ធ្វើម្នាក់ឯងមិនកើតឡើយ ព្រោះគ្មានអ្នកប្រើប្រាស់ បរិភោគ គ្មានអ្នកទិញ គ្មានអ្នកលក់ គ្មានអ្នកធានាគុណភាព

គ្មានតម្លៃ, មានតែសង្គមនេះឯង ដែលអាចញុំាងសេដ្ឋកិច្ចទ្រព្យសម្បត្តិមាសប្រាក់ឲ្យកើតឡើងបាន, ដូចជាអ្នកលក់គ្រឿងឧបភោគបរិភោគ, បើគ្មានសង្គមមនុស្ស ដែលជាអ្នកត្រូវការបរិភោគប្រើប្រាស់ទេ, គ្រឿងឧបភោគបរិភោគទាំងនោះ ដូចជាដុំដីឬភក់ជ្រាំ គ្មានតម្លៃឡើយ ឲ្យគេទទេឥតយកថ្លៃក៏គ្មាននរណាត្រូវការដែរ។ បើគ្មានអ្នកដទៃត្រូវការហើយ កសិកម្មឧស្សាហកម្ម-កម្ម ពាណិជ្ជកម្មជាដើម ដែលជាមុខសេដ្ឋកិច្ចនោះក៏គ្មានដែរ គឺគ្មានរហូតដល់ទៅស្រែចំការច្បារដំណាំ គ្មានរោងឧស្សាហកម្ម គ្មានទីក្រុង គ្មានផ្សារ គ្មានកំពង់ផែ គ្មានផ្លូវគមនាគម គ្មានសម្ភារៈដឹកនាំទាំងឡាយមានរថយន្តជាដើមនិងគ្មានសង្កាត់ភូមិស្រុកខេត្តឡើយ គឺអ្វីៗសូន្យទាំងអស់ មកអំពីគ្មានសង្គមមនុស្សនេះឯង។

ម្យ៉ាងទៀតទ្រព្យសម្បត្តិ មាសពេជ្រប្រាក់កប់កោដិរបស់ពួកមហាសេដ្ឋី បើគ្មានសង្គមអ្នកក្រ ជួយធានាគុណភាព ជាតាតម្លៃទេ គឺមានតែសេដ្ឋីម្នាក់ឯង កើតឡើងក្នុងលោកនោះ គំនរ

ពុទ្ធសាសនបណ្ឌិត្យ បណ្ណាល័យ LIBRARY BUDDHIST INSTITUTE

ទ្រព្យសម្បត្តិមាសពេជ្រប្រាក់រាប់លានកោដិនោះ ដូចជាដុំដី ព្រោះគ្មានអ្នកណាត្រូវការ គ្មានអ្នកណាចាយប្រើប្រាស់ ។

ដូច្នេះឃើញសភាវៈពិតច្បាស់ហើយថា ទ្រព្យសម្បត្តិមាសពេជ្រប្រាក់ទាំងអស់ក្នុងលោកនេះ ទោះជារបស់សេដ្ឋី គហបតីក្ដី របស់ធនាគារជាតិ ក្នុងរដ្ឋនានាក្ដី ដែលមានតម្លៃប្រើប្រាស់កើត អាស្រ័យសង្គមមនុស្សត្រូវការ កើតមានឡើងដោយសង្គមមនុស្ស មានតែសង្គមមនុស្សទេ ជាម្ចាស់របស់ទ្រព្យសម្បត្តិទាំងនោះ និងជាអ្នកបង្កើតសេដ្ឋីគហបតីទាំងឡាយក្នុងលោក, ជាពិសេសសង្គមអ្នកក្រ ជាមាតាបិតារបស់សេដ្ឋីគហបតីទាំងឡាយ ព្រោះអ្នកមានកើតពីអ្នកក្រ ។ រួមសេចក្ដីឲ្យខ្លីងាយយល់ថា ពួកសេដ្ឋីគហបតី អ្នករកទ្រព្យសម្បត្តិទាំងឡាយ ជាកម្មកររបស់សង្គមអ្នកក្រ សម្រាប់ធ្វើការប្រមែប្រមូលទ្រព្យសម្បត្តិទុក កុំឲ្យរាត់រាយ, ឯតម្លៃនិងគុណភាពទ្រព្យសម្បត្តិទាំងអស់នោះ នៅក្នុងកណ្ដាប់ដៃសង្គមអ្នកក្រ អ្នកត្រូវការប្រើប្រាស់ ។

# សង្គមជាប្រភពនៃសុជីវធម៌ វឌ្ឍនធម៌ វប្បធម៌ សីលធម៌ និងអារ្យធម៌

ដូចបាននិយាយខាងដើមហើយថា សង្គមមនុស្ស ជាសង្គមធំ មានច្បាប់ទម្លាប់ មានអង្គការ មានបញ្ហាច្រើន ព្រោះមនុស្សម្នាក់ៗមានចិត្តគំនិត មានចរិយាមារយាទផ្សេងៗគ្នា ខ្លះល្អត្រឹមត្រូវ ខ្លះអាក្រក់ខិលខូច ។ អ្នកធំមានយសសក្តិ អ្នកមានទ្រព្យសម្បត្តិ នៅជិតអ្នកតូចទាល់ក្រ ឥតយសសក្តិ ឥតទ្រព្យសម្បត្តិ ឥតអំណាច នាំឲ្យមានការប៉ះទង្គិច សង្កត់សង្កិន ជិះជាន់បៀតបៀនគេ បោកលួចប្លន់កាប់សម្លាប់ បំផ្លិចបំផ្លាញគ្នា ដែលជាហេតុនាំឲ្យកើតសេចក្តីទុក្ខភ័យព្រួយ វិនាសអន្តរាយមិនបានសុខក្នុងសង្គមមនុស្ស ។

អាស្រ័យហេតុដែលមនុស្ស ខ្លាចសេចក្តីទុក្ខព្រួយវិនាសអន្តរាយនេះហើយ ទើបនាំគ្នាបង្កើតច្បាប់ទម្លាប់ឲ្យមានជាអង្គការ គឺសុជីវធម៌ វឌ្ឍនធម៌ វប្បធម៌ សីលធម៌ និងអារ្យធម៌នេះឡើង

ដើម្បីដោះស្រាយបញ្ហាសង្គមមនុស្ស ឲ្យរួចផុតពីការប៉ះទង្គិច ជិះជាន់សង្កត់សង្កិនបៀតបៀនគ្នារវាងមនុស្សនិងមនុស្ស ។

ក) ដើម្បីបំបាត់នូវសេចក្ដីទុក្ខព្រួយធុញទ្រាន់វិវាទចិត្តដែលកើតអំពីការឥតសណ្ដាប់ធ្នាប់ ឥតរបៀបរបប គ្មានការសមរម្យនោះ គេបង្កើតឲ្យមានសុជីវធម៌ឡើង សម្រាប់ទូន្មានមនុស្សឲ្យស្គាល់ហេតុផលគួរមិនគួរ, ស្គាល់ឋានៈខ្លួននិងអ្នកដទៃ, ស្គាល់ប្រមាណជីវភាព, ស្គាល់កាលសម័យ, ស្គាល់ប្រជុំជននិងទីប្រជុំ និងស្គាល់មិត្រសំឡាញ់ ។ ផ្ទុយទៅវិញ បើគ្មានសង្គមទេ គឺក្នុងលោកនេះ មានតែម្នាក់ឯងនោះ សុជីវធម៌ក៏គ្មានដែរ ព្រោះគ្មានការចាំបាច់ចំពោះសុជីវធម៌ឡើយ ។

១- ដើម្បីបំបាត់ចោលនូវហាយនភាព គឺដំណើរវិនាសអន្តរាយ ឬសេចក្ដីសាបសូន្យ ថយចុះសេចក្ដីសុខចំរើនក្នុងសង្គមដែលជាហេតុនាំឲ្យពួកមនុស្សបានជួបប្រទះ នូវសេចក្ដីទុក្ខភ័យព្រួយក្រខ្សត់នោះ គេបង្កើតឲ្យមានវឌ្ឍនធម៌ឡើង គឺនាំគ្នាទំ

បង្កើនចំនួន បង្កើនគុណភាពវត្ថុធាតុគ្រប់យ៉ាងដែលមនុស្សត្រូវការ ឲ្យចំរើនលឿនលឿនទាន់ចំនួនមនុស្ស ទាន់សេចក្ដីត្រូវការ ដូចជាខាងគ្រឿងឧបភោគបរិភោគចំណេះវិជ្ជានិងបរិយាមារយាទជាដើម នាំគ្នាបង្កើនចំនួន បង្កើនគុណភាព បង្កើនកំរិត ឲ្យរីកសាយភាយបានច្រើន បានធំទូលាយ បានល្អខ្ពង់ខ្ពស់ប្រសើរឡើង ។ បើក្នុងលោកនេះ មានតែម្នាក់ឯងគ្មានសង្គមមនុស្សទេ វឌ្ឍនធម៌ក៏គ្មានដែរ ព្រោះគ្មានការចាំបាច់ចំពោះវឌ្ឍនធម៌ ។

គ) ដើម្បីបំបាត់ចោលនូវសេចក្ដីខ្វះខាតរបស់សង្គម ដូចជាការខ្វះខាតខាងសំដីភាសាអក្សរសាស្ត្រ ទម្លាប់ទំនៀមសិល្បៈសាសនា គិតចំណេះវិជ្ជាផ្សេងៗជារបស់ជាតិ ឬអន្តរជាតិ ដែលពួកមនុស្សត្រូវការជាចាំបាច់តាមកាលៈទេសៈនោះ គេបង្កើតឲ្យមានវប្បធម៌ឡើង ញុំាងសង្គមមនុស្ស ឲ្យបានដុះដាលលូតលាស់ ទាន់សេចក្ដីត្រូវការ តាមសម័យនិយម ។ បើគ្មានសង្គមទេ វប្បធម៌ក៏គ្មានដែរ ព្រោះគ្មាននរណាត្រូវការចំពោះវប្បធម៌ ។

ឃ- ដើម្បីបំបាត់អនាធិបតេយ្យ គឺការរំលោភជិះជាន់សង្កត់សង្កិនបៀតបៀន នឹងបំបាត់ចរិយាឃោរកាចរបស់មនុស្សក្នុងសង្គម គេបង្កើតឲ្យមានសីលធម៌និងអារ្យធម៌ឡើង ដើម្បីឲ្យមានច្បាប់ទម្លាប់ មានរដ្ឋសភា មានតុលាការ មានសាសនា មានធម្មនុញ្ញ សម្រាប់ការពារសិទ្ធិសេរីភាពមនុស្ស និងអប់រំមនុស្សក្នុងសង្គមឲ្យស្គាល់ខុសត្រូវ ចេះស្រឡាញ់អំពើល្អថ្លៃថ្នូរ ភ័យខ្លាចចំពោះអំពើអាក្រក់, បង្កើតយុត្តិធម៌ក្នុងសង្គមឲ្យកើតមានឡើង ៗ បើគ្មានសង្គមទេ សីលធម៌និងអារ្យធម៌ក៏គ្មានដែរ ព្រោះគ្មាននរណាត្រូវការចំពោះសីលធម៌និងអារ្យធម៌ឡើយ ។

## សង្គមជាប្រភពនៃចំណីអាហារ

ដូចបាននិយាយខាងដើមហើយថា ពួករុក្ខជាតិ ពួកសត្វតិរច្ឆាន និងពួកមនុស្សដែលចូលចិត្តរស់នៅជួបជុំគ្នា ជាពួក ជាក្រុម ជាសង្គមនោះ គឺដើម្បីងាយរកចំណីអាហារចិញ្ចឹមជីវិតនេះឯង ៗ បើក្នុងពិភពលោកនេះមានមនុស្សតែម្នាក់ ឬមានសត្វ

តិរច្ឆានតែមួយ ឬក៏មានរុក្ខជាតិតែមួយដើមនោះ, មនុស្សនោះ សត្វនោះ រុក្ខជាតិនោះ មិនអាចរស់នៅបានឡើយ មុខជាដាច់ពោះស្លាប់ ឬងាប់ដោយគ្មានចំណីអាហារជាមិនខាន ។

ក) ពួករុក្ខជាតិជាចំណីអាហាររបស់រុក្ខជាតិ គឺពួកស្មៅឈើ វល្លិធំៗ ជាចំណីអាហាររបស់ពួកស្មៅឈើវល្លិតូចៗ, កាលបើពួកស្មៅឈើវល្លិធំៗនោះស្រូបធាតុជំរាក់ ធាតុទឹកពីក្នុងដី ពីអាកាសមកបង្កើតជាដើម មែក ស្លឹក ផ្កា ផ្លែហើយ វាជម្រុះសំបក មែក ស្លឹក ផ្កា ផ្លែនោះទៅលើផែនដី រលួយកើតជាជី ជាចំណីអាហាររបស់ស្មៅឈើវល្លិតូចៗផង ជាម្លប់បាំងផែនដីឲ្យមានធាតុទឹកត្រជាក់ស្រើមផង ការពារខ្យល់ព្យុះសង្ឃរាផង រួមកម្លាំងគ្នាស្រូបធាតុទឹកពពកពីអាកាសឲ្យកើតជាភ្លៀងផង ។ ឯស្មៅឈើវល្លិតូចៗ ក៏ជាចំណីអាហាររបស់ស្មៅឈើវល្លិធំៗវិញ មានលំនាំដូចគ្នាដែរ ។

ខ) ពួកសត្វតិរច្ឆាន ក៏ជាចំណីអាហារគ្នានឹងគ្នាដែរ គឺសត្វ

តូចៗ ជាចំណីអាហារសត្វធំៗ ដូចយ៉ាងត្រីតូចជាចំណីអាហារត្រីធំជាដើម, ឯសត្វធំៗ ក៏ជាចំណីអាហាររបស់សត្វតូចៗ ដែរ ដូចយ៉ាងដំរីក្របីគោ ជាចំណីអាហាររបស់ពពួក រុយ មូស សុច ជាដើម ។ បើមូសសុចនោះ កើតតែម្នាក់ឯងក្រៅសង្គម ពិតជាដាច់ពោះស្លាប់ ។

ក) ពួកមនុស្សជាចំណីអាហាររបស់មនុស្ស ពិតមែនតែក្នុងពិភពលោកនេះ មិនសូវកេនមនុស្ស ស៊ីសាច់មនុស្សក៏មែនហើយ ប៉ុន្តែពួកមនុស្សមានករណីយកិច្ចចាំបាច់បំផុត គឺការបង្កើតចំណីអាហារសម្រាប់មនុស្ស ។ សូមពិចារណាមើលចុះមនុស្សគ្រប់ឋានៈទាំងអស់ក្នុងលោកនេះ, មួយថ្ងៃៗមានការខ្វល់ខ្វាយតែអំពីរឿងចំណីអាហារនេះឯង ព្រោះក្នុងមួយថ្ងៃមនុស្សត្រូវការបរិភោគចំណីអាហារយ៉ាងមធ្យមបីដង, ដូចជាក្នុងពិធីបុណ្យមួយៗ ទោះបុណ្យក្នុងសាសនាក្តីក្រៅសាសនាក្តី ដែលមានការរវល់ខ្វល់ខ្វាយធំបំផុតនោះ គឺរៀបចំធ្វើចំណីអាហារ

លៀងភ្ញៀវ ឬប្រគេនព្រះសង្ឃនេះឯង ។

ដើម្បីផ្គត់ផ្គង់ចំណីអាហារឲ្យបានគ្រប់គ្រាន់តាមសេចក្ដីត្រូវការ, ពួកមនុស្សទំនាំគ្នាធ្វើស្រែចំការច្បារដំណាំ ធ្វើនេសាទ ចិញ្ចឹមសត្វ ធ្វើឧស្សាហកម្ម ពាណិជ្ជកម្ម និងធ្វើការបំរើរដ្ឋ ដែលហៅថាធ្វើការរដ្ឋការគ្រប់ៗគ្នា ដើម្បីប្ដូរផលគ្នាទៅវិញទៅមក យកចំណីអាហារចិញ្ចឹមជីវិតរៀងៗខ្លួន គឺអ្នកធ្វើស្រែចំការច្បារដំណាំ អ្នកនេសាទ និងអ្នកចិញ្ចឹមសត្វ យកផលផ្ដល់ឲ្យអ្នកធ្វើឧស្សាហកម្ម ពាណិជ្ជកម្ម និងអ្នកធ្វើការរដ្ឋការៗ យកផលប្ដូរយកចំណីអាហារអំពីអ្នកធ្វើស្រែចំការជាដើមនោះ ។ បើគ្មានសង្គមទេ ចំណីអាហារក៏គ្មាន ព្រោះគ្មានអ្នកត្រូវការចំណីអាហារ គ្មានអ្នកបង្កើតចំណីអាហារ ។

## សង្គមជាចំណីអាហាររបស់សង្គម

សម្លម្ជូរត្រកួនមួយផ្ទាំង កើតមកពីសង្គមបី គឺម្ជូរនឹងត្រកួន យកមកពីសង្គមរុក្ខជាតិ ត្រីនិងប្រហុកយកមកពីសង្គមសត្វតិរច្ឆាន

អ្នកបច្ចេកទេសខាងការផ្សំឲ្យកើតជាសម្ភ យកមកពីសង្គមមនុស្ស បើខ្វះសង្គមណាមួយ សម្ភារត្រកូនមួយផ្កាំងនោះកើតឡើងមិនបានឡើយ ។

សម្ភារត្រកូននេះ ក៏ជាចំណីអាហាររបស់សង្គមទាំងបីដែរ គឺដំបូងជាចំណីអាហាររបស់មនុស្ស, សល់ពីមនុស្ស បានជាចំណីអាហាររបស់សត្វតិរច្ឆាន មានឆ្កែជ្រូកជាដើម, សំណល់ឬលាមករបស់មនុស្សសត្វនោះ ឬក៏រូបកាយរបស់មនុស្សសត្វដែលស៊ីសម្ភារនោះស្លាប់ទៅ រលួយកើតជាជី បានជាចំណីអាហាររបស់រុក្ខជាតិ, ដល់រុក្ខជាតិដុះលូតលាស់ល្អឡើង មនុស្សសត្វយកមកធ្វើជាចំណីអាហារទៀត ចេះតែវិលកើតជាចំណីអាហារផ្តល់ឲ្យសង្គមតៗគ្នា ដូចកង់រទេះរកចុងដើមមិនឃើញ នឹងថាសង្គមរុក្ខជាតិជាចំណីអាហារ របស់សង្គមមនុស្សសត្វតិរច្ឆានក៏ថាមិនត្រូវ, នឹងថាសង្គមសត្វតិរច្ឆាន ជាចំណីអាហាររបស់សង្គមមនុស្សនិងសង្គមរុក្ខជាតិក៏ថាមិនត្រូវ, នឹងថាសង្គម

មនុស្ស ជាចំណីអាហាររបស់សង្គមសត្វតិរច្ឆាន និងសង្គមរុក្ខជាតិ ក៏ជាមិនត្រូវដែរ ព្រោះជាចំណីអាហារទាំងអស់គ្នា ជាអ្នកស៊ីចំណីអាហារនោះទាំងអស់គ្នា ។ ដើម្បីជាឲ្យត្រូវមានតែពាក្យមួយម៉ាត់ថា "សង្គមជាចំណីអាហាររបស់សង្គម ឬជាសង្គមស៊ីសង្គម" ។

ហេតុអ្វី បានជាសង្គមជាចំណីអាហាររបស់សង្គម ? សង្គមស៊ីសង្គមដូច្នេះ ?

ដូចបាននិយាយខាងដើមហើយថា សង្គមទាំងបី កើតមកពីអវិជ្ជានិងសង្ខារ ដែលប្រមូលផ្តុំផ្សំផ្គុំធាតុដី ទឹក ភ្លើង ខ្យល់ អាកាសជាធាតុកាយ ជាធាតុសុទ្ធ ឲ្យរួមចូលគ្នាជាពួកជាក្រុម ជាសង្គមនេះឯង ។

ឯធាតុដី ទឹក ភ្លើង ខ្យល់ អាកាសនោះ មានការវិលពាក់ចងប្រស្រ័យគ្នា ជាចំណីអាហារគ្នានិងគ្នាយ៉ាងណា, សង្គមទាំងបីដែលកើតឡើង អំពីធាតុដីទឹកភ្លើងខ្យល់អាកាសនោះ ក៏មាន

លំនាំវិលទាក់ទងប្រស្រ័យគ្នា ជាចំណីអាហារគ្នានិងគ្នាយ៉ាងនោះ ដែរ, គឺមានការកើតចាស់ឈឺស្លាប់ដូចគ្នា មានជីវិតដូចគ្នា ត្រូវការចំណីអាហារដូចគ្នា មានញីឈ្មោលដូចគ្នា ។ល។

សូមពិចារណាមើលចុះ ! ពួកធាតុដី ទឹក ភ្លើង ខ្យល់ អាកាសនោះ មានការកើតចាស់ ឈឺ ស្លាប់ មានជីវិត ត្រូវការចំណីអាហារ ជាចំណីអាហារគ្នានិងគ្នា មានញីឈ្មោល ។ល។ ជាធម្មតារបស់ខ្លួនស្រាប់, ដូចជាធាតុដី មានដីចាស់ ដីថ្មី ដីចាស់គឺដីកើតយូរហើយ ដីថ្មីគឺដីទើបនឹងកើត, ដីឈឺ ដីស្លាប់ គឺដី ដល់ខ្សោះ ក្រៀមរីង អស់ជីវជាតិ នឹងដីដែលពុកផុយ ហុយហើរអស់ទៅ, ដីមានជីវិត គឺដីដែលចេះតែដុះចំរើនឡើង, ដីត្រូវការចំណីអាហារ គឺដីដែលត្រូវការជីវជាតិនិងធាតុទឹក, ដីជាចំណីអាហារគ្នានិងគ្នា គឺដីជីវជាចំណីអាហាររបស់ដីឥតជីវជាតិ ដីខ្ពស់ជាចំណីអាហាររបស់ដីទាប, អាស្រ័យហេតុធាតុដីចេះស៊ីចំណីអាហារដូច្នេះ ទើបមានពាក្យចាស់ថា ចំណីដី

អាពម៌ដី, ដីញីដីឈ្មោល គឺដីដែលមានធាតុញីឈ្មោលអាស្រ័យនៅ ។ ចំណែកខាងធាតុទឹកភ្លើងខ្យល់អាកាសទៀត ក៏មានការកើត ចាស់ ឈឺ ស្លាប់ជាដើម ទំនងដូចធាតុដីដែរ ។

កាលបើអវិជ្ជាសង្ខារ ផ្សំផ្គុំធាតុដីទឹកភ្លើងខ្យល់អាកាសនេះ បង្កើតជាសង្គមហើយ ការកើតចាស់ឈឺស្លាប់ជាដើមនោះ ក៏មានសភាពកាន់តែច្បាស់ឡើងៗជាលំដាប់, ដូចជាសង្គមរុក្ខជាតិ មានឈើកើត គឺឈើទើបនឹងដុះ, ឈើចាស់គឺឈើដែលដុះយូរហើយ, ឈើឈឺ គឺឈើដែលមានរោគមានមេស៊ីមានផ្សិតវិចរួប រឹតជញ្ជក់ស្រូបរសជាតិ ធ្វើឲ្យអន់ស្វិតក្រៀម ដុះលូតលាស់មិនបានល្អ, ឈើស្លាប់ គឺឈើដាច់លែងដុះលូតលាស់តទៅទៀត, ឈើមានជីវិត គឺឈើកំពុងរស់នៅ និងមានមេឈើពូជឈើ កូនឈើ ឈើញីឈើឈ្មោល ។ល។ ឯការស្រែកឃ្លានចំណីអាហាររបស់ឈើ ក៏កាន់តែច្បាស់ឡើងៗ ជាងធាតុនៅពាក់កាយ ដែលជាធាតុដីទឹកភ្លើងខ្យល់អាកាសសុទ្ធៗនោះ ។ លុះដល់សង្គម

រុក្ខជាតិចំរើនមកជាសង្គមសត្វតិរច្ឆាន-ជាសង្គមមនុស្សហើយ ការកើតចាស់ឈឺស្លាប់ ការស្រេកឃ្លាន ភេទញីឈ្មោលជាដើមនោះ កាន់តែច្បាស់ទាំងរូបកាយ ច្បាស់ទាំងសកម្មភាព ។

បើគេបញ្ជាក់ចង់ដឹងថែមទៀតថា ហេតុអ្វីបានជាមនុស្ស សត្វនិងរុក្ខជាតិ មានការកើតចាស់ឈឺស្លាប់ ? មានជីវិត ? មានការស្រេកឃ្លាន ? មានសេចក្តីត្រូវការស៊ីជាចំណីអាហារ ? និងមានញីមានឈ្មោលនោះ ? គេអាចដឹងបានយ៉ាងងាយថា :

រូបកាយចិត្តវិញ្ញាណ របស់មនុស្សសត្វ និងរុក្ខជាតិនោះ គឺធាតុដីទឹកភ្លើងខ្យល់អាកាសនោះឯង ប៉ុន្តែត្រង់ដីទឹកភ្លើងខ្យល់អាកាសជាធាតុសុទ្ធ (Corps simple), មនុស្សសត្វនិងរុក្ខជាតិជាធាតុផ្សំ (Corps composé) ដែលសង្ខារ គឺចលនានៃធាតុបានផ្សំឡើងប៉ុណ្ណោះ ។ ហេតុដែលនាំឲ្យមនុស្សសត្វនិងរុក្ខជាតិ មានការកើតចាស់ឈឺស្លាប់ ព្រោះធាតុសុទ្ធ ដែលជាតែធាតុដើម (Matière lire) នោះ មានការកើតចាស់ឈឺស្លាប់

ដែរ ។ ហេតុដែលនាំឲ្យមនុស្សសត្វនិងរុក្ខជាតិ មានជីវិត មានការស្រេកឃ្លាន មានសេចក្តីត្រូវការស៊ីគ្នាជាចំណីអាហារនិង មានញីឈ្មោលនោះ ព្រោះធាតុសុទ្ធដែលជាវត្ថុធាតុដើម មានជីវិត មានការស្រេកឃ្លាន មានការស៊ីគ្នាជាចំណីអាហារ និង មានញីឈ្មោលដែរ ។

អាស្រ័យសភាវៈពិតបែបនេះ ទើបព្រះអរហន្តសម្ពុទ្ធ ជាអគ្គមហាទស្សនវិទូ ព្រះអង្គបានផ្តើសនិស៊ីទប្រកាសសភាវៈពិតនេះ ក្នុងចំណោមមនុស្សលោកនិងទេវតាជាច្រើនផង ដូចក្នុងព្រះសូត្រទាំងឡាយ មានសតិបដ្ឋានសូត្រជាដើម, ជាពិសេសក្នុងធាតុប្បច្ចវេក្ខណវិធី ដែលជាវិធីមួយរបស់អ្នកបួសក្នុងព្រះពុទ្ធ-សាសនា ត្រូវពិចារណាកាលពេលទទួលបរិភោគប្រើប្រាស់នូវបច្ច័យទាំង ៤ ដូចក្នុងពេលទទួលចង្ហាន់ជាដើម ឲ្យពិចារណាថា

**យថាបច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ**
**យទិទំ បិណ្ឌបាតោ តទុបភុញ្ជកោ ច បុគ្គលោ**

## ធាតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ ។

សេចក្តីថា ចង្ហាន់បិណ្ឌបាត គឺចំណីអាហារនេះ ជាធាតុដី ទឹកភ្លើងខ្យល់អាកាសពិត គ្រាន់តែប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យ, ឯរូបអាត្មាអញដែលទទួលបរិភោគនូវចង្ហាន់នេះ ក៏ជាធាតុដែរ, មិនមែនមនុស្សសត្វ មិនមែនខ្លួនប្រាណ តែងតែសោះសូន្យបាត់បង់ទៅដូចគ្នា ។

ក្នុងអត្ថបទនេះមានន័យច្បាស់លាស់ថា មនុស្សសត្វ រុក្ខ-ជាតិ និងដីទឹកភ្លើងខ្យល់អាកាសជាធាតុដូចគ្នា មិនមែនមនុស្ស-សត្វ មិនមែនខ្លួនប្រាណឡើយ ។

បើគេចង់ដឹងថា មនុស្សជាធាតុដីទឹកភ្លើងខ្យល់អាកាសមែន ឬមិនមែននោះ គេយករូបមនុស្សម្នាក់មកពិនិត្យបញ្ជាក់ការរក នឹងឃើញយ៉ាងងាយ គឺត្រង់ឆ្អឹងរឹងៗជាធាតុដី បើគេចង់ឃើញដីច្បាស់ក្តាមៗ គ្រាន់តែយកដៃស៊ុសលើស្បែកបន្តិច នឹងឃើញដីពិតៗដែលធ្លាប់ហៅថាក្អែល, ឯទឹកមាត់ទឹកសំបោរជាដើមក្នុងខ្លួន

មនុស្សនោះជាធាតុទឹក, កំដៅក្នុងខ្លួនមនុស្សដែលគេស្ទាបទៅក្តៅៗនោះជាធាតុភ្លើង, ខ្យល់ដង្ហើមចេញចូល ជាធាតុខ្យល់, ទីស្រឡះក្នុងត្រចៀកច្រមុះមាត់ជាដើមនោះជាធាតុអាកាស ។ កាលបើរូបកាយមនុស្សនោះស្លាប់ទៅ រលួយរលាយកើតជាដី ទឹកភ្លើងខ្យល់អាកាស ដែលជាធាតុសុទ្ធសូន្យដើមវិញ ។

ត្រង់ពាក្យថា មនុស្ស សត្វ រុក្ខជាតិនោះ គ្រាន់តែសន្មតហៅតាមភ្នែកឃើញ កុំឲ្យច្រឡំគ្នានឹងដីទឹកភ្លើងខ្យល់អាកាស ដែលជាធាតុសុទ្ធប៉ុណ្ណោះ ។ ដូចជាគេយកដីមកសូនធ្វើរូបមនុស្សសត្វ និងថាមនុស្សសត្វពិតៗក៏ថាមិនត្រូវ ព្រោះវាជាដី និងថាដីពិតៗក៏ថាមិនត្រូវ ព្រោះជារូបមនុស្សសត្វ ។

ត្រង់ចំណុចនេះហើយ ដែលមានន័យសំខាន់បំផុតក្នុងទ្រឹស្តីព្រះពុទ្ធសាសនា សម្រាប់មនុស្សលោក, បើមនុស្សលោកបាននឹងយល់ច្បាស់លាស់ថា មនុស្ស សត្វ ជាធាតុដីទឹកភ្លើង ខ្យល់អាកាសពិតៗមិនមែនមនុស្សសត្វ មិនមែនខ្លួនប្រាណហើយ

អស្មិមានះ គឺសេចក្តីប្រកាន់ថាអញថាយើង ថាគេនោះ ក៏គ្មានដែរ, លោភះ ទោសះ មោហះ ដែលហៅថាប្រភពនៃអំពើអាក្រក់គ្រប់យ៉ាង មានការស៊ីសំណូក លួចប្លន់កេងកិប ឈ្លោះប្រកែកកាប់ចាក់ធ្វើសង្គ្រាមសង្កត់សង្កិនជិះជាន់គ្នាទៅវិញទៅមក និងសេចក្តីស្នេហាស្រឡាញ់ស្អប់ក៏គ្មានដែរ ព្រោះដឹងស្គាល់យល់ឃើញ ពួកមនុស្សសត្វទាំងអស់ សុទ្ធតែជាធាតុដី ទឹក ភ្លើងខ្យល់ អាកាសពិតៗទៅហើយ ។ អ្នកដែលមានគំនិតយល់ឃើញច្បាស់តាមសភាវៈពិតដូច្នេះ ជាអ្នកមានប្រាជ្ញាខ្ពង់ខ្ពស់អាចបំបាត់បោលនូវការឈឺចាស់កើតស្លាប់ក្នុងលោកធាតុនេះ ទៅនៅក្នុងឋានព្រះនិព្វាន ដែលជាទីគ្មានការកើតចាស់ឈឺស្លាប់បានព្រោះឋានព្រះនិព្វាននោះ ផុតលោកធាតុ គ្មានទាក់ទងចំពោះធាតុដីទឹកភ្លើងខ្យល់ អាកាសជាតួអវិជ្ជាសង្ខារឡើយ ។

ឯពាក្យថាមនុស្សលោក ដែលអ្នកនិពន្ធខ្ញុំ សន្មត់ឲ្យជាឈ្មោះសៀវភៅនេះ ក៏គ្មានក្នុងឋានព្រះនិព្វាននោះដែរ ព្រោះ

មនុស្សលោកកើតមានតែក្នុងលោកធាតុនេះឯង ។

## អំពីឋាននិព្វាន និងលោកធាតុ

ពាក្យចាស់ពីរម៉ាត់នេះ នាំឲ្យមានបញ្ហាចោទឡើងថា៖ ហេតុអ្វីមនុស្សលោកគ្មានក្នុងឋាននិព្វាន មានតែក្នុងលោកធាតុ? ឋាននិព្វាន និងលោកធាតុនោះនៅឯណា? បានជាមិនឃើញមានក្នុងផែនទីភូមិសាស្ត្រពិភពលោកសព្វថ្ងៃនេះសោះ!

បានជាមនុស្សលោក គ្មានក្នុងឋាននិព្វាននោះ ព្រោះមនុស្សលោកកើតមកពីធាតុ ដី ទឹក ភ្លើង ខ្យល់ អាកាស រស់នៅបានដោយធាតុដី ទឹក ភ្លើង ខ្យល់ អាកាស ។ ឯឋាននិព្វាននោះគ្មានធាតុដី ទឹក ភ្លើង ខ្យល់ អាកាសឡើយ, អាស្រ័យហេតុនេះទើបមនុស្សលោក កើតមានតែក្នុងលោកធាតុប៉ុណ្ណោះ ។ ដូចជាសត្វត្រីកើតមានរស់នៅតែក្នុងទឹក មិនដែលកើតមានរស់នៅលើគោកឡើយ ។

ឯឋាននិព្វាននោះជាទីប្រសើរវិសេស មាននៅក្រៅលោក-

ធាតុ សម្រាប់ផលញាណនៃព្រះខីណាស្រពអាស្រ័យនៅ ។

លោកធាតុ ក៏ជាឈ្មោះទីឋានដែរ គឺជាឈ្មោះទំហំលោក ក្នុងមណ្ឌលចក្រវាឡមួយៗ សម្រាប់មនុស្សសត្វនរកប្រេត ទេព្ដា មារព្រហ្មអាស្រ័យនៅ ។

ក្នុងផ្ទៃលោកដែលធំល្ហល្ហេវរកដើមមេឃមិនឃើញនេះ មានលោកធាតុ ឬចក្រវាឡច្រើនរាប់អនេកអនន្តរាប់មិនអស់, ក្នុងលោកធាតុមួយៗ គឺក្នុងចក្រវាឡមួយៗនោះ មានទ្វីបធំទ្វីបតូច មានភ្នំ មានស្ថានសួគ៌ ស្ថានព្រហ្ម ស្ថានមនុស្ស ស្ថាននរកប្រេត មានព្រះអាទិត្យ ព្រះចន្ទ ផ្កាយ មានទន្លេ សមុទ្រ, រួមសម្ភារៈលោកទាំងអស់នេះមួយក្រុមៗ ហៅថាលោកធាតុមួយឬចក្រវាឡមួយ ។ រួមលោកធាតុ ឬចក្រវាឡដែលមានរាប់មិនអស់នោះ ឈ្មោះថា ឱកាសលោក ប្រែថាទីវាលសម្រាប់សត្វលោកអាស្រ័យនៅ, ឱកាសលោកនេះ គឺគេហៅដោយសង្ខេបថា មហាសមុទ្រធាតុដូច្នេះក៏បាន ព្រោះក្នុងទីវាលដ៏ធំល្ហល្ហេវរកដើម

ទេយមិនឃើញនេះ ពេញព្រៀបទៅដោយធាតុ ដី ទឹក ភ្លើង ខ្យល់ អាកាស ។

ហេតុដែលឋាននិព្វានគឺផុតលោកធាតុមិនឃើញមានក្នុងផែនទីភូមិសាស្ត្រសាកលលោក ដែលអ្នកភូមិសាស្ត្រគូរសព្វថ្ងៃនេះ ព្រោះគេគូរតែត្រឹមឋានមនុស្សមួយ ដែលខ្លួនគេបានស្គាល់ប៉ុណ្ណោះ មិនបានគូរផែនទីគ្រប់ឋាន ទាំងអស់ក្នុងលោកធាតុមួយឡើយ គឺគេមិនទាន់ចេះគូរផែនទីលោកធាតុសាស្ត្រទេ គេចេះគូរតែត្រឹមផែនទីភូមិសាស្ត្រប៉ុណ្ណោះ ព្រោះអ្នកវិទ្យាសាស្ត្រសព្វថ្ងៃ គ្មានមធ្យោបាយទៅឲ្យបានដល់លោកធាតុឡើយ គេកំពុងតែខំទៅ ស្ថានព្រះចន្ទមួយបានដោយលំបាក ។

ឯឋាននិព្វាននោះ ទោះដល់ទៅសម័យវិទ្យាសាស្ត្រចំរើនផុតលេខហើយ ក៏មិនអាចដឹងមិនអាចគូរជាផែនទីបានឡើយ ព្រោះជាឋាននៅក្រៅលោកធាតុ ក្រៅឧកាសលោក ។

ចំពោះឋាននិព្វាននេះ មានមតិខ្លះយល់ថា គ្មានទេ ព្រោះ

ចិត្តជាអរូប ឯចិត្តនោះត្រូវចម្រាញ់ដោយសោឡសកិច្ចទាំង១៦ ឲ្យកើតជាផលញ្ញាណទៀត គឺចម្រាញ់ចិត្តដែលនៅគ្រោតគ្រាតជាប់ធាតុ ដី ទឹក ភ្លើង ខ្យល់ អាកាសនោះ ឲ្យស្ងួតខ្សោះអស់ធាតុដើម ។ ផលញ្ញាណនោះ ឈប់កើតជាស់ឈើស្លាប់ហើយ គឺសូន្យ បាត់តែម្ដង គ្មានការចាំបាច់ចំពោះទីស្ថានឡើយ ។ បានសេចក្ដីថាព្រះនិព្វានដូចជាឡវិសេសមួយសម្រាប់ដុតកម្ទេចចិត្តវិញ្ញាណចោល ឲ្យចប់ពូជចិត្តវិញ្ញាណ មនុស្សសត្វមួយ ៗ ត្រឹមនោះ ។

មតិនេះប្រហែលមានសំអាងចំពោះពុទ្ធភាសិតថា "**អច្ចិ យថា វាតវេគេន ខិត្តំ អត្ថំ បលេតិ ន ឧបេតិ សង្ខំ ។ ឯវំ មុនី នាមកាយា វិមុត្តោ អត្ថំ បលេតិ ន ឧបេតិ សង្ខំ ។**" ដែលប្រែថាអណ្ដាតភ្លើង ត្រូវខ្យល់បក់រលត់ទៅហើយ មិនប្រាកដថាអណ្ដាតភ្លើងនោះទៅនៅទីណា យ៉ាងណា ។ មុនីគឺព្រះខីណាស្រព ដែល

លះបង់នាមកាយ(សុគតហើយ) ក៏រមែងមិនប្រាកដថា ទៅនៅទីណា យ៉ាងនោះដែរ ។

ក្នុងពុទ្ធភាសិតនេះ ក៏មិនមែនបាត់សេចក្ដីថា សូន្យគ្មានអ្វីសោះដែរ គ្រាន់តែថាចិត្តព្រះទីណាស្រេចនោះ មិនប្រាកដជានៅទីណា, ឯទីស្ថាននោះពិតជាមាន ទើបមានពាក្យថា «មិនប្រាកដទីណា» ព្រោះជាអលោកធាតុ ។ ដូចជាអណ្ដាតភ្លើងដែលរលត់ទៅ, អណ្ដាតភ្លើងនោះពិតជានៅមាន ប៉ុន្តែមិនដឹងមាននៅទីណាឲ្យប្រាកដ ព្រោះអណ្ដាតភ្លើងនោះលះបង់ ពណ៌ក្លិន និងកំដៅអស់ហើយ ។

មតិខ្លះទៀតយល់ថា ឋាននិព្វាន មាននៅក្នុងលោកនេះឯង បើបុគ្គលណាបានសម្រេចព្រះនិព្វានហើយ ចិត្តបុគ្គលនោះឈប់ចាប់ជាតិ ជាមនុស្ស សត្វ ទេពតា មារព្រហ្មទៀតហើយ ព្រោះអស់ហេតុបច្ច័យ, ការមិនកើតទៀតនាំឲ្យបានសុខស្ងប់ ព្រោះគ្មានការចាស់ ឈឺ ស្លាប់, ចិត្តនោះចេះតែអណ្ដែតសប្បាយ

តាមអាកាសដូចធូលី ។

មតិមួយបែបផ្សេងទៀត យល់ថាព្រះនិព្វានគ្រាន់តែជាឈ្មោះរបស់ចិត្តដែលស្ងប់ ឬឈ្មោះធម៌ដែលនាំឲ្យចិត្តស្ងប់, ឯសេចក្ដីស្ងប់នោះ មិនមែនសេចក្ដីស្ងប់ធម្មតា ដែលមនុស្សធ្លាប់ស្គាល់ជួបប្រទះក្នុងពេលខ្លះ ហើយបាត់បង់ទៅវិញនោះទេ គឺជាសេចក្ដីស្ងប់ទៀងទាត់ប្រាសចាកហេតុបច្ច័យ ។ វត្ថុណាដែលមានហេតុបច្ច័យតាក់តែងកាលណាអស់ហេតុបច្ច័យហើយ, វត្ថុនោះរមែងចូលទៅនៅក្នុងសេចក្ដីស្ងប់ស្ងាត់របស់លោកធាតុ ឬបក្កព់ឡនេះឯង ។

មតិទាំងអស់នេះ អ្នកនិពន្ធ មិនបានបដិសេធថាខុសទេ ហើយក៏មិនបានយល់ស្របថាពិតជាត្រឹមត្រូវផងដែរ ព្រោះហេតុនិងផលមិនសូវស្របគ្នា ។

សូមមិត្រអ្នកអានទាំងឡាយ ពិនិត្យរកសេចក្ដីពិតក្នុងរឿងព្រះនិព្វាននេះដោយយកចិត្តទុកដាក់កុំខាន ព្រោះជាបញ្ហាជីវិត

ពិតៗ, បើបានពិនិត្យរកសេចក្តីពិតក្នុងរឿងព្រះនិព្វាននេះឃើញ ហើយ គប្បីតម្រង់ដំណើរជីវិតឲ្យប្រព្រឹត្តទៅចំពោះនិព្វាននោះកុំខាន កុំបណ្តោយឲ្យជីវិតសាត់អណ្តែតសាវ៉ា ស្លាប់ដូចពស់រស់ដូចកង្កែបនោះឡើយ, ឯសេចក្តីសុខចំរើន ដែលមនុស្សលោកបានទទួលខ្លះៗក្នុងលោកនេះ ដូចជាសីលធម៌ អារ្យធម៌ វប្បធម៌ និងមនុស្សធម៌ជាដើមនោះ គឺជាកម្មរស្មីផ្សាយចេញមកពីព្រះនិព្វាននោះឯង, ប៉ុន្តែមនុស្សលោកយល់ច្រឡំអស់ទាំងទ្វីប ថាព្រះនិព្វាន គឺសេចក្តីស្លាប់ជារបស់ខ្មោច មានប្រយោជន៍តែក្នុងស្រុកខ្មោច ជារឿងដោយឡែក សម្រាប់និយាយក្នុងវត្តអារាម សម្រាប់អ្នកបួស និងសម្រាប់មនុស្សចាស់ៗជិតស្លាប់ ដែលខ្សោះហើយចូលវត្តលោកសង្ឃ ជាពិសេសគេថា សម្រាប់មនុស្សល្ងង់ មនុស្សខ្ជិល មិនមែនជាបញ្ហារបស់រដ្ឋ របស់អ្នកក្រុង របស់អ្នកពិភពលោកឡើយ ។ ឯការពិតនោះព្រះនិព្វាន គឺជាវត្ថុបំណងធំបំផុតរបស់អ្នកពិភពលោកផ្ទាល់តែម្តង ដូចសម្តែង

ស្រែកឃ្លានរបស់អ្នកពិភពលោកសព្វថ្ងៃ ដែលនាំគ្នាទាំងស្រែកច្រហឹងពេញលោកថា សន្តិភាព សន្តិភាព (La paix La paix) នោះ តើអ្វីនាំឲ្យគេនិយាយភាសានេះ? គឺកម្មរស្មីដែលផ្សាយចេញពីព្រះនិព្វានពិតៗ នាំឲ្យគេភាសានេះ ក្រៅពីព្រះនិព្វានចេញគ្មានភាសានេះឡើយ ។

ដើម្បីឲ្យបានយល់ខ្លះដោយល្អៈភាសន្នអំពីរឿងព្រះនិព្វាន គឺឲ្យគ្រាន់តែដឹងថានិព្វាននោះវិសេសយ៉ាងណា? មានការពិតបែបណា? សូមត្រិះរិះពិចារណាតាមអត្ថបទដូចតទៅនេះ ។

ជាបឋម សូមលើកយកពាក្យបីម៉ាត់ មកធ្វើជាប្រធាន ដើម្បីវែកញែកឲ្យងាយយល់គឺ៖

**ក–និព្វាន,**

**ខ–អ្នកនិព្វាន,**

**គ–ឋាននិព្វាន ។**

ពាក្យទាំងបីម៉ាត់នេះ បើមិនបានជាគិត ច្រើនច្រឡំឈ្មោះ

ធម៌ ឈ្មោះបុគ្គលនិងឈ្មោះទីឋាន, ការច្រឡំនេះឯងតែងឲ្យមានការយកស្រាយខុសរឿងព្រះនិព្វាន ។

ក) និព្វាន ឬព្រះនិព្វាន ជាឈ្មោះធម៌ គឺឈ្មោះលោកុត្តរធម៌ទី៩ (មគ្គ៤ផល៤ និព្វាន១) ជាបរមត្ថធម៌ជាន់ខ្ពស់បំផុតក្នុងទ្រឹស្តីពុទ្ធសាសនា, មាន២គឺ:

១-កិលេសនិព្វាន ធម៌រំលត់កិលេស គឺរំលត់លោភៈ ទោសៈ មោហៈ ជាដើម ។

២-ខន្ធនិព្វាន ធម៌រំលត់ខន្ធ៥គឺរំលត់រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ។

ខ) អ្នកនិព្វាន ជាឈ្មោះបុគ្គលដែលបានសម្រេចនូវនិព្វានធម៌, មាន២ដែរគឺ:

១-ព្រះអរិយៈ ជាសេខបុគ្គល រាប់ពីសោតាបន្នៈឡើងទៅ ដែលលោកបានសម្រេចនូវកិលេសនិព្វាន ។

២- ព្រះខីណាស្រព ជាអសេខបុគ្គល ដែលលោកបាន

សម្រេចនូវខន្ធនិព្វាន ។

ចំណែកខាងអ្នកពិភពលោក និងពុទ្ធបរិស័ទទាំងឡាយជាបុថុជ្ជនដែលកំពុងស្វែងរកសន្តិភាព កំពុងបួសរៀន ក្តីមានសីលភាវនាសព្វថ្ងៃនេះ ក៏ឈ្មោះថាអ្នកនិព្វាន បានដោយសន្មតដែរ ព្រោះមានចំណងដើម្បីសន្តិភាព ដើម្បីនិព្វាន ។

ក) ឋាននិព្វាន ទីលំនៅរបស់អ្នកនិព្វាន, មាន២ដែរគឺ:

១- លោកធាតុ បានដល់ពិភពលោកនេះ គឺកាមភព រូបភព អរូបភព ជាទីលំនៅរបស់អ្នកបានសម្រេចកិលេសនិព្វាន គឺថាបើលោកបានសម្រេចមគ្គផល ក្នុងស្ថានមនុស្ស ស្ថានទេវតា ឬស្ថានព្រហ្ម លោកស្ថិតនៅទីនោះៗសិន ព្រោះក៏រឹតកាលនៃកិលេសតណ្ហា និងអាយុសង្ខារលោកមិនទាន់អស់មិនទាន់ដល់។ ឯព្រះអរិយបុគ្គល ដែលលោកបានសម្រេចកិលេសនិព្វាននេះ លោកទៅចាប់ជាតិកើតក្នុងទេវលោកមនុស្សលោក ព្រហ្មលោកនេះ ១ជាតិ ២ជាតិ ៣ជាតិ រហូតដល់៧ជាតិទៀត តាមនិស្ស័យ

វាសនារបស់លោក ទើបសម្រេចនូវនិព្វានក៏បាន ។

២- អលោកធាតុ ឬនិព្វានដ្ឋាន ទីស្ថានវិសេស មិនពាក់ទង់ចំពោះធាតុ ដី ទឹក ភ្លើង ខ្យល់ អាកាស ដែលជាទីទួល អវិជ្ជាសង្ខារ, ជាទីលំនៅរបស់ផលញាណនៃព្រះខីណាស្រពទាំងឡាយ ដែលលោកបានសម្រេចនូវនិព្វានហើយ ។

និព្វានដ្ឋាននេះ មាននៅក្រៅលោកធាតុក្រៅឧកាសលោក គឺទីស្ថានណាដែលគ្មានឈ្មោះថាលោកធាតុ ថាឧកាសលោក ទីស្ថាននោះឯងឈ្មោះនិព្វានដ្ឋាន គឺឋាននិព្វាន ។ ព្រោះចិត្តវិញ្ញាណមានជាន់ថ្នាក់, ឯទីស្ថានសម្រាប់ចិត្តវិញ្ញាណអាស្រ័យនៅ ក៏មានជាន់ថ្នាក់ដែរ ។ ដូចជាចិត្តវិញ្ញាណថ្នាក់មនុស្សសត្វ ត្រូវកើតអាស្រ័យនៅ ឋានមនុស្ស, ចិត្តវិញ្ញាណថ្នាក់ទេវតា ព្រហ្មមានរូបឥតរូប ត្រូវកើតអាស្រ័យនៅ ឋានទេវតា ឋានព្រហ្មមានរូបឥតរូប, ចិត្តវិញ្ញាណថ្នាក់និព្វានដែលជាថ្នាក់ខ្ពស់បំផុត កំចាត់បង់អវិជ្ជាសង្ខារអស់ហើយ ត្រូវអាស្រ័យ

ពុទ្ធសាសនបណ្ឌិត្យ
បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

នៅក្នុងឋាននិរ្យាន ដែលមាននៅក្រៅលោកធាតុ ក្រៅឱកាសលោក ។

ឯទីតាំងក្រៅឱកាសលោកនេះ ពិតជាមាន ព្រោះមានពុទ្ធភាសិតមួយឃ្លាក្នុងគម្ពីរទីឃនិកាយ ត្រង់មហាបទានសូត្រ ដែលព្រះអរហន្តសម្ពុទ្ធបរមគ្រូ សំដែងអំពីប្រវត្តិរបស់ព្រះពុទ្ធវិបស្សី ត្រង់សេចក្ដីអស្ចារ្យនៅពេលចុះចាប់បដិសន្ធិក្នុងផ្ទៃព្រះនាងពន្ធុមតី ជាពុទ្ធមាតានោះថា

**"យាបិ តា លោកន្តរិកា អឃា អសំវុតា អន្ធការា តិមិសា យត្ថបិមេ ចន្ទិមសុរិយា ឯវំ-មហិទ្ធិកា ឯវំមហានុភាវា អាភាយ នានុភោន្តិ តត្ថបិ អប្បមាណោ ឧឡារោ ឱភាសោ បាតុភវតិ អតិក្កម្មេវ ទេវានំ ទេវានុភាវំ។**

ប្រែថា ទីណាដែលធំហាងទទេ នៅក្នុងទីបំផុតនៃលោក ឥតមានអ្វីបាំងរាំង មានតែងងឹតសូន្យសុង, សូម្បីព្រះអាទិត្យ

ព្រះចន្ទ ដែលមានឫទ្ធិមានអានុភាពច្រើនយ៉ាងនេះ ក៏ផ្សាយពន្លឺទៅមិនដល់ក្នុងទីណា ពន្លឺភ្លឺស្វាងច្បាស់រកប្រមាណមិនបាន (ក្នុងពេលព្រះវិបស្សីពោធិសត្វចុះចាប់បដិសន្ធិនោះ) កន្លងនូវទេវានុភាពនៃទេវតាទាំងឡាយ ក៏កើតប្រាកដឡើងក្នុងទីនោះ ។

ត្រង់ពាក្យថា „ទីដែលចំហទទេ នៅទីបំផុតលោក„ នេះឯង ជាសក្ខីភាពមួយនៃការដឹងថា ទីនោះ គឺទីក្រៅលោកធាតុ ក្រៅឱកាសលោក ព្រោះមានពាក្យថា „ទីចំហទទេ„ និងមានពាក្យថា „នៅទីបំផុតលោក" ទៀត គឺមិនមែនទីចំហទទេ ក្នុងលោកធាតុ ក្នុងឱកាសលោកនេះឡើយ ។ ពាក្យថា „ទីបំផុតលោក„ នេះ បើនិយាយអំពីធម៌ សំដៅយកទីបំផុតនៃកាមគុណ៥ ឬទីបំផុតនៃកិលេសតណ្ហា, បើនិយាយអំពីទីឋាន សំដៅយកទីបំផុតភព ទីបំផុតលោកធាតុ ។

ត្រង់ចំណុចថា „មានទីក្រៅឱកាសលោក និងមានឋាននិព្វាននៅក្រៅឱកាសលោក„នេះ ប្រហែលមិនត្រូវអ្នកអានភាគច្រើន

មិនធ្លាប់គិតថា មានទេដឹង? ធ្លាប់តែយល់ថា „អាកាសោ អនន្តោ អាកាសគ្មានទីបំផុត„ នេះឬ? តើអាកាសនិងឱកាស-លោកដូចគ្នាឬផ្សេងគ្នា? សូមវិនិច្ឆ័យចុះ ។

មតិថា ឋាននិព្វាន មាននៅក្រៅលោកធាតុ ក្រៅឱកាស-លោកនេះ មិនមែនជាមតិថ្មីចេញមកពីអ្នកនិពន្ធខ្ញុំទេ គឺជាមតិចាស់ គំនិតចាស់ របស់អ្នកប្រាជ្ញទាំងឡាយ ពីបុរាណកាលមក ប្រកបដោយហេតុផលត្រឹមត្រូវ, ខ្ញុំគ្រាន់តែបញ្ជាក់ឲ្យរឹតតែច្បាស់ថែមទៀតប៉ុណ្ណោះ ។

ក្នុងដីកាអភិធម្ម មានពាក្យថា **„លោកន្តំ និព្វានំ ភវន្តំ និព្វានំ„** ប្រែថា ឋាននិព្វាន ឋិតនៅទីបំផុតលោក ទីបំផុតភព ។ ពាក្យថា „លោក-ភព„នេះ មាននៅក្នុងលោកធាតុ ក្នុងឱកាសលោក, ពាក្យថា „ទីបំផុត„ ដូចធ្លាប់ជម្រាបស្រាប់ហើយ បានសេចក្ដីថា ក្រៅដោយឡែកចាក គឺក្រៅដោយឡែកចាកលោក ចាកភព ។ នេះជាហេតុផលមួយ

សឲ្យឃើញថា ឋាននិព្វាន ពិតជានៅក្រៅឱកាសលោក មិនទាក់ទងនឹងធាតុ ទឹក ដី ភ្លើង ខ្យល់ ឡើយ, ស្របនឹងពុទ្ធភាសិតក្នុងកេវដ្ដសូត្រថា „ **ឯត្ថ អាបោ ច បឋវី ច តេជោ វាយោ ន គាធតិ„** ប្រែថា ធាតុ ទឹក ដី ភ្លើង ខ្យល់ មិនតាំងនៅក្នុងឋាននិព្វាននុ៎ះឡើយ ។

ក្នុងអនុដីកាអភិធម្ម ដែលពន្យល់អំពីពាក្យថា „លោកុត្តរចិត្ត„ នោះ មានចងបទវិគ្គហៈពន្យល់ថា **កាមរូបារូបសំ-ខាតលោកតោ ឧត្តរតិ តតោ វា សត្ត ឧត្តិណ្ណ និយ្យាន តារវដ្ដិតិ លោកុត្តរំ** ប្រែថា មគ្គញាណឯណា បានឆ្លងផុតចាកកាមលោក រូបលោក អរូបលោក មគ្គញាណនោះ ឈ្មោះលោកុត្តរៈ, មួយទៀតផលញ្ញាណឯណា ញុំាងសត្វទាំងឡាយឲ្យឆ្លងទៅកាន់ឋាននិព្វាន ជាខាងលើចាកលោកទាំងបី ផលញ្ញាណនោះ ឈ្មោះលោកុត្តរៈ ។

អត្ថាធិប្បាយនេះរឹតតែមានហេតុផលច្បាស់ថែមទៀត

បានតាំងប្រាប់ថា ឋាននិព្វាន ស្ថិតនៅទីបំផុតកំពូលខាងលើៗ ឯពាក្យថាខាងលើ ឬខាងក្រោមនោះមិនជាការចាំបាច់អ្វីទេ ទោះជាទិសខាងណាក៏ដោយ ឲ្យតែទីនោះស្ថិតនៅក្រៅលោកធាតុ ក្រៅឧកាសលោកហើយ ឈ្មោះថាឋាននិព្វានទាំងអស់ ។ បានជាថាដូច្នេះ ព្រោះពាក្យថាលើក្រោមនេះ ជាពាក្យគ្មានខណ្ឌចប់ទេ, ដូចជាអ្នកនៅស្ថានមនុស្ស មើលឃើញព្រះអាទិត្យព្រះចន្ទ ឃើញផ្កាយ ថានៅខាងលើខ្ពស់, អ្នកនៅក្នុងស្ថានព្រះចន្ទជាដើម នោះមើលឃើញពិភពផែនទៀត ថានៅខាងលើខ្ពស់ទៀត ទេះតែមានលើមិនចប់, កាលបើមានលើមិនចប់ហើយ ពាក្យថាមានក្រោមក៏មិនចប់ដែរ ព្រោះឧកាសលោក គឺទីវាល សម្រាប់សត្វលោកនៅអាស្រ័យនេះ ធំណាស់គ្មានដើងមេឃឡើយ ។

បើឧកាសលោក ដែលជាមហាសមុទ្រនៃធាតុ ធំពេកគ្មានដើងមេឃសោះយ៉ាងនេះ ហេតុអ្វីក៏ហៅថា ឋាននិព្វានមាននៅក្រៅឧកាសលោកនោះ? តើត្រង់ទីណាទៅ ដែលហៅថាក្រៅ?

បញ្ហានេះមិនពិបាកដោះស្រាយឡើយ តាមគម្មតាលោកសច្ចៈ តែមានទុក្ខពិតជាមានសុខ, មានអាក្រក់ពិតជាមានល្អ, មានធំពិតជាមានតូច, មានក្នុងពិតជាមានក្រៅ, មានទីដែលមានធាតុ ពិតជាមានទីដែលគ្មានធាតុ ។ល។ អាស្រ័យហេតុនេះ ពាក្យថា ឋាននិព្វាន មាននៅក្រៅលោកធាតុ ក្រៅឱកាសលោកនេះជាពាក្យពិត ព្រោះមានពាក្យថា "មានលោកធាតុ ថាមានឱកាសលោក" ពិតហើយ ។

ឯពាក្យថា ក្រៅឱកាសលោកនៅត្រង់ទីណានោះ គឺនៅត្រង់ទីបំផុតនៃព្រំប្រទល់ឱកាសលោកសីមានោះឯង, ដូចជាគេសួរថា ទឹកដីបរទេសនៅត្រង់ទីណា? យើងអាចឆ្លើយថា នៅត្រង់ទីបំផុតនៃព្រំប្រទល់រដ្ឋសីមា ។

អំពីរឿងឋាននិព្វានស្ថិតនៅក្រៅឱកាសលោកនេះ នៅមានពុទ្ធភាសិតច្រើនទៀតជាភស្តុតាង, ដូចពុទ្ធភាសិត មានក្នុងគម្ពីរអង្គុត្តរនិកាយ នវកនិបាត សុត្តន្តបិដក ត្រង់មហាវគ្គថា :

បុន ចបរំ ព្រាហ្មណា ភិក្ខុ សព្វសោ នេវសញ្ញានាសញ្ញាយតនំសមតិក្កម្ម សញ្ញា-វេទយិតនិរោធំ ឧបសម្បជ្ជ វិហរតិ ។ បញ្ញា-យស្ស ទិស្វា អាសវា បរិក្ខីណា ហោន្តិ ។ អយំ វុច្ចតិ ព្រាហ្មណា ភិក្ខុ លោកស្ស អន្តមគមា លោកស្ស អន្តេ វិហរតិ តិណ្ណោ លោកេ វិសត្តិកន្តិ ។

ប្រែថា ម្នាលព្រាហ្មណ៍ទាំងឡាយ មួយទៀតភិក្ខុព្រោះកន្លងបង់ នេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់នូវសញ្ញាវេទយិតនិរោធ ។ អាសវៈរបស់ភិក្ខុនោះ ក៏អស់រលីងទៅ ព្រោះយល់ឃើញដោយប្រាជ្ញា ។ ម្នាលព្រាហ្មណ៍ទាំងឡាយ ភិក្ខុនេះ តថាគតហៅថា បានដល់ទីបំផុតនៃលោក ឋិតនៅក្នុងទីបំផុតនៃលោក បានឆ្លងផុតនូវតណ្ហាក្នុងលោកហើយ ។

ពុទ្ធភាសិតមួយទៀត ក្រាបបញ្ចប់ហើយផ្សាស់ថា ព្រះ

និព្វាន មានអាយតនៈដែលដាល់នៅដែនកើត, ពុទ្ធភាសិតថា

អត្ថិ ភិក្ខវេ តទាយតនំ ។ យត្ថ នេវ បឋវី ន អាបោ ន តេជោ ន វាយោ ន អាកាសានញ្ចាយតនំ ន វិញ្ញាណញ្ចាយតនំ ន អាកិញ្ចញ្ញាយតនំ ន នេវសញ្ញានាសញ្ញាយតនំ ។ នាយំ លោកោ ន បរលោកោ ឧភោ ចន្ទិមសុរិយា ។ តត្រាបាហំ ភិក្ខវេ នេវ អាគតិំ វទាមិ ន គតី ន ឋិតី ន ចុតិ ន ឧប្បត្តិ ។ អប្បតិដ្ឋំ អប្បវត្តំ អនារម្មណមេវេតំ ។ ឯសេវន្តោ ទុក្ខស្ស ។

ប្រែថា ម្នាលភិក្ខុទាំងឡាយ អាយតនៈនោះមានក្នុងព្រះនិព្វាន ។ ក្នុងអាយតនៈនោះ មិនមានធាតុ ដី ទឹក ភ្លើង ខ្យល់ មិនមែនជាអាកាសានញ្ចាយតនៈ វិញ្ញាណញ្ចាយតនៈ អាកិញ្ចញ្ញាយតនៈ ធីងមិនមែននេវសញ្ញានាសញ្ញាយតនៈឡើយ ។

អាយតនៈក្នុងលោកនេះក៏មិនមែន ក្នុងលោកដទៃក៏មិនមែន ក្នុងលោកព្រះចន្ទព្រះអាទិត្យទាំងពីរនេះក៏មិនមែនដែរ ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនសំដែងនូវអាយតនៈនោះថា ជាការទៅមក ជាការស្ថិតនៅ ជាការច្យុតិកើត ។ អាយតនៈនោះមិនមានទីតាំងនៅ មិនមានការប្រព្រឹត្តិទៅ មិនមានអារម្មណ៍ ។ នេះឯងជាទីបំផុតទុក្ខ ។

ក្នុងពុទ្ធភាសិតនេះមានពាក្យថា អាយតនៈ ដែលប្រែថា លំនៅឬដែនកើត ក្នុងលំនៅឬដែនកើតនោះ គ្មានធាតុដី ទឹក ភ្លើង ខ្យល់ទេ មិនមែនស្ថានព្រហ្មមានរូបអរូប ដែលមានឈ្មោះថា អាកាសានញ្ចាយតនៈជាដើមនោះទេ ។ ព្រះអង្គបានបញ្ជាក់ទៀតថា ជាដែនកើតក្នុងលោកនេះក៏មិនមែន ក្នុងលោកដទៃក៏មិនមែន ក្នុងលោកព្រះចន្ទព្រះអាទិត្យក៏មិនមែនដែរ គឺអាយតនៈដែលប្រែថាលំនៅឬដែនកើតរបស់ព្រះនិព្វាននោះគ្មានក្នុងឱកាសលោកនេះ ។ លំនៅឬដែនកើតនោះ គ្មានចលនាទៅមក

គ្មានទីតាំងនៅ ស្លាប់ កើត និងគ្មានអារម្មណ៍ឡើយ ។

ត្រង់ចំណុចនេះ យើងបានដឹងច្បាស់ថា ឋានព្រះនិព្វាន ជាឋានវិសេស នៅក្រៅចំហាយធាតុ ដី ទឹក ភ្លើង ខ្យល់ ក្រៅឱកាសលោក ពិតជាស្ថានប្រាសចាកហេតុបច្ច័យ សមជាទីនៅអាស្រ័យរបស់ផលញាណនៃព្រះខីណាស្រពទាំងឡាយ ដែលលោកបានចម្រាញ់ អស់ចំហាយធាតុហើយ ជាផលញ្ញាណប្រាសចាកហេតុបច្ច័យដូចគ្នា ។

ពាក្យថា អាយតនៈក្នុងពុទ្ធភាសិតនេះមានមតិខ្លះបកស្រាយថា «មិនមែនជាអាយតនៈ ដែលប្រែថា ល់នៅដែនកើត ជាទីស្ថានព្រះនិព្វាននោះទេ, អាយតនៈនេះជាឈ្មោះព្រះនិព្វាន គឺជាព្រះនិព្វានជាអាយតនៈ, ដែលថាព្រះនិព្វានជាអាយតនៈនោះសំដៅសេចក្តីថា ធម្មាយតនៈ គឺធម្មារម្មណ៍ ដែលចិត្តត្រូវពឹងផ្អែកក្នុងការឈានឡើងកាន់លោកុត្តរធម៌, ព្រោះថាក្នុងខណៈចិត្តឡើងកាន់អរិយមគ្គនោះ អាយតនៈគឺព្រះនិព្វានមកប្រាកដ

ក្នុងចិត្ត» ។ អាស្រ័យហេតុនេះទើបចាត់ទុកព្រះនិព្វានជាអាយតនៈក្រៅ ចិត្តជាអាយតនៈក្នុង ។

មតិនេះប្រហែលគេយល់ថា គ្មានឋានព្រះនិព្វានទេ ។ បើគ្មានឋានព្រះនិព្វានពិតមែននោះ មតិនេះពិតជាត្រូវ ។ ត្រង់ពុទ្ធភាសិតថា មិនមែនជាអាយតនៈក្នុងលោកនេះ ។ល។ នឹងថាគ្មានអារម្មណ៍នោះខុសទៅវិញ ។ ព្រោះព្រះនិព្វាន ដែលមតិខាងលើនេះថាជាអាយតនៈ គឺធម្មាយតនៈនោះ ជាអាយតនៈខាងក្រៅ ដែលជាអាយតនៈទី ៦ ក្នុងលោកនេះ ជាគូនិងមនាយតនៈគឺចិត្តដែលជាអាយតនៈខាងក្នុងជាអាយតនៈទី ៦ក្នុងលោកនេះដែរ ។ កាលបើមនាយតនៈស្រូបបានធម្មាយតនៈមកធ្វើជាធម្មារម្មណ៍, ធម្មារម្មណ៍នោះ មានមនាយតនៈនោះឯងជាទីកើតនៅ ជាទីប្រព្រឹត្តិទៅ ។ មានន័យដូចគ្នានិងធម្មាយតនៈក្នុងអនុស្សតិទី ១០ គឺឧបសមានុស្សតិ ដែលយកព្រះនិព្វានជាធម្មារម្មណ៍នោះដែរ ។ ឃើញថាផ្ទុយនឹងពុទ្ធភាសិតដែលថា មិនមែន

ជាសាយតនៈក្នុងលោកនេះ មិនមានទីតាំងនៅមិនមានការប្រព្រឹត្តិទៅ គឺជាមិនមានអារម្មណ៍នោះទាំងស្រុង ។

ការសើរើរបស់អ្នកនិពន្ធនេះ គ្រាន់តែជាបតិជំទាស់មួយ សម្រាប់ពិចារណាការសេចក្តីពិត ឲ្យឃើញសមហេតុផល ក្នុងរឿងព្រះនិព្វានប៉ុណ្ណោះ ។

## អំពីសេចក្តីសុខក្នុងឋាននិព្វាន

រឿងសេចក្តីសុខក្នុងឋាននិព្វាន ក៏ជាបញ្ហាមួយ ដែលដែលមនុស្សលោកពិបាកយល់ដែរ ទោះបីព្រះសម្ពុទ្ធបរមគ្រូនិងព្រះអរហន្តជាពុទ្ធសាវកទាំងឡាយ បានសំដែងពន្យល់សព្វគ្រប់មានក្នុងត្រៃបិដកពុទ្ធសាសនាហើយ ក៏មនុស្សលោកបុថុជ្ជនសព្វថ្ងៃ ស្តាប់ការសុខក្នុងឋាននិព្វាននោះមិនសូវបាន, ដូចពាក្យថា:

«ព្រះនិព្វាន គ្មានការកើត គ្មានការស្លាប់ គ្មានទុក្ខ មានតែបរមសុខម្យ៉ាង,, ពាក្យនេះគេមិនយល់ថា អ្នកនិយាយនោះចង់ថាម៉េចឡើយ, គេឆ្ងល់ថា បើគ្មានកើតបានគឺនឹងស្លាប់

បើគ្មានស្លាប់បានអីនឹងកើត? បើកើតក៏គ្មានស្លាប់ក៏គ្មាន បានតែទទេ!, បើទទេ បានអីនឹងទទួលបរមសុខ?

បញ្ហានេះ អ្នកនិពន្ធខ្ញុំ ទុកជូនមិត្រអ្នកអានទាំងឡាយ ដែលចេះភាសានិព្វានជួយដោះស្រាយ បកប្រែផងចុះ ៗ

ឯសេចក្ដីសុខក្នុងឋាននិព្វាននោះ មានច្រើនយ៉ាងណាស់ សុទ្ធតែជាភាសានិព្វានដែរ ពិបាកយល់ ៗ បើប្រៀបឱ្យងាយស្ដាប់ តាមលំនាំភាសាខ្មែរយើងថា សេចក្ដីសុខស្ងប់បែបណា, ការមិនក្ដៅក្រហាយខ្វល់ខ្វាយចិត្ត ព្រោះការស្រេកឃ្លាន មានក្រចាញ់ឈ្នះ ព្រាត់ប្រាសបែបណា, សេចក្ដីចំរើនរុងរឿងបែបណា, ជោគជ័យសិរីមង្គលបែបណា ដែលមនុស្សសព្វ ទេពតាមារព្រហ្ម មិនធ្លាប់បានស្គាល់ជាតិសោះ ក្នុងទុកាសលោកនេះ, សេចក្ដីសុខស្ងប់ជាដើមបែបនេះឯង ជាបរមសុខក្នុងឋាននិព្វានបរមសុខនោះ បានជាវិសេសប្លែកយ៉ាងនោះ ព្រោះមិនមែនកើតមានមកពីធាតុ ដី ទឹក ភ្លើង ខ្យល់ អាកាស មិនមែនកើតអាង

មកពីបុណ្យផ្ទាល់ឡើយ គឺកើតមានពីផលរបស់ផលបុណ្យ ហៅជាផលវិបាក គ្មានហេតុបច្ច័យតាក់តែង ជាគូនឹងផលញាណ ដែលកើតមានពីលោកុត្តរចិត្ត ឥតហេតុបច្ច័យតាក់តែងដូចគ្នា ។

ចំណែកខាងវត្ថុធាតុដើម របស់ផលញាណនោះ ដើមបំផុត គឺធាតុ ដី ទឹក ភ្លើង ខ្យល់ អាកាស ដែលជាគូអវិជ្ជា, ចលនានៃធាតុនោះគឺសង្ខារផ្សំផ្គុំឲ្យកើតជាតិណាជាតិមួយ, កើតជាញាណ ជាវិញ្ញាណ ជាចិត្ត ។ ការផ្ទុះខាត់បម្រាញ់ចិត្តនោះ ឲ្យប្រាសចាកលំនាំធាតុដើម អស់ការកើត ចាស់ ឈឺ ស្លាប់ អស់ហេតុបច្ច័យ គឺលោកុត្តរធម៌, លោកុត្តរធម៌បម្រាញ់បានហើយ កើតជាលោកុត្តរចិត្ត, ទីបំផុតលោកុត្តរចិត្តនោះ គឺផលញាណ សំដៅយកចិត្តព្រះខីណាស្រព ដែលលោកសម្រេចនូវនិព្វាន លះបង់ទុកាសលោកហើយ ។

ផលញាណនេះឯង មិនបានទៅចាប់ជាតិកើតជាថ្មីកង បាននិព្វានទៀតឡើយ ព្រោះបានកើតពីលោកុត្តរធម៌រួចស្រេច

ហើយ គ្រាន់តែទៅនៅក្នុងឋាននិព្វាននោះតែម្តង, អាស្រ័យហេតុនេះ ទើបក្នុងឋាននិព្វាននោះ គ្មានការកើត គ្មានសេចក្តីស្លាប់ មានតែបរមសុខម្យ៉ាង ។

## អត្ថបទប្រៀបធៀបអំពីរឿងនិព្វាន

១- ផលវិបាក និងផលញាណ បុរាណបណ្ឌិតប្រៀបដូចប្រេងដូង ។

២- បុណ្យនិងចិត្តប្រៀបដូចផ្លែដូងទុំៗ បើគេមិនចង់ឲ្យផ្លែដូងទុំនោះផុះតទៅទៀត គេកាប់កោសពូតយកខ្ទិះស្ងួចហ្រាញ់ដកហូតយកជាតុដីទឹកភ្លើងខ្យល់អាកាសគ្រោតគ្រាតចេញ កើតជាប្រេងៗ

៣- កាលកើតជាប្រេងហើយ គេមិនដែលយកប្រេងនោះចាក់ដាក់ក្នុងដីដូចកាលដាំវានោះទៀតឡើយ គេដាក់ក្នុងទីផ្សេង គឺក្នុងដប ឬកែវ ។

៤- ប្រេងដូងនោះ នឹងថាផុះកើតជាដើមដូងទៀតក៏មិនមែន នឹងថាប្រេងដូងនោះស្លាប់ក៏មិនមែន ។

៥– ផ្លែផ្កាទុំនោះជាសត្យទេ ក៏មិនមែន ព្រោះមានគ្រាប់ពូជដែលកើតពីផ្លែផ្កាទុំនោះ ។

៦– គ្រាប់ពូជទុំនោះ គឺជាមិនដឹងអ្វីសោះ ក៏មិនមែន, បើមានធាតុត្រជាក់ទៅប៉ះ វាបេះកក, មានធាតុក្ដៅទៅប៉ះវាបេះរលាយ ។

៧– គ្រាប់ពូជនោះ មានការទៀងទាត់ជាងផ្លែផ្កាទុំ វាលែងអស់លែងស្លាប់ទៀតហើយ ព្រោះគេកាប់បំបែកកោស ពួតចម្រាញ់ ដកទាត់យកធាតុ ដី ទឹក ភ្លើង ខ្យល់អាកាស គ្រោតគ្រាតចេញអស់ហើយ ។

(ចប់ដោយសង្ខេប)

អត្ថបទប្រៀបធៀបទាំង ៧ យ៉ាងនេះ មានន័យជ្រាលជ្រៅ ប្រកបដោយគោលការណ៍ច្បាស់លាស់ ចំពោះរឿងនិព្វាន, សូមមិត្តអ្នកអានទាំងឡាយ ពិចារណា វែកញែកសាកល្បងមើលកុំខាន ក្នុងពេលដែលបានអានសៀវភៅនេះចប់ហើយ ។

ភ្នំពេញថ្ងៃទី ២៥ វិច្ឆិកា ១៩៦៧

សុង - ស៊ីវ

**មានលក់ដុំ និង លក់រាយ**

នូវសៀវភៅធម៌គ្រប់មុខគ្រប់ប្រភេទ នៅ

“បណ្ណាគារត្រៃរតន៍” ផ្ទះលេខ 136Eo

វិថីខេមរភូមិន្ទ រាជធានីភ្នំពេញ

សូមនិមន្ត និង អញ្ជើញដោយមេត្រីភាព ។